# ក្រសួងអប់រំ យុវជន និងកីឡា
**Ministry of Education Youth and**


**វិទ្យាស្ថានជាតិអប់រំ**
**National Institute of Education**

**ជិន ភិរម្យ**
**CHIN PHIRUM**


**និក្ខេបបទ**

# ទស្សនៈយល់ឃើញរបស់នាយកសាលា និងគ្រូវិទ្យាល័យ លើការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី

## The views of Upper Secondary School Teachers and Principals on the implementation of new curriculum Framework

Case Study **Prey Veng** Province

**និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំឯកទេស**
**វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

**ភ្នំពេញ ២០១៩**

**ក្រសួងអប់រំ យុវជន និងកីឡា**

**Ministry of Education Youth and Sport**

**វិទ្យាស្ថានជាតិអប់រំ**

**National Institute of Education**

**ជិន ភិរម្យ**

**CHIN PHIRUM**

# ទស្សនៈយល់ឃើញរបស់នាយកសាលា និងគ្រូវិទ្យាល័យ លើការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី

**The views of Upper Secondary School Teachers and Principals on the implementation of new curriculum Framework**

**ករណីសិក្សា៖ ខេត្តព្រៃវែង**

**Case Study៖ Prey Veng Province**

**និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ**

**ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

**សាស្ត្រាចារ្យណែនាំ៖**

**ឯ.ឧ.បណ្ឌិត សៀង សុវណ្ណា សាស្ត្រាចារ្យណែនាំគោល**

**ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩**

**ក្រសួងអប់រំ យុវជន និកីឡា**

**Ministry of Education Youth and Sport**

**វិទ្យាស្ថានជាតិអប់រំ**

**National Institute of Education**

**ជិន ភិរម្យ**

**CHIN PHIRUM**

# ទស្សនៈយល់ឃើញរបស់នាយកសាលា និងគ្រូវិទ្យាល័យ លើការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី

# The views of Upper Secondary School Teachers and Principals on the implementation of new curriculum Framework

Case Study៖ **Prey Veng** Province

គណៈកម្មការវាយតម្លៃនៃការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ

ឯកទេស៖**វិជ្ជាជីវៈ**នាយកសាលាមធ្យមសិក្សាទុតិយភូមិ

ថ្ងៃទី ខែ ឆ្នាំ២០២០

និក្ខេបបទនេះត្រូវបានវាយតម្លៃដោយ៖

______________________________

______________________________

ប្រធានគណៈកម្មការ

______________________________

______________________________

គ្រូវាយតម្លៃទី១

______________________________

______________________________

គ្រូវាយតម្លៃទី២

______________________________

______________________________

គ្រូវាយតម្លៃទី៣

សមាជិក

សមាជិក

លេខាកត់ត្រា

# ឯកភាពដោយ៖

**តំណាងក្រសួងអប់រំ យុវជន និងកីឡា**

**ឯកឧត្តមបណ្ឌិត ជ័យ  សារិន**

**នាយកវិទ្យាស្ថានជាតិអប់រំ**

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទឈ្មោះ **ជិន ភិរម្យ** សូមបញ្ជាក់ថានិក្ខេបបទដែលមានចំណងជើង«**ទស្សនៈយល់ឃើញរបស់នាយកសាលា និងគ្រូវិទ្យាល័យលើការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី**»ករណីសិក្សាវិទ្យាល័យក្នុងខេត្ត **ព្រៃវែង** សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ ឬសាកលវិទ្យាល័យណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ឬខ្លឹមសារអ្វីមួយត្រូវបានយកមកប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាត ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវ និងចងក្រងខាងលើនេះពិតជាការស្រាវជ្រាវរបស់ខ្ញុំបាទប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

ហត្ថលេខា

**ជិន ភិរម្យ**

# ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ក្នុងនាមជាសាស្ត្រាចារ្យណែនាំគោល និងណែនាំរង នៃការសរសេរនិក្ខេបបទស្រាវជ្រាវនេះសូមបញ្ជាក់ថាបេក្ខជនឈ្មោះ **ជិន តិរម្យ** ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវខាងលើប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

សាស្ត្រាចារ្យណែនាំ

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណ ដល់អ្នកទាំងអស់គ្នាដែលបានចូលរួមចំណែកជួយជ្រោមជ្រែង និងលះបង់ពេលវេលាដ៏មានតម្លៃក្នុងការចងក្រងនិក្ខេបបទនេះឡើង។ ជាបឋម ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកឪពុក **អ៊ុន ឈិន** និងអ្នកម្តាយ **ផាត់ សាមាន** ដែលអ្នកមានគុណទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ផ្តល់នូវដំបូន្មានល្អៗ និងបានបញ្ជូនកូនឱ្យចូលរៀនតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ដោយមិនគិតពីការនឿយហត់និងលំបាក ព្រមទាំងតស៊ូគ្រប់បែបយ៉ាងដើម្បីកូនទទួលបានចំណេះដឹងដល់សព្វថ្ងៃនេះ និងសូមថ្លែងអំណរគុណដល់លោកឪពុកក្មេក **ញ៉ុច លី** អ្នកម្តាយក្មេក **គង់ យឿន** លោកស្រី **ញ៉ុច ស៊ីថាន់** ជាភរិយា និងកូនទាំងពីរជាទីស្រឡាញ់ ដែលបានជួយជ្រោមជ្រែងផ្នែកថវិកា ស្មារតីនិងលើកទឹកចិត្តឱ្យខ្ញុំបាទបានបន្តការសិក្សាឯកទេសវិជ្ជាជីវៈនាយកសាលា មធ្យមសិក្សាទុតិយភូមិជំនាន់ទី២ឆ្នាំសិក្សា ២០១៨-២០១៩។សូមថ្លែងអំណរគុណឯកឧត្តម **បណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំដែលបានរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលនាយកសាលានេះឡើងដើម្បីឱ្យនាយកសាលាក្លាយជាអ្នកគ្រប់គ្រងអប់រំល្អប្រកបដោយប្រសិទ្ធភាពនៅក្នុងសាលារៀន។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តម **បណ្ឌិត សៀង សុវណ្ណា** ជាសាស្ត្រាចារ្យណែនាំគោលដែលបានផ្តល់នូវមតិយោបល់ល្អៗពីរបៀបរៀបចំកម្រងសំណួរ ការជ្រើសសំណាកដើម្បីធ្វើការសម្ភាស ជាពិសេសជំរុញឱ្យយើងខ្ញុំខិតខំប្រឹងប្រែងជម្នះឧបសគ្គដើម្បីសម្រេចបាននូវការសរសេរនិក្ខេបបទនេះរហូតទទួលបានជោគជ័យប្រកបដោយមោទនភាព។

សូមថ្លែងអំណរគុណចំពោះឯកឧត្តម **បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតឱ្យមានវគ្គបណ្តុះបណ្តាលនាយកសាលានេះឡើង។ សូមថ្លែងអំណរគុណផងដែរដល់លោកនាយក នាយករង លោកគ្រូ អ្នកគ្រូទាំងអស់នៃ **វិទ្យាល័យ បឹងព្រះ វិទ្យាល័យ ជា ស៊ីមរក្សជ័យ វិទ្យាល័យបាភ្នំ និងវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន កំពង់លាវ** ដែលបានអនុញ្ញាត និងសហការក្នុងការចូលរួមបំពេញកម្រងសំណួរធ្វើឱ្យការប្រមូលទិន្នន័យសម្រាប់ការសរសេរនិក្ខេបបទនេះទទួលបានជោគជ័យ។

-មិត្តភក្តិរួមជំនាន់ទី២ទាំងអស់នៃវគ្គនាយកសាលា ដែលបានជួយផ្តល់យោបល់និងមតិក្នុងការកែលម្អហើយជួយរកឯកសារពាក់ព័ន្ធនិក្ខេបបទនេះ។

-គ្រូឧទ្ទេសគ្រប់មុខវិជ្ជានៅវិទ្យាស្ថានជាតិអប់រំ គ្រូឧទ្ទេសគ្រប់មុខវិជ្ជានៅ អគ្គនាយកដ្ឋាន និង នាយកដ្ឋានផ្សេងៗនៃក្រសួងអប់រំ យុវជន និងកីឡាដែលបានជួយជ្រោមជ្រែង ដូចជាការផ្តល់មតិយោបល់ និងឯកសារល្អៗជាច្រើនក្នុងកិច្ចការស្រាវជ្រាវនេះ។

ជាទីបញ្ចប់ សូមគោរពជូនពរលោកអ្នកមានគុណទាំងបួន ជូនពរឧត្តមភរិយាជាទីស្រឡាញ់និងក្រុមគ្រួសារ ឯកឧត្តម លោក លោកស្រីទាំងអស់ជួបតែសេចក្តីសុខ កម្លាំងមាំមួន សុខភាពល្អនិងសម្រេចគ្រប់ភារកិច្ចនិងកិច្ចការទាំងអស់។

ថ្ងៃ...........ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...... ខែកញ្ញា ឆ្នាំ២០២០

និស្សិតវគ្គនាយកសាលា

**ជិន តិរម្យ**

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដើម្បីស្វែងរកឱ្យឃើញនូវៈ (១) ចំណេះដឹងរបស់អ្នកអនុវត្តក្របខណ្ឌកម្មវិធីសិក្សា (២) ទស្សនៈយល់ឃើញពីការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅថ្មីដែលក្រសួងអប់រំ យុវជន និងកីឡា ដាក់ឱ្យអនុវត្ត (៣) ចំណុចវិជ្ជមាន និងបញ្ហាប្រឈមនៅពេលអនុវត្តកម្មវិធីសិក្សាថ្មីនេះ ព្រមទាំងមធ្យោបាយក្នុងការដោះស្រាយ ហើយការសិក្សាស្រាវជ្រាវនេះគឺមិនផ្អែកទៅលើភេទ ឋានៈតួនាទី មុខវិជ្ជាឯកទេស កម្រិតវប្បធម៌ និងបទពិសោធក្នុងការគ្រប់គ្រង ការបង្រៀនរបស់ពួកគាត់ឡើយ។ ភាគសំណាកក្នុងការសិក្សាស្រាវជ្រាវនេះគឺមាន គណៈគ្រប់គ្រងចំនួន **១៣នាក់** លោកគ្រូ អ្នកគ្រូចំនួន **១៤៥ នាក់ សរុបមានចំនួន ១៥៨ នាក់**។ក្នុងចំណោមគណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូទាំងអស់នោះគឺពួកគាត់កំពុងគ្រប់គ្រង និងបង្រៀននៅកម្រិតវិទ្យាល័យលើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ភូមិវិទ្យា ផែនដីវិទ្យា ភាសាខ្មែរ គេហវិទ្យា សីលធម៌ពលរដ្ឋវិទ្យា ប្រវត្តិវិទ្យា និង ភាសាបរទេស នៅក្នុងវិទ្យាល័យចំនួនបួន ក្នុងខេត្តព្រៃវែង គឺ **វិទ្យាល័យបឹងព្រះ វិទ្យាល័យជា ស៊ីម រក្សជ័យ** ដែលជាវិទ្យាល័យស្ថិតនៅទីជនបទ **វិទ្យាល័យ បាភ្នំ** ស្ថិតនៅទីប្រជុំជនស្រុក និង**វិទ្យាល័យសម្តេចតេជោ ហ៊ុន សែន កំពង់លាវ** ស្ថិតនៅទីប្រជុំជនខេត្ត/ក្រុង។ឧបករណ៍ប្រើប្រាស់សម្រាប់សិក្សាស្រាវជ្រាវនេះគឺកម្រងសំណួរដែលរៀបចំឡើងដោយខ្ញុំបាទ ដែលជាអ្នកស្រាវជ្រាវ ហើយត្រូវបានបែងចែកជាពីរផ្នែកគឺៈ(១) ព័ត៌មានផ្ទាល់ខ្លួនរបស់គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូ អ្នកគ្រូដែលជាអ្នកចូលរួមផ្តល់ចម្លើយ (២) ចំណេះដឹង និងទស្សនៈយល់ឃើញដែលទាក់ទងទៅនឹងក្របខណ្ឌកម្មវិធីសិក្សាថ្មី ដោយបង្ហាញពីចំណុចវិជ្ជមាន បញ្ហាប្រឈម ព្រមទាំងមធ្យោ-បាយក្នុងការដោះស្រាយផងដែរ។ ទិន្នន័យដែលប្រមូលបានត្រូវយកមកផ្តុំជាគំនិតរួម ទស្សនៈរួមដូចគ្នា ឬមានប្រហាក់ប្រហែលគ្នា រួចយកមកបង្កើតជាតារាងទិន្នន័យហើយធ្វើការវិភាគតាមបែប បរិមាណវិស័យផង និងតាមបែបគុណវិស័យផង។ក្នុងការវិភាគនេះនឹងប្រើប្រាស់កម្មវិធី EXCEL ដើម្បីស្វែងរកចំនួន ប្រេកង់(Frequency) ភាគរយ(%) ដ្យាក្រាម និងក្រាប ។

លទ្ធផលដែលទទួលបានសំខាន់ៗក្នុងការសិក្សាស្រាវជ្រាវនេះអាចសង្ខេបបានដូចខាងក្រោមៈ

១). គណៈគ្រប់គ្រងចំនួន ៩៦.១៥% លោកគ្រូ អ្នកគ្រូចំនួន ១៨.៦៦% មាន ចំណេះដឹងច្រើនឬយល់ច្រើនលើគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាគោល ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និង គណៈគ្រប់គ្រងប្រហែល៣៨.៤៦% លោកគ្រូ អ្នកគ្រូប្រហែលជា១២.៤១% មានចំណេះដឹងតិចតួច ហើយនិងគណៈគ្រប់គ្រង ១៥.៣៨% និងលោកគ្រូ អ្នកគ្រូ ៦៩.០០% យល់ច្រឡំកម្មវិធីសិក្សាទៅនឹងបំណែងចែកកម្មវិធីសិក្សាឬសេវាសម្រាប់បង្រៀនប្រចាំសប្តាហ៍ ប្រចាំខែ ដោយរៀបរៀងចេញពីសៀវភៅសិក្សាគោល។ លើសពីនេះទៅទៀតពួកគាត់យល់ឃើញថាការអភិវឌ្ឍកម្មវិធីសិក្សាថ្មីគឺសំដៅលើការកែប្រែ ឬផ្លាស់ប្តូរសៀវភៅសិក្សាគោលថ្មី។ ហើយការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព គឺសំដៅលើការបញ្ចប់មេរៀនដែលមាននៅក្នុងសៀវភៅសិក្សាគោលឬបំណែងចែកមេរៀនដែលត្រូវបង្រៀនប្រចាំឆ្នាំឱ្យទាន់ពេលដែលបានកំណត់ ហើយសិស្សមានគុណភាព ឬលទ្ធផលសិក្សាល្អទៀត ប៉ុន្តែប្រហែលជា៨៤%នៃពួកគាត់បានឱ្យតម្លៃទៅលើការទាន់បំណែងចែកមេរៀន ឬផែនការបង្រៀនប្រចាំឆ្នាំជាជាងគុណភាពទៅវិញដោយសារខ្លាចទទួលបានការស្តីបន្ទោសពីថ្នាក់លើ។

២). ក្នុងចំណោម គណៈគ្រប់គ្រងនិង លោកគ្រូ អ្នកគ្រូសរុប១៥៨នាក់ អ្នកដែលមានទស្សនៈយល់ឃើញថា ការបែងចែកបណ្តុំមុខវិជ្ជានេះគឺជាការល្អ មានចំនួន ១១៣ នាក់ ស្មើនឹង ៧១.៥១% ហើយតាមការផ្តុំគំនិត ឬទស្សនៈរបស់ពួកគាត់ដែលបានបញ្ចេញដូចគ្នា និងប្រហាក់ប្រហែលគ្នានោះថា ការបែងចែកបណ្តុំមុខវិជ្ជានេះធ្វើឱ្យ សិស្សជ្រើសរើសមុខវិជ្ជាដែលខ្លួនចូលចិត្ត ហើយមានពេលវេលាច្រើនសម្រាប់ខិតខំប្រឹងប្រែងរៀនសូត្រលើមុខវិជ្ជាដែលខ្លួនបានជ្រើសរើស ហើយចំនួន៣៦ នាក់ទៀត ស្មើនឹង ២២.៧៨%មានទស្សនៈថា មិនល្អ ព្រោះសិស្សមិនសូវខិតខំសិក្សាលើមុខវិជ្ជាដែលក្រៅពីបណ្តុំមុខវិជ្ជា ដែលពួកគេជ្រើសរើស។ ដោយឡែកចំនួន ៣ នាក់ទៀត ស្មើនឹង១.៩០% មានទស្សនៈថា ការបែងចែកនេះ មានគុណសម្បត្តិផង និងគុណវិបត្តិផង ព្រោះសិស្សមួយចំនួនធំជ្រើសរើសមុខវិជ្ជាតាមចំណង់ចំណូលចិត្ត ហើយខិតខំរៀនសូត្រ ឯសិស្សខ្លះទៀតជ្រើសរើសតាមមិត្តភក្តិ មិនមានការពិចារណាត្រឹមត្រូវ រួចពេលមានការលំបាកក្នុងការសិក្សានោះ នាំឱ្យមានការបោះបង់ការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ និងចំនួន៦ នាក់តៀតស្មើនឹង ៣.៨០% មិនមានទស្សនៈថា ល្អ ឬមិនល្អទេ ព្រោះកម្មវិធីសិក្សាថ្មីនេះមិនទាន់បានអនុវត្តផង និងចំនួន ៨៧ នាក់ស្មើនឹង៥៥.០៦% មានទស្សនៈថា អនុវត្តកម្មវិធី

សិក្សាថ្មី ដែលបង្រៀន និងរៀន ៤០ ម៉ោងក្នុងមួយសប្តាហ៍បាននិងមានចំណុចវិជ្ជមានច្រើន ហើយ៧១នាក់ស្មើនឹង៤៤.៩៥% មានទស្សនៈថាអនុវត្តមិនបាន ។

៣).បញ្ហាប្រឈមចម្បងៗដែលពួកគាត់ជួបប្រទះគឺខ្វះខាតសិទ្ធក្នុងការសម្រេចចិត្តនៅក្នុងថ្នាក់រៀន ភាពខ្វះចន្លោះនៅក្នុងសៀវភៅសិក្សាគោល គ្មានការសហការ និងចែករំលែកចំណេះដឹងរវាងសមាជិកក្រុមមុខវិជ្ជាដូចគ្នាខ្វះបន្ទប់ពិសោធន៍ឬបន្ទប់ ICT ខ្វះខាតសម្ភារៈឧបទេស សៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា គ្រប់កម្រិតបានអភិវឌ្ឍរួចហើយតាមកម្មវិធីសិក្សាមុន ពិសេសថ្នាក់ទី១១ និងទី១២(មុខវិជ្ជាគោល និងជម្រើស) តែត្រូវការកាត់ម៉ោងសិក្សា កាត់ខ្លឹមសារមេរៀនឱ្យស្របទៅតាមសេចក្តីណែនាំថ្មី។ មិនបានបំប៉នគ្រូដើម្បីកែសម្រួលការបង្រៀនតាមសេចក្តីណែនាំថ្មី ត្រូវការរៀបចំថ្នាក់ គ្រូទៅតាមបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នាយកសាលា គ្រូ សិស្ស សហគមន៍ មិនយល់អំពីគោលការណ៍ច្បាស់ពីបណ្តុំទាំងពីរនេះ ការជ្រើសរើសបណ្តុំទាំងពីរនេះដោយប្រថុយប្រថាន តាមគ្នា ឬតាមការរៀបចំ របស់សាលានីមួយៗ មានភាពរើសអើង ទាំងគ្រូ ទាំងសិស្ស មានប្រតិកម្មពីគ្រូមុខវិជ្ជាខ្លះអំពីបញ្ហាម៉ោងសិក្សា ។

ប្រសិនបើមានការអភិវឌ្ឍកម្មវិធីសិក្សាថ្មី ពួកគាត់សំដៅលើការផ្លាស់ប្តូរសៀវភៅសិក្សាគោលថ្មី លោកគ្រូ អ្នកគ្រូ ត្រូវការសៀវភៅគ្រូ បើទោះបីជាគាត់មិនបានអនុវត្តតាមទាំងស្រុងក៏ដោយ។ ក្រៅពីសៀវភៅគ្រូ ពួកគាត់ត្រូវការបណ្តុះបណ្តាលលើខ្លឹមសារមេរៀនថ្មី ការគាំទ្រពីប្រធានក្រុមបច្ចេកទេសឱ្យបានត្រឹមត្រូវ សមត្ថភាពសិស្សត្រូវឱ្យស្មើនឹងកម្រិតថ្នាក់ដែលពួកគាត់កំពុងរៀន ចំនួនម៉ោង និងចំនួនមេរៀនឱ្យស៊ីគ្នា និងសំណូមពរឱ្យអ្នករៀបចំកម្មវិធីសិក្សាមុខវិជ្ជាផ្សេងៗគ្នាធ្វើការជាមួយគ្នា ដើម្បីជៀសវាងភាពច្រំដែលនៃមេរៀនរវាងមុខវិជ្ជាផ្សេងគ្នា កម្រិតខ្លឹមសារមេរៀនមានការស៊ីសង្វាក់គ្នារវាងមុខវិជ្ជា សូមធ្វើការពិនិត្យសៀវភៅសិក្សាគោលឱ្យបានច្បាស់លាស់មុននឹងបោះពុម្ពចែកចាយប្រើប្រាស់។

# មាតិកា


សេចក្តីប្រកាសរបស់បេក្ខជន....................................................................................................... iv

ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ ..................................................................................................... v

សេចក្តីថ្លែងអំណរគុណ ................................................................................................................. vi

មូលន័យសង្ខេប.........................................................................................................................viii

មាតិកា ......................................................................................................................................... xi

ជំពូកទី១........................................................................................................................................ 1

សេចក្តីផ្តើម ................................................................................................................................... 1

ជំពូកទី១........................................................................................................................................ 2

សេចក្តីផ្តើម ................................................................................................................................... 2

*១.១.សាវតារ .................................................................................................................. 2*

*១.២.បញ្ហានៃការស្រាវជ្រាវ............................................................................................. 6*

*១.៣.វត្ថុបំណងនៃការស្រាវជ្រាវ ...................................................................................... 8*

*១.៤.សំណួរស្រាវជ្រាវ ..................................................................................................... 8*

*១.៥.សារៈសំខាន់នៃការស្រាវជ្រាវ..................................................................................... 8*

*១.៦.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ................................................................. 9*

*១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ* ........ *9*

**ជំពូកទី២** ........ **10**

**រំលឹកទ្រឹស្តី** ........ **10**

**ជំពូកទី២** ........ **11**

**រំឭកទ្រឹស្តី** ........ **11**

*២.១.និយមន័យពាក្យគន្លឹះ និងទ្រឹស្តីពាក់ព័ន្ធ* ........ *11*

*២.១.១ និយមន័យ: កម្មវិធីសិក្សា( CURRICULUM )* ........ *11*

២.១.២.គោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា/ក្របខណ្ឌកម្មវិធីសិក្សា ........ 12

២.១.៣.កម្មវិធីសិក្សាគោល( Core curriculum ) ........ 13

២.១.៤.ស្តង់ដាកម្មវិធីសិក្សា( Curriculum Standart ) ........ 14

២.១.៥.កម្មវិធីសិក្សាលម្អិត( Syllabus ) ........ 14

២.១.៦.ខ្លឹមសារកម្មវិធីសិក្សា( Curriculum Content ) ........ 15

២.១.៧.រង្វាយតម្លៃ ........ 15

២.១.៨.ការអនុវត្តកម្មវិធីសិក្សា( Curriculum Implementation ) ........ 16

*២.២.ឯកសារផ្សេងៗទាក់ទងនឹងកម្មវិធីសិក្សា* ........ *16*

*២.៣.ការអនុវត្តកម្មវិធីសិក្សាកន្លងមក* ........ *28*

*២.៤.បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា* ........ *31*

ជំពូកទី៣ ........ 35

វិធីសាស្ត្រស្រាវជ្រាវ ........ 35

*៣.១.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ........ 35*

*៣.២.វិធីសាស្ត្រនៃការប្រមូលទិន្នន័យ ........ 35*

*៣.៣. ការបង្កើតកម្រងសំណួរ ........ 36*

*៣.៤. កម្រងសំណួរ និងគោលបំណង ........ 36*

*៣.៥ ដំណើរការនៃការជ្រើសរើសនិងវិភាគសំណាក ........ 36*

*៣.៦.សង្ខេបដំណើរការស្រាវជ្រាវ ........ 37*

*៤.១ ចំណេះដឹងទាក់ទងទៅនឹងកម្មវិធីសិក្សាថ្មី ........ 40*

៤.១.១ការផ្តល់និយមន័យចំពោះពាក្យ ........ 40

៤.១.២ ការបានដឹង និងទទួលបានការផ្សព្វផ្សាយកម្មវិធីសិក្សាថ្មី ........ 41

៤.១.៣ ការធ្លាប់ និងមិនធ្លាប់បានទទួលវគ្គបណ្តុះបណ្តាល កម្មវិធីសិក្សាថ្មី ........ 42

៤.១.៤ ការបែងចែកបណ្តុំមុខវិជ្ជា ........ 43

៤.១.៥ ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងនិងគ្រូបង្រៀនលើការបែងចែកបណ្តុំមុខវិជ្ជា ........ 43

*៤.២.បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា ........ 46*

៤.២.២ មុខវិជ្ជាភាសាបរទេស ........ 47

៤.២.៣ មុខវិជ្ជាភាសាខ្មែរ ........ 47

៤.២.៤ មុខវិជ្ជារូបវិទ្យា ........ 47

៤.២.៥ មុខវិជ្ជាគីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យានិងបរិស្ថាន ........ 47

៤.២.៦ មុខវិជ្ជាភូមិវិទ្យា ........ 47

៤.២.៧ មុខវិជ្ជាប្រវត្តិវិទ្យា ........ 48

៤.២.៨ មុខវិជ្ជាសីលធម៌ពលរដ្ឋ ........ 48

៤.២.៩មុខវិជ្ជាគេហកិច្ច ........ 48

**ជំពូកទី៥ ........ 50**

*៥.១ សេចក្តីសន្និដ្ឋាន ........ 50*

៥.១.១ ចំណេះដឹងទាក់ទងនឹងកម្មវិធីសិក្សា ........ 51

៥.១.២ ទស្សនៈរបស់នាយកសាលា និងគ្រូបង្រៀនលើការបែងចែកបណ្តុំមុខវិជ្ជា និងការអនុវត្ត កម្មវិធីសិក្សា៤0ម៉ោងក្នុងមួយសប្តាហ៍ ........ 52

៥.១.៣ តម្រូវការក្នុងការអនុវត្តកម្មវិធិសិក្សាថ្មី ........ 54

*៥.២ ពិភាក្សាលើលទ្ធផលស្រាវជ្រាវ ........ 55*

៥.២.១ ចំណេះដឹងស្តីពីកម្មវិធីសិក្សា ........ 55

៥.២.២ បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធិសិក្សា ........ 57

*៥.៣ សំណូមពរ ........ 59*

**ឯកសារពិគ្រោះ ........ 61**

**ឧបសម្ព័ន្ធ ........ Error! Bookmark not defined.**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្ដីផ្ដើម

## ១.១.សាវតារ

ប្រទេសនីមួយៗនៅលើសកលលោក តែងចាត់ទុកវិស័យអប់រំ ជាវិស័យសំខាន់ ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស សម្រាប់បម្រើឱ្យសេចក្ដីត្រូវការ របស់សង្គមជាតិ។ ដោយសារសង្គមជាតិ មានការអភិវឌ្ឍឥតឈប់ឈរ ទើបវិស័យអប់រំត្រូវតែយកចិត្តទុកដាក់ខ្លាំង ទៅលើការអភិវឌ្ឍធនធានមនុស្សឱ្យទទួលបានចំណេះដឹង បំណិន សីលធម៌ល្អ និងមានបុគ្គលិកលក្ខណៈពេញលេញ ដើម្បីមានលទ្ធភាពចូលរួមចំណែក ក្នុងការអភិវឌ្ឍប្រទេសជាតិ ឱ្យមានការរីកចម្រើន។ ការកែលម្អវិស័យអប់រំគឺជាការធានានូវ ការលើកកម្ពស់គុណភាព ដែលជានិន្នាការរួមរបស់បណ្ដាប្រទេសក្នុងពិភពលោក។ ឯការអភិវឌ្ឍកម្មវិធីសិក្សា គឺជាការងារស្នូលនៃការបង្កើនគុណភាពនិងប្រសិទ្ធភាពអប់រំ។ ក្នុងការអភិវឌ្ឍកម្មវិធីសិក្សា ការបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សា (គោលនយោបាយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ,២០០៤) ឬការបង្កើតក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស(ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស,២០១៧) គឺជាការងារចាំបាច់បំផុត។ អស់រយៈពេលជាងពីរទសវត្សរ៍កន្លងទៅនេះ សាកលភាវូបនីយកម្មលើគ្រប់វិស័យ ជាពិសេស វិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្របច្ចេកទេស និងនយោបាយបានធ្វើឱ្យពិភពលោកកាន់តែមានការប្រកួតប្រជែងគ្នាផង និងសហការគ្នាផង ដើម្បីឈានទៅសម្រេច គោលដៅអភិវឌ្ឍសហវត្សរ៍ និងការអភិវឌ្ឍប្រកបដោយចីរភាព។ កំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំ គឺដើម្បីអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ហើយវាក៏ជាកត្តាកំណត់ពីភាពជោគជ័យនៃការអភិវឌ្ឍលើគ្រប់វិស័យផងដែរ។

វិស័យអប់រំជាបេះដូងនៃការអភិវឌ្ឍគ្រប់វិស័យ ទើបធ្វើឱ្យប្រទេសជាច្រើនមើលឃើញពីសារៈសំខាន់នៃវិស័យនេះ។ ប្រទេសកម្ពុជាក៏ជាប្រទេសមួយស្ថិតក្នុងចំណោមប្រទេសទាំងនោះ

ដែរ។ ដើម្បីឆ្លើយតបទៅនឹងសាកលភាវូបនីយកម្មនេះ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពដល់ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការពង្រឹងគុណភាពអប់រំដែលស្ថិតនៅមុំទី៤ ដោយយកអភិបាលកិច្ចល្អជាស្នូល ព្រោះការអប់រំប្រកបដោយគុណភាពនិងភាពឆ្លើយតបគឺជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍ ធនធានមនុស្សឱ្យត្រូវទៅនឹងតម្រូវការពលកម្មថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ហើយក៏ជួយ ឱ្យជីវភាពរបស់ប្រជាជនប្រសើរឡើង ធ្វើឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាពផងដែរ។ ការពង្រឹងគុណភាពអប់រំគឺជាកត្តាសំខាន់បំផុត ដើម្បីលើកស្ទួយសមត្ថភាពធនធានមនុស្ស និងក្លាយជាកម្លាំងស្នូល សម្រាប់ជំរុញការអភិវឌ្ឍសង្គមកម្ពុជាឱ្យទៅជាសង្គមពុទ្ធិនិងវិបុលភាព ផ្អែកលើចំណេះដឹង និងចំណេះធ្វើ ព្រមទាំងជួយលើកកម្ពស់សេដ្ឋកិច្ចប្រទេសជាតិទាំងមូលផងដែរ។ បច្ចុប្បន្នប្រទេសកម្ពុជាបាននិងកំពុងឆ្លងកាត់ពីឋានៈនៃប្រទេសដែលមានចំណូលទាប ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយកំពុងប្រែក្លាយខ្លួនឱ្យទៅជាប្រទេសមានប្រាក់ចំណូលមធ្យម កម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅ ឆ្នាំ២០៥០។ ដើម្បីសម្រេចចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើកំណែទម្រង់លើគ្រប់វិស័យ ជាពិសេសវិស័យអប់រំ សុខាភិបាល កសិកម្ម ឧស្សាហកម្ម និងទេសចរណ៍។ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវទិសដៅ កំណែទម្រង់ជាអាទិភាពចំនួន១៥ក្នុងរយៈពេលមធ្យម ពីឆ្នាំ ២០១៦-២០១៨ សម្រាប់កែទម្រង់វិស័យអប់រំរបស់ខ្លួន ជាពិសេស កែទម្រង់ ក្របខណ្ឌកម្មវិធី សិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ដើម្បីធានាថាកម្ពុជាមានធនធានមនុស្សដែលមាន សមត្ថភាពសម្រាប់បម្រើដល់គ្រប់វិស័យ។ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ត្រូវបានរៀបចំឡើងដើម្បីអប់រំពលរដ្ឋកម្ពុជាឱ្យទៅជាពលរដ្ឋពេញលេញ តាមរយៈ ការធ្វើ ទំនើបកម្មកម្មវិធីសិក្សាឱ្យមានលក្ខណៈស្តង់ដា ត្រូវទៅតាមតំបន់ និងអន្តរជាតិ ទាំងខ្លឹមសារ ឯកទេស វិធីសាស្ត្ររៀន និងបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងគោលបំណងធ្វើឱ្យសមត្ថភាពសិស្ស ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅកម្រិតជាតិ តំបន់ និងសកលលោក។

គុណភាពអប់រំបានទទួលរងឥទ្ធិពលពីកត្តាជាច្រើន ដូចជាកត្តាគុណភាពគ្រូបង្រៀន គុណភាពនាយកសាលារៀន គុណភាពសម្ភារឧបទេស និងជាពិសេសគឺកម្មវិធីសិក្សាដែលរួមបញ្ចូល

ទាំងឯកសារពាក់ព័ន្ធនឹង ក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ សៀវភៅសិស្ស ការអនុវត្តសម្ភារៈឧបទេស និងមន្ទីរពិសោធន៍វិទ្យាសាស្ត្រ។ ឯកសារទាំងអស់នេះ ត្រូវតែរៀបចំឡើងដោយមានការសិក្សាស្រាវជ្រាវ និងពិគ្រោះយោបល់ឱ្យបានល្អិតល្អន់ ទៅលើ មុខវិជ្ជា និងមុខវិជ្ជារងនីមួយៗ និងរវាងកម្រិតថ្នាក់ មួយទៅកម្រិតថ្នាក់មួយទៀត ដើម្បីធានា នូវប្រសិទ្ធភាព នៃការរៀន និងការបង្រៀន និងការពាក់ព័ន្ធនៃចំណេះដឹងសម្រាប់ បម្រើការ រស់ នៅប្រចាំថ្ងៃ។ ការរៀបចំបែបនេះ នឹងធ្វើឱ្យទំនាក់ទំនងនៃខ្លឹមសារមេរៀននៃ មុខវិជ្ជានីមួយៗ មានភាពប្រទាក់ក្រឡាគ្នា និងមានភាពរលូនទៅតាមការបែងចែកនៃការអភិវឌ្ឍកម្មវិធីសិក្សា តាមលក្ខណៈវិទ្យាសាស្ត្រ។ ក្របខណ្ឌកម្មវិធីសិក្សាត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានទស្សនៈ និងចក្ខុវិស័យថ្មីស្របតាមនិន្នាការអប់រំសាកល រដ្ឋធម្មនុញ្ញ ច្បាប់អប់រំ ផែនការជាតិអប់រំសម្រាប់ ទាំងអស់គ្នា និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣។ កម្មវិធីសិក្សាពីឆ្នាំ១៩៨០ ដល់ ឆ្នាំ២០០៩និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣បង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការ ប្រែក្លាយទៅជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ខាងមុខនេះ (ក្របខណ្ឌកម្មវិធីសិក្សា អប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស,២០១៦)។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពអប់រំតាមបណ្តាប្រទេស នៅក្នុងសហគមន៍ អាស៊ាន ដែលធានា ឱ្យអ្នកសិក្សាមានសមត្ថភាព និងភាពជាពលរដ្ឋពេញលេញ ឆ្លើយតបទៅនឹងតម្រូវការរបស់ ខ្លួន តម្រូវការក្នុងឧស្សាហកម្មថ្មីនៃទីផ្សារការងាររបស់ប្រទេសជាតិ តំបន់ និងសកលលោកដែល មានលក្ខណៈទាន់សម័យនិងបែបវិទ្យាសាស្ត្រ ក្រសួងអប់រំ យុវជន និងកីឡាមានតួនាទីយ៉ាង សំខាន់ក្នុងការដឹកនាំ និងបំពេញភារកិច្ចក្នុងការកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រកបដោយគុណភាព និងភាពឆ្លើយតប ឱ្យស្របទៅនឹងគោលនយោបាយធំៗចំនួន២គឺៈ(១) ធានាឱ្យការអប់រំមានគុណភាព សមធម៌ បរិយាប័ន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង(២) ធានាភាពស័ក្តិសិទ្ធិនៃភាព ជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់អប់រំលើចំណុចអាទិភាពចំនួន ១៥ ដោយឈរលើ មូលដ្ឋានសរសរស្តម្ភចំនួន៥គឺៈ (១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២) ការពិនិត្យឡើងវិញកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា (៣) ការដាក់ឱ្យអនុវត្តនូវការងារអធិការកិច្ច(៤)ការពង្រឹងការងារប្រឡង

និង(៥) ការកែទម្រង់ឧត្តមសិក្សា។ ការកែទម្រង់កម្មវិធីសិក្សាគឺជាសរសរស្តម្ភមួយក្នុងចំណោម សរសរស្តម្ភទាំង៥ ព្រោះវាពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព និងភាពឆ្លើយតប (ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេក ទេសឆ្នាំ ២០១៦) និង ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជ រដ្ឋាភិបាលនីតិកាល ទី៦ នៃរដ្ឋសភា។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការ យុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ហើយកម្ពុជាបាននិងកំពុងធ្វើកំណែទម្រង់យ៉ាងទូលំ ទូលាយ និងស៊ីជម្រៅលើគ្រប់វិស័យ ពិសេសវិស័យអប់រំ យុវជន និងកីឡា ដោយបានដាក់ចេញ នូវ វិធានការ អាទិភាព នៃ កំណែទម្រង់ វិស័យអប់រំ យុវជន និងកីឡាជាបន្តបន្ទាប់ ដែលក្នុងនោះ សរសរស្តម្ភទី២ក៏បានផ្តោតទៅលើការពិនិត្យឡើងវិញ នូវកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សាផងដែរ។

ក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំនូវ ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស សម្រាប់អប់រំ សិស្សានុសិស្សឱ្យក្លាយ ទៅជាពលរដ្ឋពេញ លេញប្រកបដោយវិជ្ជាសម្បទា (អក្ខរសាស្ត្រ លេខសាស្ត្រ ភាសាបរទេស បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍) បំណិនសម្បទា(អនុវត្តចំណេះដឹងនិងជំនាញ បំណិន ពិចារណានិងការបង្កើតថ្មី ការប្រាស្រ័យទាក់ទង និងការធ្វើការងារជាក្រុម) និងចរិយាសម្បទា (កាយសុខភាព ចិត្តសុខភាព អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម សហគ្រិនភាព និងភាព ជាអ្នកដឹកនាំ និងការទទួលខុសត្រូវ)(ក្របខណ្ឌកម្មវិធីសិក្សា,២០១៦)។ កាលពីអតីតកាល បន្ទាប់ ការដួលរលំនៃរបបប្រល័យពូជសាសន៍ ការអប់រំនៅកម្ពុជាបានអនុវត្តនូវគោលនយោបាយ "អ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនទាន់ចេះសោះ"។ នៅពេលនោះ ប្រទេសកម្ពុជាយើងនៅមានភាពក្រីក្រនៅឡើយ ដូចនេះ កម្មវិធីសិក្សាមិនត្រូវបានរៀបចំក្នុង កម្រិតខ្ពស់ដូចប្រទេសជឿនលឿនបានទេ។ ពោលគឺត្រូវរៀបចំដោយផ្តើមពីអ្វីដែលសមស្រប តាមសេដ្ឋកិច្ចនិងសង្គមជាតិជាក់ស្តែង ពិសេសគឺលៃយ៉ាងណា ធានាឱ្យសិស្សអាចទទួលបាន ចំណេះដឹងមូលដ្ឋានប្រកបដោយជោគជ័យ បន្ទាប់មកទើបរៀបចំឱ្យ ឈានឡើងបន្តិចម្តងៗ តាមប្រវត្តិ និងដំណាក់កាលនីមួយៗ (ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន,២០១៦ ) ។

## ១.២.បញ្ហានៃការស្រាវជ្រាវ

តាមរយៈការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៩- ២០១៣សៀវភៅផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៣-២០១៨ ទំព័រទី១០បានរៀបរាប់ថា ប្រព័ន្ធអប់រំនៅកម្ពុជានៅតែប្រឈមទៅនឹងបញ្ហាគុណភាពអប់រំនៅឡើយ ដោយប្រព័ន្ធអប់រំមិនទាន់អាចផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់ និងភាពឆ្លើយតបសម្រាប់កុមារ និងយុវជន។ គុណភាពអប់រំទទួលរង ឥទ្ធិពលពីកត្តាជាច្រើនជាពិសេស កម្មវិធីសិក្សា រាប់បញ្ចូលទាំងឯកសារពាក់ព័ន្ធ និងគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត សៀវភៅគ្រូ សៀវភៅសិស្ស ការប្រើប្រាស់សម្ភារឧបទេស មន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងសៀវភៅណែនាំអំពីការវាយតម្លៃសមត្ថភាពសិស្សជាដើម។ ដូចនេះដើម្បីលើកកម្ពស់គុណភាពសិស្ស និងភាពឆ្លើយតបនៃការសិក្សាក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការពិនិត្យឡើងវិញ លើកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងសម្ភារសិក្សាជាប្រចាំ និងមានលក្ខណៈជាប្រព័ន្ធ។ របាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៤-២០១៨ ទំព័រទី ៦៦ចំណុចទី ៣ស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការអប់រំបច្ចេកទេស និងកែលម្អកម្មវិធីសិក្សាសម្រាប់មធ្យមសិក្សាចំណេះទូទៅបានលើកឡើងពីបញ្ហាជាច្រើន ដែលបានជួបប្រទះក្នុងពេលអនុវត្តកម្មវិធីសិក្សានៅកម្រិតសាលារៀន ដោយលោកគ្រូ អ្នកគ្រូមិនអាច អនុវត្តកម្មវិធីសិក្សាបានពេញលេញបណ្តាលមកពីកត្តាមួយចំនួនដូចជាកត្តាគ្រោះធម្មជាតិនិងហានិភ័យផ្សេងៗ ការឈប់សម្រាកក្រៅផ្លូវការ និងការបំពេញភារកិច្ចរបស់គ្រូនៅមានកម្រិត ការប្រើវិធីសាស្ត្របែបទន្ទេញចាំមាត់នៅតែកើតមាន កង្វះខាតអ្នកសម្របសម្រួលកម្មវិធីសិក្សាកម្រិតថ្នាក់ស្រុកនៅតែជាបញ្ហាចោទនៅឡើយ។ ការយល់ដឹងទាក់ទងទៅនឹងគោលនយោបាយកម្មវិធីសិក្សានៅមានកម្រិតទាបក្នុងចំណោមគ្រូបង្រៀនទាំងអស់ និងការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សានៅមានកម្រិតនៅឡើយ។

បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនដែលកើតមាននៅពេលធ្វើការផ្លាស់ប្តូរ កម្មវិធីសិក្សាពីការផ្តោតលើខ្លឹមសារ មកជាកម្មវិធីសិក្សាដែលផ្តោតលើលទ្ធផលសិក្សារបស់សិស្ស ឬពីការរៀនដោយទន្ទេញចាំមាត់មកជាការបង្ហាញលទ្ធផលសិក្សា គឺបញ្ហាចំណេះដឹងរបស់គ្រូបង្រៀន ព្រោះគ្រូបង្រៀនមិនបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងសមស្របទៅតាមកម្មវិធីសិក្សាថ្មីនោះ

ទេ (Spady និង Marshall ឆ្នាំ១៩៩១ ទំព័រ ៦៨)។ គ្រូបង្រៀនគឺជាមនុស្សសំខាន់បំផុតក្នុងដំណើរការអនុវត្តកម្មវិធីសិក្សាដោយគាត់ត្រូវប្រើប្រាស់ចំណេះដឹង បទពិសោធន៍ និងជំនាញវិជ្ជាជីវៈឱ្យអស់ពីលទ្ធភាព។ ម្យ៉ាងទៀតពួកគាត់គឺជាមនុស្សមានទំនួលខុសត្រូវខ្ពស់ ក្នុងការណែនាំកម្មវិធី-សិក្សា ទៅដល់សិស្សនៅក្នុងថ្នាក់រៀន។ដូចនេះគ្រូបង្រៀនគឺជាចំណុចកណ្តាល សម្រាប់ រាល់ការកែលម្អកម្មវិធីសិក្សា ហើយប្រសិនបើកម្មវិធីសិក្សាទទួលបានការកែលម្អហើយនោះ គ្រូបង្រៀនត្រូវតែដឹងនិងយល់ច្បាស់ពីកម្មវិធីសិក្សាថ្មីនោះ (Carl,២០០៩)។ ទោះបីជាកម្មវិធីសិក្សាថ្មីល្អប៉ុណ្ណាក៏ដោយ ប្រសិនបើគ្រូបង្រៀនមិនបានអនុវត្តប្រកបដោយប្រសិទ្ធភាពទេនោះ ការអប់រំនឹងមិនអាចសម្រេចបាននូវវត្ថុបំណងរបស់កម្មវិធីសិក្សានោះទេ។ ដូចនេះដើម្បីអនុវត្ត កម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព លុះត្រាតែលោកគ្រូ អ្នកគ្រូដែលជាអ្នកអនុវត្តនៅក្នុងថ្នាក់រៀនផ្ទាល់បានយល់ដឹងពីវត្ថុបំណង ខ្លឹមសារមេរៀន វិធីសាស្ត្រ និងបច្ចេកទេសក្នុងការបង្រៀន និងវិធីសាស្ត្រក្នុងការវាយតម្លៃសមត្ថភាពបានល្អ ហើយត្រូវអនុវត្តនៅក្នុងដំណើរការបង្រៀន របស់គាត់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កម្មវិធីសិក្សាផងដែរ (Gurol,២០០៨)។ ទោះបីជា មានការលើកឡើងពីបញ្ហាប្រឈមផ្សេងៗ ក្នុងការអនុវត្តកម្មវិធីសិក្សានៅក្នុងប្រទេសកម្ពុជាក៏ដោយក៏នៅតែពុំទាន់ឃើញមានការសិក្សាស្រាវជ្រាវស៊ីជម្រៅពីចំណេះដឹងរបស់គ្រូលើ កម្មវិធីសិក្សានៅឡើយ។ សៀវភៅស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនរបស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការឆ្នាំ២០១៦ នៅត្រង់ចំណុចចំណេះដឹងវិជ្ជាជីវៈ១.៥ ទំព័រទី១០បានសរសេរថា លោកគ្រូ អ្នកគ្រូត្រូវមានចំណេះដឹងស្តីអំពីខ្លឹមសារកម្មវិធីសិក្សាហើយមានសមត្ថភាពពន្យល់ និងបង្រៀន ខ្លឹមសារមុខវិជ្ជាដែលមានក្នុងកម្មវិធីសិក្សានោះឱ្យបានល្អ ដោយលោកគ្រូ អ្នកគ្រូអាចគូសបញ្ជាក់ពីខ្លឹមសារសំខាន់ៗនៃកម្មវិធីសិក្សាដែលត្រូវបង្រៀនឱ្យបានច្បាស់លាស់មុននឹងបង្រៀន ដើម្បីបង្ហាញថាខ្លួនបានយល់ពីខ្លឹមសារនោះត្រឹមត្រូវល្អ(Piaget,១៩៧៧)។ បើទោះបីគ្រូបង្រៀន ត្រូវបានបណ្តុះបណ្តាលកម្មវិធីសិក្សាជាក់លាក់ណាមួយនៅមហាវិទ្យាល័យក៏ដោយ ក៏ពួកគាត់ ត្រូវដឹងនិងសម្របទៅតាមប្រព័ន្ធអប់រំថ្មីសំដៅលើការធ្វើកំណែទម្រង់ ឬផ្លាស់ប្តូរកម្មវិធីសិក្សា ព្រោះកម្មវិធីសិក្សាថ្មីនឹងមានបញ្ញត្តិថ្មី និងវិធីសាស្ត្រថ្មី។ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាមុននឹងក្លាយជា គ្រូបង្រៀន លោកគ្រូអ្នកគ្រូទទួលបានវគ្គបណ្តុះបណ្តាលនៅសាលាគរុកោសល្យ ឬវិទ្យាស្ថានជាតិអប់រំ ដោយពុំមានបញ្ចូលវគ្គសិក្សាស្តីអំពីកម្មវិធីសិក្សានោះទេ និងរាល់ការកែលម្អកម្មវិធីសិក្សា

ម្តងៗ ក្រសួងក៏មិនអាចបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់គ្រូទាំងអស់ឡើយ ដោយគ្រាន់តែផ្សព្វផ្សាយតាមរយៈខ្សែបណ្តោយប៉ុណ្ណោះ។

### ១.៣.វត្ថុបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ៗចំនួន៣គឺ៖

(១)រកឱ្យឃើញ កម្រិតចំណេះដឹងរបស់អ្នកអនុវត្តនូវក្របខណ្ឌកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំ យុវ ជន និងកីឡាឆ្នាំ២០១៦

(២)បង្ហាញពីទស្សនៈយល់ឃើញនូវការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅថ្មីដែលក្រសួងអប់រំ យុវជន និងកីឡាបានប្រកាសដាក់ឱ្យអនុវត្ត

(៣)កំណត់ចំណុចវិជ្ជមាន និងបញ្ហាប្រឈមនៅពេលអនុវត្តកម្មវិធីសិក្សាថ្មីនេះ ព្រមទាំងមធ្យោបាយក្នុងការដោះស្រាយ។

### ១.៤.សំណួរស្រាវជ្រាវ

តបតាមគោលបំណងខាងលើការស្រាវជ្រាវនេះមានគោលបំណងឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដូចខាងក្រោម៖

១) តើចំណេះដឹងរបស់អ្នកអនុវត្តក្របខណ្ឌកម្មវិធីសិក្សានាពេលបច្ចុប្បន្ននេះ មានកម្រិតណា?

២)តើគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូមានទស្សនៈយល់ឃើញយ៉ាងដូចម្តេចចំពោះ ការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅថ្មីដែលក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសដាក់ឱ្យអនុវត្ត?

៣) តើគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ គិតថាមានចំណុចវិជ្ជមាន បញ្ហាប្រឈមនិងមធ្យោបាយក្នុងការដោះស្រាយអ្វីខ្លះសម្រាប់ការអនុវត្តក្របខណ្ឌកម្មវិធីសិក្សានាពេលបច្ចុប្បន្ននេះ?

### ១.៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះនឹងផ្តល់ជូនព័ត៌មានគ្រប់ជ្រុងជ្រោយដែលទទួលបានពីអ្នកអនុវត្តកម្មវិធីសិក្សាផ្ទាល់ហើយអាចយកមកប្រើប្រាស់ដើម្បីជាជំនួយដល់ការអភិវឌ្ឍកម្មវិធីសិក្សា និងការអនុវត្តកម្មវិធីសិក្សា ប្រកបដោយប្រសិទ្ធភាព។ លទ្ធផលសំខាន់ៗនៃការស្រាវជ្រាវនេះរំពឹងថា

នឹងអាចជួយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាឱ្យបានដឹង ពីកម្រិតយល់ដឹង ពីតម្រូវការ និងបញ្ហាប្រឈមក្នុងការអនុវត្ត និងទស្សនៈ យល់ឃើញរបស់នាយក នាយករង លោកគ្រូ អ្នកគ្រូ លើកម្មវិធីសិក្សាដែលនាយកដ្ឋានបានបង្កើត និងយក មកជជែកវែកញែករកវិធីដោះស្រាយដើម្បីកែលម្អកម្មវិធីសិក្សាលើកក្រោយៗទៀតឱ្យបានល្អប្រសើរឡើង។

## ១.៦.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារធនធាន និងពេលវេលាមានកម្រិត អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាលើមុខវិជ្ជាមួយចំនួនដូចជាអក្សរសាស្ត្រខ្មែរ គណិតវិទ្យា ភាសាអង់គ្លេស រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា បរិស្ថាន ភូមិវិទ្យា ប្រវត្តិវិទ្យាសីលធម៌ពលរដ្ឋ គេហកិច្ច និងសេដ្ឋកិច្ចនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដោយផ្តោតលើក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។

## ១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជា៥ជំពូកពោលគឺជំពូកទី១៖ សេចក្តីផ្តើមដែលមានការរៀបរាប់សង្ខេបទៅលើលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទនៃការស្រាវជ្រាវ គោលបំណង ដែនកំណត់ វិសាលភាព សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។ ជំពូកទី២៖រំឭកទ្រឹស្តីដែលមានការបកស្រាយនិងពន្យល់លម្អិតទៅលើទ្រឹស្តីដែលទាក់ទងទៅនឹង ការអភិវឌ្ឍកម្មវិធីសិក្សានៅក្នុង និងក្រៅប្រទេសកម្ពុជា គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត ស្តង់ដាកម្មវិធីសិក្សា និងករណីសិក្សាផ្សេងៗដែលជាប់ពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សា។ ជំពូកទី៣៖វិធីសាស្ត្រស្រាវជ្រាវដែលបានលើកឡើងអំពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការស្រាវជ្រាវ និងការវិភាគ។ ជំពូកទី៤៖លទ្ធផលស្រាវជ្រាវនិងមានការបកស្រាយនិងពិភាក្សានូវរាល់ចំណុចដែលបានរកឃើញដោយលើកអំណះអំណាងលទ្ធផលស្រាវជ្រាវរបស់អ្នកសិក្សាមុនៗ មកធ្វើជាមូលដ្ឋានក្នុងការពិភាក្សានេះ។ ជំពូកទី៥៖ សន្និដ្ឋាន និងសំណូមពរ។ ជំពូកនេះបានសង្ខេបនូវគ្រប់ចំណុចទាំងអស់ដែលបានរកឃើញនិងបានពិភាក្សាដើម្បីផ្តល់ជាយោបល់ ឬលើកជាសំណូមពរសម្រាប់ធ្វើការកែលម្អកម្មវិធីសិក្សានេះឱ្យកាន់តែល្អប្រសើរ។

# ជំពូកទី២
# រំឭកទ្រឹស្តី

# ជំពូកទី២

# រំឭកទ្រឹស្តី

## ២.១.និយមន័យពាក្យគន្លឹះ និងទ្រឹស្តីពាក់ព័ន្ធ

### ២.១.១ និយមន័យ: កម្មវិធីសិក្សា( CURRICULUM )

កម្មវិធីសិក្សាជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗជាច្រើន នៃការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំហើយត្រូវបានគេឱ្យនិយមន័យខុសគ្នាៗ។ អ្នកខ្លះឱ្យនិយមន័យថាកម្មវិធីសិក្សាគឺជាបណ្តុំនៃមុខវិជ្ជាទាំងឡាយណាដែលដាក់ឱ្យក្មេងសិក្សា ដោយគិតថាមានសារសំខាន់សម្រាប់ជីវភាពរស់នៅ ឬសម័យកាលរបស់ពួកគេ។ រីឯអ្នកខ្លះទៀតបានឱ្យនិយមន័យកម្មវិធីសិក្សាថា ជាមុខវិជ្ជា "អចិន្ត្រៃយ៍" ដូចជាវេយ្យាករណ៍ អំណានវោហាសាស្ត្រ តក្កវិជ្ជា គណិតវិទ្យា និងជាសៀវភៅដ៏អស្ចារ្យរបស់លោកខាងលិច ដែលបានបញ្ចូលចំណេះដឹងសំខាន់ៗហើយល្អបំផុត។ កម្មវិធីសិក្សាជាមុខវិជ្ជាដែលមានប្រយោជន៍បំផុតសម្រាប់ការរស់នៅក្នុងសង្គមសម័យបច្ចុប្បន្ន (Sieng,2007)។ Bonser នៅឆ្នាំ1920 បានឱ្យនិយមន័យថាកម្មវិធីសិក្សាគឺជាបទពិសោធន៍ទាំងឡាយ ដែលអ្នកសិក្សារំពឹងទុកថានឹងទទួលបាននៅក្នុងសាលារៀន។Caswell and Campbell នៅឆ្នាំ1935បានផ្តល់និយមន័យថាកម្មវិធីសិក្សា គឺជាការផ្សំឡើងនូវបទពិសោធន៍ទាំងឡាយដែលអ្នកសិក្សាទទួលបានក្រោមការបង្ហាត់បង្រៀនរបស់គ្រូ។ ចំណែកឯ Smith, Stanley, and Shores នៅឆ្នាំ1957 បានកំណត់និយមន័យកម្មវិធីសិក្សាថាគឺជាការតម្រៀបបទពិសោធរបស់សិស្សឬនិស្សិតតាមលំដាប់លំដោយដើម្បីអប់រំពួកគេឱ្យចេះពីរបៀបគិត របៀបដោះស្រាយ និងរបៀបធ្វើសកម្មភាពនានា ។ កម្មវិធីសិក្សាគឺជាផែនការនៃការសិក្សាទាំងអស់ ដែលបានគ្រោងទុកសម្រាប់សាលារៀនប្រកបដោយ ការទទួលខុសត្រូវខ្ពស់។ វាគឺជាលទ្ធផលសរុបនៃបទពិសោធន៍ក្នុងការសិក្សា ដែលបានផ្តល់ដល់សិស្ស ដើម្បីឱ្យពួកគេអាចទទួលបាននូវបំណិនទូទៅ និងជំនាញទៅតាមតំបន់ ឬបរិបទដែលអ្នកសិក្សាត្រូវរៀនសូត្រ។ កម្មវិធីសិក្សាគឺជាអ្វីៗដែលសិស្សទទួលបានពីការងារដោយកុំព្យូទ័ររបស់ខ្លួន និងពីបណ្តាញនានា ដូចជាអ៊ិនធឺណែត។ វាជាចំណោទបញ្ហារបស់អ្នកជំនាញ និងជាការស្វែងយល់ពីទិដ្ឋភាពស្មុគស្មាញនៃស្ថានភាពរស់នៅ

របស់មនុស្ស។ តាមសទ្ទានុក្រមក្នុងសៀវភៅក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ឆ្នាំ២០១៦ ត្រង់ទំព័រទី២៦ បានផ្តល់និយមន័យកម្មវិធីសិក្សា គឺជាក្របខណ្ឌអនុវត្តចំណេះដឹង និងបទពិសោធដែលមានដើម្បីអភិវឌ្ឍដល់សិស្សានុសិស្សឱ្យមានចំណេះដឹង ជំនាញ និងលក្ខណៈសម្បត្តិដែលបានកំណត់ទុក។ កម្មវិធីសិក្សាប្រៀបដូចជាផែនទីកំណត់ទិសដៅនៃការអភិវឌ្ឍដល់សិស្សានុសិស្សឱ្យឈានដល់មាត្រដ្ឋាន នៃការរៀនសូត្រដែលជាគោលដៅ និងមានការវាយតម្លៃការស្វែងយល់ ដើម្បីឱ្យជ្រួតជ្រាប ពីការវិវឌ្ឍទៅមុខនៃសិស្សានុសិស្សម្នាក់ៗក្នុងការអភិវឌ្ឍសមត្ថភាពដើម្បីឈានដល់ស្តង់ដាដែលបានកំណត់ទុក។

ផ្អែកតាមនិយមន័យដូចដែលបានរៀបរាប់ខាងលើ គេអាចញែកកម្មវិធីសិក្សាជាពីរប្រភេទទៅតាមនិន្នាការរបស់ប្រទេសនីមួយៗ (១) កម្មវិធីសិក្សាដែលផ្តោតតែទៅលើជំនាញ ឬឯកទេសដែលអ្នកសរសេរកម្មវិធីចង់បានពោលគឺ ជាការសម្រួចឱ្យច្បាស់តែទៅលើមុខវិជ្ជានីមួយៗដោយមិនគិតពីអារម្មណ៍ ពីមូលដ្ឋានគ្រឹះឬពីចំណាប់ចំណូលចិត្តរបស់អ្នកសិក្សាឡើយ និងបង្រៀនតែអ្វីៗដែលមានស្រាប់ ហើយ លើកទឹកចិត្ត ចំពោះតែអ្នករៀនពូកែ។ សិស្សជាអ្នកទទួល រីឯគ្រូជាអ្នកបញ្ចុក បង្រៀនដោយប្រើគោលវិធី គ្រូមជ្ឈមណ្ឌល។និង(២) កម្មវិធីសិក្សាដែលផ្តោតតែទៅលើបទពិសោធន៍ ឬចំណាប់ចំណូលចិត្តរបស់អ្នកសិក្សាៈជាកម្មវិធីសិក្សាដែលមានលក្ខណៈច្នៃប្រឌិតនិងបត់បែនទៅតាមកាលៈទេសៈ យកអ្នកសិក្សាជាធំ ទ្រឹស្តីផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ សិស្សជាអ្នកពិភាក្សា និងដោះស្រាយបញ្ហាដោយខ្លួនឯង ដោយគ្រូបង្រៀនប្រើគោលវិធីសិស្សមជ្ឈមណ្ឌល (វិទ្យាស្ថានជាតិអប់រំ,២០១៩)។

## ២.១.២.គោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា/ក្របខណ្ឌកម្មវិធីសិក្សា

គោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សាគឺជាឧបករណ៍សម្រាប់រៀបចំឬគ្រប់គ្រងខ្លឹមសារកម្មវិធីសិក្សា (គោលនយោបាយអប់រំ និតិវិធី បញ្ញត្តិ។ល។) ដែលមានលក្ខណៈជាប្រព័ន្ធ។ មុននឹងសរសេរកម្មវិធីសិក្សាលម្អិត ស្តង់ដាកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ត្រូវសរសេរគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាឬក្របខណ្ឌកម្មវិធីសិក្សាជាមុន។ នៅក្នុងក្របខណ្ឌកម្មវិធីសិក្សាត្រូវមានចែងនូវចក្ខុវិស័យ គោលបំណង ចំនួនសប្តាហ៍ដែលត្រូវអនុវត្តក្នុងមួយឆ្នាំសិក្សារបាយមុខវិជ្ជាក្នុងកម្រិតថ្នាក់នីមួយៗ ក្នុងភូមិសិក្សានីមួយៗ របាយម៉ោងក្នុងមុខវិជ្ជានីមួយៗនិងតាមកម្រិតថ្នាក់នីមួយៗ។ គោលនយោបាយអភិវឌ្ឍកម្មវិធី សិក្សាឬក្របខណ្ឌកម្មវិធីសិក្សាត្រូវគ្របដណ្តប់លើបញ្ហាទាំងឡាយដែលមានឥទ្ធិពលលើការអភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សាដូចជាកម្មវិធីសិក្សា ត្រូវធ្វើឡើងឱ្យស្របតាមតម្រូវការរបស់ប្រទេសជាតិនាពេលបច្ចុប្បន្ន និងពេល

អនាគត វិធីសាស្រ្តបង្រៀន ការជ្រើសរើសគ្រូបង្រៀន វង្វាយតម្លៃ និងការប្រឡងថ្នាក់ជាតិ និងសូម្បីតែទំហំថ្នាក់រៀនផងដែរ។

ក្របខណ្ឌកម្មវិធីសិក្សាឬគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា ត្រូវបានរៀបចំឡើងដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពអប់រំតាមបណ្ដាប្រទេសក្នុងសហគមន៍អាស៊ាន ដែលធានាឱ្យអ្នកសិក្សាមាន សមត្ថភាពឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន តម្រូវការទីផ្សារការងាររបស់ប្រទេសក្នុងតំបន់ និងពិភព លោក។

ក្របខណ្ឌកម្មវិធីសិក្សាឬគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា ត្រូវបានរៀបចំឡើងដោយឈរ លើមូលដ្ឋានទស្សនៈ និងចក្ខុវិស័យថ្មី ស្របតាមនិន្នាការអប់រំសាកល រដ្ឋធម្មនុញ្ញ ច្បាប់អប់រំ ផែនការជាតិ អប់រំសម្រាប់ទាំងអស់គ្នា ផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៤-២០១៨ កម្មវិធីសិក្សាពីឆ្នាំ១៩៨០ ដល់ឆ្នាំ២០០៩ និងក៏ជាឯកសារគន្លឹះសម្រាប់អភិវឌ្ឍន៍ឯកសារសំខាន់ៗដោយអ្នកពាក់ព័ន្ធ ដូចជាសៀវភៅសិក្សា សម្ភារៈឧបទេសដែលបម្រើឱ្យការបង្រៀននិងរៀន សេចក្តីណែនាំស្តីពីវិធីសាស្រ្តបង្រៀន និង សូចនាករនៃលទ្ធផលសិក្សារំពឹងទុកសម្រាប់វាយតម្លៃសមត្ថភាពសិស្សទៅតាមកម្រិតថ្នាក់ និងទៅតាម មុខវិជ្ជាដែលមានលក្ខណៈសត្យានុម័ត អាចប្រមើលមើលដឹងជាមុននិងមានតម្លាភាព។

### ២.១.៣.កម្មវិធីសិក្សាគោល( CORE CURRICULUM )

តាមវចនានុក្រម Collins Cobuild កម្មវិធីសិក្សាគោលគឺជាបណ្ដុំមុខវិជ្ជាដែលសិស្សនៅក្នុងក្រុមអាយុណាមួយត្រូវតែរៀន។ តាមសទ្ទានុក្រមកម្មវិធីសិក្សារបស់UNESCO បោះពុម្ពនៅឆ្នាំ២០១៣ បាន ផ្តល់និយមន័យថាកម្មវិធីសិក្សាគោល (Core Curriculum) គឺជាបណ្តុំនៃចំណេះដឹង ជំនាញ និងឥរិយាបថដែលរំពឹងថាសិស្សទាំងអស់ត្រូវរៀន។ ជាទូទៅវាពាក់ព័ន្ធទៅនឹងបណ្តុំមុខវិជ្ជា និងផ្នែកនៃការសិក្សាសម្រាប់សិស្សទូទៅ ដូចជាភាសា គណិតវិទ្យា អប់រំកាយ និងកីឡា វិទ្យាសាស្រ្ត និងសិក្សាសង្គមជាដើម។

នៅក្នុងឆ្នាំ១៩៩៦ កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយភូមិ ត្រូវបានបង្កើតឡើងដោយវិទ្យាស្ថានស្រាវជ្រាវគរុកោសល្យ បច្ចុប្បន្នជានាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា ដែលក្នុងនោះមានការរៀបរាប់អំពីគោលដៅអប់រំជាតិ គោលដៅអប់រំចំណេះទូទៅ គោលបំណង កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ របាយម៉ោងបង្រៀនលើមុខវិជ្ជានីមួយៗតាមកម្រិតថ្នាក់ សមាសភាគនៃកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិដែលមាន

ដូចជាបណ្តុំមុខវិជ្ជា និងមុខវិជ្ជារង។ នៅក្នុងមុខវិជ្ជានីមួយៗបានរៀបរាប់អំពីគោលបំណងនៃកម្មវិធីសិក្សារបស់មុខវិជ្ជានីមួយៗផងដែរ។

### **២.១.៤.ស្តង់ដាកម្មវិធីសិក្សា**( CURRICULUM STANDART )

តាមវចនានុក្រម Collins Cobuild ទំព័រទី១៤២១បានផ្តល់និយមន័យជាច្រើនដូចជាស្តង់ដាកម្មវិធីសិក្សាគឺជាកម្រិតគុណភាពឬសមិទ្ធិផល ជាពិសេសកម្រិតមួយដែលគេគិតថាអាចទទួលយកបាន។

ស្តង់ដាកម្មវិធីសិក្សាគឺជាឯកសារដែលគេប្រើប្រាស់សម្រាប់វាស់ស្ទង់លទ្ធផលសិក្សារបស់សិស្សជាប្រចាំដើម្បីធ្វើយ៉ាងណាជំរុញការសិក្សារបស់សិស្សឱ្យសម្រេចបានលទ្ធផលសិក្សាយ៉ាងហោចណាស់ ត្រឹម កម្រិតស្តង់ដាមួយដែលបានកំណត់ក្នុង១ឆ្នាំសិក្សា។ ស្តង់ដា កម្មវិធីសិក្សាពិតជាមានតម្លៃសម្រាប់សិស្សា នុសិស្ស គ្រូបង្រៀន នាយកសាលា មន្ត្រីអប់រំ មាតាបិតា ដៃគូអភិវឌ្ឍ និងអ្នកចាប់អារម្មណ៍នានាក្នុងការ សហការលើកកម្ពស់ការបង្រៀននិងរៀនហើយវាជួយបង្កើនការយល់ដឹងរបស់គ្រូ ដើម្បីរៀបចំការបង្រៀន និងរៀនឱ្យចំទិសដៅ សំដៅធានាថាសិស្សទាំងអស់ទទួលបាននូវចំណេះដឹង និងបំណិនសំខាន់ៗតាម រយៈការសិក្សានៅសាលារៀន ព្រមទាំងជួយគ្រូក្នុងការធ្វើតេស្ត និងវាយតម្លៃដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាព និងការតាក់តែងវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១២)។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពអប់រំ និងឱ្យស្របតាមគោលនយោបាយកម្មវិធីសិក្សាចំណេះទូទៅ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍន៍ និងផ្សព្វផ្សាយនូវស្តង់ដាកម្មវិធីសិក្សាថ្នាក់ទី៣ ទី៦ ទី៩ និង ទី១២ ដោយបានកំណត់ និងបង្ហាញលទ្ធផលសិក្សាសំខាន់ៗក្នុងកម្រិតបទដ្ឋានអប្បបរមា ដែលតម្រូវឱ្យ សិស្សទាំងអស់ត្រូវចេះ និងអាចធ្វើបានបន្ទាប់ពីបញ្ចប់ការសិក្សានៅដំណាក់កាលសិក្សានីមួយៗ។ ស្តង់ដា កម្មវិធីសិក្សាថ្នាក់ទី១២ បោះពុម្ពនៅក្នុងឆ្នាំ២០១២ដែលមាន២បណ្តុំមុខវិជ្ជាគឺ៖ មុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម គ្រប់មុខវិជ្ជាដែលមានដូចជាអក្សរសាស្ត្រខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា ភូមិ វិទ្យា ផែនដីវិទ្យានិងបរិស្ថាន សេដ្ឋកិច្ចវិទ្យា និងសីលធម៌-ពលរដ្ឋវិជ្ជា។

### **២.១.៥.កម្មវិធីសិក្សាលម្អិត**( SYLLABUS )

កម្មវិធីសិក្សាលម្អិតជាគោលបន្ទាត់សម្រាប់ការរៀបចំសៀវភៅសិក្សា ការរៀបចំតេស្ត ការផលិត សម្ភារឧបទ្ទេស និងវិធីសាស្ត្របង្រៀន។ ឯកសារនេះមានលទ្ធផលសិក្សារំពឹងទុក

ខ្លឹមសារសំខាន់ៗនៃកម្មវិធីសិក្សាតាមមេរៀននីមួយៗ និងចំនួនម៉ោងសិក្សាតាមមេរៀន និងតាមកម្រិតថ្នាក់នីមួយៗ។

ក្រសួងអប់រំ យុវជន និងកីឡាបានតាក់តែងកម្មវិធីសិក្សាលម្អិតមធ្យមសិក្សាទុតិយភូមិ ដោយយោងទៅតាមគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា២០០៥-២០០៩ ដើម្បីធានា សម្រេចឱ្យបាននូវយុទ្ធសាស្ត្រដូចជា (១) ធ្វើទំនើបកម្ម និងកែលម្អគុណភាពអប់រំតាមរយៈការកែទម្រង់ដែលមានប្រសិទ្ធភាពដើម្បី ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃសង្គមសេដ្ឋកិច្ចរបស់ប្រទេស (២) ផ្សារភ្ជាប់ការអប់រំ ការងារបណ្តុះបណ្តាលទៅនឹងទីផ្សារពលកម្ម និងសង្គមក្នុងគោលបំណងលើកកម្ពស់សមត្ថភាពយុវវ័យ ឱ្យយក ចំណេះដឹង និងបំណិនរបស់ខ្លួនទៅប្រើប្រាស់ក្នុងសង្គម ដើម្បីបុព្វហេតុការពារនិងកសាងមាតុភូមិជាទីស្នេហារបស់ខ្លួន (៣) ស្តារ និងអភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡា។

កម្មវិធីសិក្សាលម្អិត គឺជាឯកសារគោលសម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោល។ នៅក្នុងកម្មវិធីសិក្សាលម្អិត មានសរសេរលទ្ធផលសិក្សាតាមមេរៀន តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់ ឧទាហរណ៍ដូចជា លទ្ធផលសិក្សាមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១០ ទី១១ ទី១២ និងខ្លឹមសារមេរៀនភាសាខ្មែរថ្នាក់ទី១០ ទី១១ និងទី១២។

### ២.១.៦.ខ្លឹមសារកម្មវិធីសិក្សា( CURRICULUM CONTENT )

ខ្លឹមសារកម្មវិធីសិក្សា (Curriculum Content) គឺជាប្រធានបទ គំនិត ជំនឿ ឥរិយាបថ បញ្ញត្តិ និងរឿងរ៉ាវពិតជាក់ស្តែងផ្សេងៗដែលបានចាត់ថ្នាក់ចូលទៅក្នុងក្រុមចំណេះដឹង ជំនាញ តម្លៃនិងឥរិយាបថ ហើយរំពឹងថាសិស្សបានរៀននូវក្រុមទាំងនោះ និងត្រូវបានយកមកបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការបង្រៀននិងរៀន នេះបើតាមសទ្ទានុក្រមកម្មវិធីសិក្សារបស់អង្គការ UNESCO បោះពុម្ពឆ្នាំ២០១៣ ។

### ២.១.៧.វង្វាយតម្លៃ

វង្វាយតម្លៃគឺជាដំណើរការវាស់វែងឬវាយតម្លៃលើការសម្រេចបាន ឬភាពរីកចម្រើនរបស់អ្នកសិក្សា ។ វង្វាយតម្លៃសមត្ថភាពនៅក្នុងថ្នាក់រៀន (Formative Assessment) គឺជាការវាស់វែងពីភាពរីកចម្រើន និងលទ្ធផលសម្រេចបានរបស់សិស្សដែលមានគោលបំណងគាំទ្រ និងជួយពង្រឹងការសិក្សាស្របទៅតាមដំណើរការអប់រំដើម្បីឱ្យដល់តម្រូវការដែលចង់បាន។ វង្វាយតម្លៃថ្នាក់ជាតិ (Summative Assessment) គឺជាការវាស់វែងលទ្ធផលសម្រេចបានរបស់ អ្នកសិក្សាក្នុងគោលបំណង ដើម្បីផ្តល់ព័ត៌មានអំពីថាតើអ្នកសិក្សាសម្រេចបានកម្រិតណាមួយ នៅក្នុង

ពេលវេលាជាក់លាក់ ដូចជាស្តង់ដាតេស្ត ឬការប្រឡងថ្នាក់ជាតិជាដើម។ រង្វាយតម្លៃដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការអប់រំផ្អែកលើលទ្ធផល។ វាបានជួយកំណត់ពីភាពរីកចម្រើននៃការសិក្សារបស់សិស្សដែលជាប្រភពព័ត៌មានមួយយ៉ាងសំខាន់សម្រាប់ការធ្វើឱ្យប្រសើរឡើងថែមទៀត។ការធ្វើតេស្តដើម្បីវាស់ស្ទង់សមត្ថភាពសិស្សមានគោលបំណងស្វែងយល់និងធ្វើឱ្យប្រសើរឡើងនូវការសិក្សារបស់សិស្ស។ វាជួយឱ្យការរំពឹងទុករបស់ យើងដែលបានកំណត់នៅក្នុងលក្ខខណ្ឌស្តង់ដា នៃគុណភាពសិក្សាដោយប្រមូលផ្តុំជាប្រព័ន្ធ វិភាគ និងបកស្រាយទុកជាភស្តុតាងដើម្បីកំណត់ពីការបំពេញភារកិច្ចរបស់យើងបានល្អកម្រិតណា តើវាដូចទៅនឹងអ្វីដែលយើងរំពឹងទុកនិងមានស្តង់ដាដែរឬទេ និងអាចប្រើប្រាស់លទ្ធផលនេះទុកជាឯកសារព័ត៌មានពន្យល់ និងកែលម្អការបំពេញភារកិច្ចដែរឬទេ (Angelo, ១៩៩៥)។

### ២.១.៨.ការអនុវត្តកម្មវិធីសិក្សា( CURRICULUM IMPLEMENTATION )

ការអនុវត្តសំដៅលើការយកទ្រឹស្តីទៅអនុវត្តជាក់ស្តែង។ ការអនុវត្តកម្មវិធីសិក្សាត្រូវបានកំណត់ ន័យដោយអ្នកប្រាជ្ញជាច្រើនដូចជា Mezieobi (១៩៩៣) បានសំយោគពាក្យអនុវត្តកម្មវិធីសិក្សា គឺជា ដំណើរការនៃការអនុវត្តផែនការដែលក្នុងនោះ មានការព្រមព្រៀងគ្នាលើការសម្រេចចិត្ត សំណើ និងនយោបាយឱ្យមានប្រសិទ្ធភាព។ (Okebukula,២០០៤) បានពន្យល់ថាការអនុវត្តកម្មវិធីសិក្សាគឺជាការបកប្រែ គោលបំណងរបស់កម្មវិធីសិក្សា ទៅជាការអនុវត្តជាក់ស្តែង។ Garba,២០០៤ យល់ថាការអនុវត្តកម្មវិធី សិក្សាគឺជាដំណើរការដែលដាក់កម្មវិធីសិក្សាឱ្យទៅជាការអនុវត្ត ដើម្បីសម្រេចបានគោលបំណងកម្មវិធីសិក្សាដែលបាន គ្រោងទុក។ (Ivowi,២០០៤) ការអនុវត្តកម្មវិធីសិក្សាគឺជាការបកប្រែទ្រឹស្តីទៅជាការអនុវត្តឬជាការយកសំណើទៅជាសកម្មភាព។ (Afangideh,២០០៩) បញ្ញត្តិនៃការអនុវត្តកម្មវិធីសិក្សាគឺជាការទាញអ្នកសិក្សាឱ្យចូលទៅក្នុងឱកាសសិក្សាដែលបានគ្រោងទុក។ទាំងអស់នេះ គឺជាគោលនយោបាយរបស់រដ្ឋាភិបាលដែលបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សា។

សរុបមក ការអនុវត្តកម្មវិធីសិក្សា គឺជាសកម្មភាពទាំងឡាយនៅក្នុងថ្នាក់រៀន ឬនៅក្រៅថ្នាក់រៀនដោយមានការចូលរួម និងកិច្ចខិតខំប្រឹងប្រែងពីសំណាក់គ្រូបង្រៀន អ្នកសិក្សា រដ្ឋបាលសាលារៀន អាណាព្យាបាល ដែលមានបំណងលើកកម្ពស់ការសិក្សា។

## ២.២.ឯកសារផ្សេងៗទាក់ទងនឹងកម្មវិធីសិក្សា

ឯកសារគោលនយោបាយថ្មីមួយសម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សាអប់រំមូលដ្ឋាន(ថ្នាក់ទី១-៩) និងកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១០-១២)នៅប្រទេសកម្ពុជា ក្នុងបរិបទដែល

មានក្នុងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា២០០៣-២០១៥។ ឯកសារគោលនយោបាយនេះ បរិយាយពីគោលបំណង និងរចនាសម្ព័ន្ធនៃកម្មវិធីសិក្សា រួមទាំងម៉ោងបង្រៀន។ ខ្លឹមសារ លម្អិតនៃកម្មវិធីសិក្សា នឹងមានពណ៌នាក្នុងឯកសារថ្មី កម្មវិធីសិក្សាជាតិ។ រចនាសម្ព័ន្ធនៃកម្មវិធីសិក្សាក្នុងឯកសារនេះមានបំណងធ្វើឱ្យសម្រេចនូវរាល់ចំណុចគន្លឹះជាអាទិភាពទាំងឡាយរបស់ក្រសួង អប់រំ យុវជន និងកីឡា ដែលបានកំណត់ក្នុងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា២០០៣-២០១៥ ដូចជា៖

- សមធម៌ក្នុងការទទួលការអប់រំនៅកម្រិតអប់រំមូលដ្ឋាន
- ការផ្តល់ការអប់រំប្រកបដោយគុណភាពខ្ពស់នៅមធ្យមសិក្សាទុតិយភូមិ
- គោលនយោបាយហិរញ្ញវត្ថុជួយដល់សិស្សក្រីក្រ
- ការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព
- ការបង្កើនការទទួលខុសត្រូវក្នុងការអភិវឌ្ឍស្តង់ដា។

ម៉្យាងទៀត គោលនយោបាយនេះ បានរៀបចំឡើងនូវចំណុចមួយចំនួនក្នុងកម្មវិធីសិក្សាគោលឆ្នាំ ១៩៩៦ ដូចជាការសម្រួលរបាយម៉ោងសិក្សា ការផ្តល់ការអប់រំបំណិនជីវិតក្នុងកម្មវិធីបំណិនជីវិតមូលដ្ឋាន ការផ្តល់សិទ្ធិឱ្យសិស្សជ្រើសមុខវិជ្ជាសិក្សានៅថ្នាក់ទី១១ និងទី១២ ដោយបន្ថែមម៉ោងសិក្សាសម្រាប់មុខវិជ្ជានីមួយៗ និងបន្ថយមុខវិជ្ជាដែលសិស្សត្រូវរៀន ដើម្បីឱ្យសិស្សមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាមុខវិជ្ជាដែលគេជ្រើសរើស។ គោលនយោបាយនេះបានរៀបចំឡើងសម្រាប់រយៈពេល៥ឆ្នាំ០០៥-២០០៩ហើយត្រូវពិនិត្យឡើងវិញ មុនដំណាច់ឆ្នាំ ២០០៩ ដើម្បីអភិវឌ្ឍន៍គោលនយោបាយថ្មី សម្រាប់រយៈពេល ៥ឆ្នាំ២០១០-២០១៤ ឱ្យស្របទៅតាមស្ថានភាពអប់រំ និងការវិវឌ្ឍជាក់ស្តែងរបស់ប្រទេសជាតិ។ ក្រសួងអប់រំ យុវជន និងកីឡាមានជំនឿថាគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សានេះ គឺជាឯកសារដ៏មានសារៈសំខាន់ សម្រាប់លោកគ្រូ អ្នកគ្រូ នាយកគ្រឹះស្ថានសិក្សា មន្ត្រីអប់រំ មាតា បិតា សិស្ស អ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវអប់រំ និងអ្នកចាប់អារម្មណ៍នានា។ ក្រសួង សង្ឃឹមថាគ្រប់ស្ថាប័នអប់រំសហគមន៍មូលដ្ឋាន អង្គការជាតិ អន្តរជាតិ និងអ្នកចាប់អារម្មណ៍ទាំងអស់នឹងសហការគ្នាបន្តជួយគាំទ្រការអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យ។ ខាងក្រោមនេះគឺជាដំណាក់កាលនិងគោលដៅនៃការអភិវឌ្ឍកម្មវិធីសិក្សានៅកម្ពុជា៖

**ឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៦**: កម្មវិធីសិក្សាអប់រំមានគោលដៅគឺបណ្តុះបណ្តាលតំណយុវជនឱ្យក្លាយជាពលរដ្ឋល្អ ពលករល្អ យុទ្ធជនល្អ ដែលជាប្រភពអនាគតកម្មាភិបាលរបស់ប្រទេស

ជាតិ។ ក្នុងដំណាក់កាលនោះប្រព័ន្ធអប់រំមានរយៈពេល១០ឆ្នាំ (៤+៣+៣) ហើយទម្រង់កម្មវិធីសិក្សាយកខ្លឹមសារជាគោល (content base)។ នៅខណៈពេលនោះ ទាំងកម្មវិធីសិក្សា សៀវភៅសិក្សាគោល (សៀវភៅខ្លះបោះពុម្ពនៅប្រទេសវៀតណាម និងសហភាពសូវៀត) រីឯភាសាបរទេសគឺភាសាវៀតណាម និងភាសារុស្ស៊ី។

**១៩៨៧ ដល់ឆ្នាំ១៩៩៦**: គោលដៅអប់រំជាតិគឺៈបណ្តុះយុវជនឱ្យមានចំណេះដឹងមូលដ្ឋានខាងវិទ្យាសាស្ត្រពិត វិទ្យាសាស្ត្រសង្គម និងពហុបច្ចេកទេស ដើម្បីក្លាយជាពលរដ្ឋល្អ ពលករល្អ និងយុទ្ធជនល្អ ហើយប្រព័ន្ធអប់រំមានរយៈពេល១១ឆ្នាំ (៥+៣+៣)។ ចំនួនម៉ោងសិក្សាក្នុង១ឆ្នាំសិក្សាគឺពី៧៩២ ទៅ ៨៥៨ម៉ោង។ នៅបឋមសិក្សាចំនួនម៉ោងសិក្សា១ឆ្នាំសិក្សាគឺពី៧៩២ ទៅ ៨៥៨ម៉ោង ភាសាបរទេសគ្មាន ។ នៅមធ្យមសិក្សាកម្រិត១ ចំនួនម៉ោងសិក្សា១ឆ្នាំសិក្សាគឺពី៩៣៦ទៅ១០៨០ម៉ោង ភាសាបរទេសគឺ ភាសាវៀតណាម និង រុស្ស៊ី (១៩៨៧ ដល់១៩៩០ ) រីឯនៅមធ្យមសិក្សាកម្រិត២ (ថ្នាក់ទី៩ ដល់ទី១១) ចំនួនម៉ោងសិក្សាក្នុង១ឆ្នាំសិក្សាគឺពី៩៣៦ទៅ១០៨០ម៉ោង ភាសាបរទេសគឺភាសាវៀតណាម និងភាសារុស្ស៊ី (១៩៨៧ ដល់១៩៩០) និង (១៩៩១ ដល់១៩៩៦ បើកទូលាយ បារាំង អង់គ្លេស...) ។ រដ្ឋជាអ្នកទទួលខុសត្រូវទាំងស្រុងលើកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ ) តែសៀវភៅភាសាវៀតណាម និងភាសារុស្ស៊ី បោះពុម្ពនៅក្រៅប្រទេស ។

**ឆ្នាំ១៩៩៧ ដល់ ឆ្នាំ២០០៤** មានការកែទម្រង់ធំមួយដោយប្តូរប្រព័ន្ធអប់រំ ទម្រង់កម្មវិធីសិក្សា សៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀន (យើងប្រើតាមប្រព័ន្ធអន្តរជាតិ) ។ ហើយគោលដៅអប់រំជាតិក្នុងពេលនោះគឺបណ្តុះបណ្តាលសិស្សានុសិស្សឱ្យក្លាយជាមនុស្សពេញ-លេញ (ពលរដ្ឋល្អ ពលរដ្ឋថ្លៃថ្នូរ ពលករជំនាញ) ដែលជាប្រភពធនធានអភិវឌ្ឍន៍ជាតិ។ នៅបឋមសិក្សា៦ឆ្នាំ ចំនួនម៉ោងសិក្សាក្នុង១ឆ្នាំសិក្សាគឺ១២៦០ម៉ោង មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ ចំនួនម៉ោងសិក្សាក្នុង១ឆ្នាំសិក្សាៈ១២៦០ម៉ោង មធ្យមសិក្សាទុតិយភូមិ ៣ឆ្នាំ ចំនួនម៉ោងសិក្សាក្នុង១ឆ្នាំសិក្សាគឺ១២៦០ម៉ោង។ ភាសាបរទេសគឺសិក្សាភាសាបារាំង និងអង់គ្លេស។

**ឆ្នាំ២០០៥ ដល់ ឆ្នាំ២០១៦** : ចែកជា ៣ ដំណាក់ ៖ (១) ២០០៥ ដល់ ២០១០ (២) ២០១១ ដល់២០១៥ និង(៣) ២០១៦។ ក្នុងពេលនេះមានការកែលម្អថ្មីបន្ថែមទៀតនូវទម្រង់កម្មវិធីសិក្សា សៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀន គោលវិធីសិស្សមជ្ឈមណ្ឌល។ គោលដៅអប់រំជាតិ

គឺបណ្តុះបណ្តាលសិស្សានុសិស្សឱ្យក្លាយជាមនុស្សពេញលេញ (ពលរដ្ឋល្អ ពលរដ្ឋថ្លៃថ្នូរ ពលករជំនាញ) ដែលជាប្រភពធនធានអភិវឌ្ឍន៍ជាតិ។ ខណៈពេលនោះ ប្រព័ន្ធអប់រំគឺ១២ឆ្នាំ សម្រាប់បឋមសិក្សា៦ឆ្នាំ មធ្យមសិក្សាបឋមភូមិ៣ឆ្នាំ មធ្យមសិក្សាទុតិយភូមិ៣ឆ្នាំ (៦+៣+៣) រីឯទម្រង់ កម្មវិធីសិក្សា យកលទ្ធផលសិក្សាជាគោល (learning outcome best)។

**ឆ្នាំ២០០៥ ដល់ឆ្នាំ២០១០**: បឋមសិក្សា ពីថ្នាក់ទី១ ដល់ទី៣គឺ៣៨សប្តាហ៍ ក្នុង១ឆ្នាំសិក្សា ហើយចំនួនម៉ោងសិក្សាក្នុង១ឆ្នាំសិក្សាគឺពី១០២៦ម៉ោង ទៅ១១៤០ម៉ោង និងចំនួនមុខវិជ្ជាមាន៥មុខវិជ្ជា ។ រីឯ(ថ្នាក់ទី៤ ដល់ទី៦) ចំនួនសប្តាហ៍ និងចំនួនម៉ោងដូចគ្នា តែចំនួនមុខវិជ្ជាមាន៦មុខវិជ្ជា។ សម្រាប់ មធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧ ដល់ទី៩) គឺ៣៨សប្តាហ៍ ក្នុង១ឆ្នាំសិក្សា និង១២១៦ម៉ោងដល់១៣៣០ម៉ោងក្នុង១ឆ្នាំសិក្សា ហើយចំនួនម៉ោងសរុបប្រចាំសប្តាហ៍ គឺ៣២ម៉ោងទៅ៣៥ម៉ោង និងមាន៧មុខវិជ្ជា។ សម្រាប់មធ្យមសិក្សាទុតិយភូមិ(ថ្នាក់ទី១០ ដល់ទី១២) ថ្នាក់ទី១០គឺរៀន៣២ម៉ោងទៅ៣៥ម៉ោង ក្នុងមួយសប្តាហ៍ ហើយចំនួនសប្តាហ៍គឺ៣៨សប្តាហ៍ ក្នុង១ឆ្នាំសិក្សា ចំនួនម៉ោងសរុបគឺ១២១៦ម៉ោង ដល់ ១៣៣០ម៉ោងក្នុងមួយឆ្នាំសិក្សា។ ចំនួនមុខវិជ្ជាមានៈ៧មុខវិជ្ជាដែរ គឺ១. ភាសាខ្មែរ ២. ភាសាបរទេស ៣. គណិតវិទ្យា ៤.វិទ្យាសាស្ត្រ (៤) ៥.សិក្សាសង្គម (៤) ៦.អប់រំកាយ កីឡា និងសុខភាព ៧.កម្មវិធី បំណិនជីវិតតាមមូលដ្ឋាន (រួមទាំងអប់រំសិល្បៈ) ភាសាបរទេស ៖ ភាសាបារាំង /អង់គ្លេស, ថ្នាក់ទី១១ និងទី១២ គឺ៣២ម៉ោងក្នុងមួយសប្តាហ៍ ៣៨សប្តាហ៍ ក្នុង១ឆ្នាំសិក្សា និង១២១៦ម៉ោងក្នុង១ឆ្នាំសិក្សា ។

**ឆ្នាំ២០១១ ដល់ឆ្នាំ២០១៥** នៅបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ មិនមានការប្រែប្រួលទេ មានតែមួយចំណុច គឺយើងដាក់បង្រៀនភាសាអង់គ្លេសពីថ្នាក់ទី៤ ឡើងទៅ។ យោងសេចក្តីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការ អនុវត្តកម្មវិធីសិក្សានៅមធ្យមសិក្សាទុតិយភូមិ ដោយប្តូរពីការសិក្សាមុខវិជ្ជាគោល និងជ្រើសរើស មកជា ការបែងចែកជាពីរបណ្តុំមុខវិជ្ជានៅថ្នាក់ទី១១ និងទី១២គឺបណ្តុំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ មូលហេតុនៃការប្រែប្រួលៈ(បញ្ហាវិញ្ញាសាប្រឡង ការរៀបចំថ្នាក់ គ្រូបង្រៀន យន្តការនៃការជ្រើសរើសមុខវិជ្ជា ជាដើម)។

**ឆ្នាំ២០១៦** ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែទម្រង់កម្មវិធីសិក្សាថ្មី ដោយអភិវឌ្ឍន៍ក្របខណ្ឌកម្មវិធីសិក្សាសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សា សៀវភៅសិក្សាគោល និង

សម្ភារឧបទេស ព្រមទាំង បង្កើតចក្ខុវិស័យថ្មីគឺ៖ ធានាអប់រំពលរដ្ឋឱ្យមានលក្ខណៈសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក មានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទានិងមនសិការ ស្នេហាជាតិ ដើម្បីអភិវឌ្ឍន៍ជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។

នៅក្នុងដំណាក់កាលនេះក្របខណ្ឌកម្មវិធីសិក្សាបានបញ្ចូលភាសាអង់គ្លេស និងកុំព្យូទ័រ ចាប់ពីថ្នាក់ទី៤ឡើងទៅ និងសម្រាប់មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧ ដល់ទី៩) ចំនួនមុខវិជ្ជាមាន ១៥មុខវិជ្ជា បញ្ចូលមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ សម្រាប់មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០ ដល់ទី១២) គឺចែកជា២បណ្តុំមុខវិជ្ជា(វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម) ហើយចំនួនម៉ោងសិក្សា ក្នុង១ ឆ្នាំសិក្សាគឺ១៤០០ម៉ោង និងចំនួនម៉ោងសរុបក្នុងមួយសប្តាហ៍គឺ **៤០ម៉ោង** ។

លទ្ធផលនៃការសិក្សាទៅលើកម្មវិធីសិក្សា និងការវិភាគសៀវភៅសិក្សាគោលដែលកំពុងប្រើប្រាស់ នាពេលបច្ចុប្បន្នបានបង្ហាញពីភាពចាំបាច់ ដើម្បីធានាថាខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោលមាន ការពាក់ព័ន្ធគ្នាពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយ តាមលំដាប់លំដោយ និងគ្រប់ជ្រុងជ្រោយ។ លើសពីនេះទៅទៀត មេរៀនខ្លះនៃមុខវិជ្ជាមួយចំនួន ជាពិសេសមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រនៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ត្រូវឱ្យមានការពាក់ព័ន្ធទៅនឹងការអនុវត្តជាក់ស្តែងនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងការវិវត្ត របស់ពិភពលោក។ សិស្សដែលបញ្ចប់ការសិក្សាពីភូមិសិក្សានីមួយៗ មានសមត្ថភាពគ្រប់គ្រាន់សម្រាប់ ប្រកបកិច្ចការរស់នៅ សម្រាប់បន្តការសិក្សានៅសាលាបច្ចេកទេសឬនៅគ្រឹះស្ថានឧត្តមសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡាបានប្រកាសស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសនេះឱ្យមានប្រសិទ្ធភាពខ្ពស់សម្រាប់អភិវឌ្ឍន៍សមត្ថភាពពលរដ្ឋ ឆ្លើយតបការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក និងធ្វើការកែសម្រួលរៀងរាល់ ៥ ឆ្នាំម្តងតាមរយៈក្រុមការងារអភិវឌ្ឍន៍ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងក្រុមការងារបច្ចេក-ទេស ហើយត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧តទៅ។ ដូចនេះការអភិវឌ្ឍកម្មវិធីសិក្សានៅពេលនេះ ជាដំណាក់ កាលទី៣គឺដើម្បីធ្វើឱ្យសមត្ថភាពសិស្សដែលបញ្ចប់ការសិក្សាពីភូមិសិក្សានីមួយៗមានចំណេះដឹង បំណិន និងឥរិយាបថសម្រាប់ប្រកបកិច្ចការ

រស់នៅប្រចាំថ្ងៃនិងសម្រាប់បន្តការសិក្សា។ ជាងនេះទៅទៀត ក្របខណ្ឌកម្មវិធីសិក្សានេះ គឺធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពអប់រំ ឆ្លើយតបទៅនឹងការប្រែប្រួលរបស់ពិភពលោក និងឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ ដែលបានបង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការប្រែក្លាយទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ជំណូលខ្ពស់នៅឆ្នាំ២០៥០ (ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស,២០១៦)។

ដោយផ្អែកលើសៀវភៅក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសបោះពុម្ពឆ្នាំ ២០១៦ កម្មវិធីសិក្សាជាតិត្រូវកំណត់ឱ្យបង្រៀន៣៥សប្តាហ៍ក្នុងមួយឆ្នាំសិក្សា ហើយចែកចេញជាបីផ្នែក សំខាន់ៗ គឺកម្មវិធីសិក្សាចំណេះទូទៅ(មត្តេយ្យសិក្សា និងបឋមសិក្សា) កម្មវិធីសិក្សាអប់រំមូលដ្ឋាន និងកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ។

**ក.កម្មវិធីសិក្សាចំណេះទូទៅ (មត្តេយ្យ និងបឋមសិក្សា)**

ពីឆ្នាំ២០០៥-២០០៩ វត្ថុបំណងនៃការអប់រំគឺអភិវឌ្ឍទេពកោសល្យ និងសមត្ថភាពរបស់សិស្ស ដើម្បីឱ្យគេក្លាយជាមនុស្សពេញលេញរីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបរាងកាយ។ ជាពិសេសឱ្យពួកគេអាចមានចំណូលចិត្ត និងស្រឡាញ់ការសិក្សា ដើម្បីបម្រើការងារ និងបន្តការសិក្សាពេញមួយជីវិតបាន មានចំណេះដឹងផ្នែកភាសាខ្មែរ អក្សរសាស្ត្រខ្មែរ និងគណិតវិទ្យាជាមូលដ្ឋាន។ មានចំណេះដឹង បំណិន និងឥរិយាបថចាំបាច់ដើម្បីលើកស្ទួយ ការថែរក្សាសុខភាពផ្នែកផ្លូវកាយបញ្ញាស្មារតីរបស់ខ្លួន ហើយចូលរួមចំណែកក្នុងការ លើកស្ទួយការថែរក្សាសុខភាពក្រុមគ្រួសារ និងសង្គមឱ្យកាន់តែល្អប្រសើរថែមទៀត។ មានសមត្ថភាពគ្រប់គ្រង មានទំនួលខុសត្រូវ លើសកម្មភាព លើសេចក្តីសម្រេចរបស់ខ្លួន និងមានជំនឿជាក់លើខ្លួនឯង មានការកោតសរសើរ និងឱ្យតម្លៃទៅលើសារៈសំខាន់នៃគំនិតវិទ្យាសាស្ត្រ បច្ចេកវិទ្យា ការបង្កើតថ្មី និងគំនិតច្នៃប្រឌិត មានបំណិនក្នុងការ បម្រើការងារ យល់ដឹង និងមានឥរិយាបថវិជ្ជមានចំពោះការងារ មានសមត្ថភាពធ្វើការងារជាមួយអ្នកដទៃ ប្រកបដោយប្រសិទ្ធភាព និងភាពសុខដុម មានសមត្ថភាពក្នុងការពិចារណាថ្លឹងថ្លែង មានស្មារតីទទួលខុសត្រូវ មានសីលធម៌ ចេះបែងចែក វិភាគ ដោះស្រាយបញ្ហាក្នុងគ្រួសារនិងសង្គម។ ស្វែងយល់ និងឱ្យតម្លៃដល់អ្នកដទៃ ដល់អរិយធម៌ វប្បធម៌ផ្សេងៗ ប្រវត្តិសាស្ត្រនានា ដែលអាចឈានទៅរកការកសាងស្មារតីសាធារណៈ ក្នុងន័យចេះគោរពសិទ្ធអ្នកដទៃ និងមានសមធម៌។ ជាពលរដ្ឋសកម្ម មានគំនិតយល់ដឹងជ្រៅជ្រះអំពីការ

វិវត្តនៃសង្គម ប្រព័ន្ធគ្រប់គ្រងច្បាប់ទម្លាប់របស់ប្រទេសកម្ពុជា ចេះរក្សា និងលើកស្ទួយតម្លៃជាតិ មានស្មារតីស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្រ យល់ដឹងពីសារៈសំខាន់ និងចេះការពារថែរក្សាបរិស្ថានធម្មជាតិសង្គមនិងវប្បធម៌ ចំណុចគន្លឹះនៃការកែលម្អកម្មវិធីសិក្សាឆ្នាំ១៩៩៦ ដែលមាន ក្នុងរចនាសម្ព័ន្ធថ្មីមានដូចតទៅៈ

សម្រួលកម្មវិធីសិក្សាផ្នែកដំបូងនៃបឋមសិក្សាដើម្បីឱ្យគ្រូអាចផ្តោតលើការ បង្រៀន ដែលអាចធ្វើ ឱ្យសិស្សទាំងអស់ចេះភាសាខ្មែរ និងចេះគណនាលេខស្ទាត់នៅជំណាច់ថ្នាក់ទី៣ ឱ្យនិយមន័យ និងបញ្ជាក់ពីការផ្តល់ការអប់រំបំណិនជីវិត និងផ្តល់ឱកាស អនុវត្តកម្មវិធី បំណិនជីវិតតាមមូលដ្ឋាន ប្រើគោលវិធី បញ្ចូលគ្នានូវមុខវិជ្ជាវិទ្យាសាស្ត្រ និងសិក្សាសង្គមក្នុង ការអប់រំមូលដ្ឋាន ដើម្បីធ្វើឱ្យការបង្រៀនកាន់តែមាន គុណភាព និងប្រសិទ្ធភាពខ្ពស់។ ការបង្រៀនភាសាបរទេសជាអាទិភាពមួយ។ ផែនការណែនាំការបង្រៀនភាសាបរទេស អាស្រ័យលើអត្ថិភាពធនធានដែលមានក្នុងប្រទេសទាំងមូល។ ក្រសួងនឹងផ្តល់ការបង្រៀន ភាសាបរទេសចាប់ពីថ្នាក់ទី៤ដល់ថ្នាក់ទី១២។ ក្រសួងអប់រំ យុវជន និងកីឡា នឹងជំរុញសាលារៀនឱ្យ បង្រៀនភាសាបរទេសដោយប្រើធនធានឧបត្ថម្ភពីខាងក្រៅនិងប្រើម៉ោងក្នុងកម្មវិធីបំណិនជីវិតមូលដ្ឋាន។ មានរចនាសម្ព័ន្ធច្បាស់លាស់សម្រាប់អភិវឌ្ឍន៍ស្តង់ដាមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា (ការគណនាលេខ)នៅជំណាច់ថ្នាក់ទី៣ និងទី៦ ព្រមទាំងមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម និងភាសាបរទេសក្នុងការប្រឡងថ្នាក់ជាតិនៅជំណាច់ថ្នាក់ទី៩ ហើយមានជម្រើសមុខវិជ្ជាសិក្សានៅថ្នាក់ ទី១១ និងទី១២ ដោយមានបន្ថែមម៉ោងសិក្សា សម្រាប់មុខវិជ្ជានីមួយៗ ដើម្បីឱ្យសិស្សដែលបានបញ្ចប់ការសិក្សាកាន់តែមានគុណភាពល្អប្រសើរ។ មុខវិជ្ជាដែលសិស្សត្រូវរៀនមានចំនួនតិចជាងមុន មានរចនាសម្ព័ន្ធច្បាស់លាស់ សម្រាប់ពង្រីក ការផ្តល់ការអប់រំនៅមធ្យមសិក្សាទុតិយភូមិ តាមរយៈភាពជាដៃគូរដ្ឋ និង ឯកជន។

**តារាងទី១ៈរបាយមុខវិជ្ជានិងម៉ោងសិក្សា(សម្រាប់មត្តេយ្យសិក្សា)**

| ល.រ. | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ |
| ១ | ចិត្តចលភាព | ៦ | ៦ | ៦ |
| ២ | បុរេគណិត | ៣ | ៣ | ៣ |
| ៣ | បុរេសំណេរ | ៤ | ៤ | ៤ |
| ៤ | វិទ្យាសាស្ត្រ | ៣ | ៣ | ៣ |

| ៥ | សិក្សាសង្គម | ១៤ | ១៤ | ១៤ |
|---|---|---|---|---|
| **សរុបម៉ោងសិក្សាប្រចាំសប្តាហ៍** | | **៣០** | **៣០** | **៣០** |

សម្គាល់:៥ថ្ងៃក្នុងមួយសប្តាហ៍៦ម៉ោងសិក្សាក្នុងមួយថ្ងៃនិង១ម៉ោងសិក្សាមានរយៈពេល៣០នាទី ។

**តារាងទី ២ ៖ របាយមុខវិជ្ជា និងម៉ោងសិក្សា(ពីថ្នាក់ទី១ ដល់ទី៦)**

| ល.រ | មុខវិជ្ជា | ថ្នាក់ | | | | | |
|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ភាសាខ្មែរ | ១១ | ១១ | ១១ | ៩ | ៩ | ៩ |
| ២ | គណិតវិទ្យា | ៧ | ៧ | ៧ | ៦ | ៦ | ៦ |
| ៣ | វិទ្យាសាស្ត្រ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| ៤ | កុំព្យូទ័រ | ០ | ០ | ០ | ១ | ១ | ១ |
| ៥ | សិក្សាសង្គម | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| ៦ | អប់រំសិល្បៈ | ១ | ១ | ១ | ១ | ១ | ១ |
| ៧ | អប់រំកាយ និងកីឡា | ២ | ២ | ២ | ២ | ២ | ២ |
| ៨ | អប់រំសុខភាព | ១ | ១ | ១ | ១ | ១ | ១ |
| ៩ | ភាសាបរទេស | ២ | ២ | ២ | ២ | ២ | ២ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ០ | ០ | ០ | ២ | ២ | ២ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |

សម្គាល់៖៦ថ្ងៃក្នុងមួយសប្តាហ៍ ៥ម៉ោងសិក្សាក្នុងមួយថ្ងៃ និងមួយម៉ោងសិក្សាមានរយៈពេល៤០នាទី។

**ខ.កម្មវិធីសិក្សាមធ្យមសិក្សាបឋមភូមិ**

ក្រោយពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ សិស្សនឹងទទួលបាន: វិជ្ជាសម្បទា៖ មាន ចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាព កាយសម្បទា សីលធម៌ វិទ្យាសាស្ត្រ បច្ចេក-វិទ្យាព័ត៌មាននិងសារគមនាគមន៍(ICT) និងភាសាបរទេស)។ បំណិនសម្បទា៖ មានបំណិនមូលដ្ឋានរឹងមាំ និងទូលំទូលាយផ្នែកភាសាខ្មែរ (ការអាន ការសរសេរ ការនិយាយ និងការស្តាប់) ផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀប ពន្យល់ បកស្រាយ និងដោះស្រាយបញ្ហា) ផ្នែកវិទ្យាសាស្ត្រ

បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) មូលដ្ឋាន ផ្នែកត្រិះរិះពិចារណានិង ដោះស្រាយបញ្ហាមូលដ្ឋានក្នុងការសិក្សានិងក្នុងសង្គម ផ្នែកប្រាស្រ័យទាក់ទងទូលំទូលាយ សម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ ផ្នែកបង្ការនិងថែទាំសុខភាពបឋម ព្រមទាំងមានសមត្ថភាពស្គាល់ខុស ស្គាល់ត្រូវ។ ចរិយាសម្បទា៖ ស្រឡាញ់ និងផ្តល់តម្លៃដល់ការសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធ ស្គាល់ និងឱ្យ តម្លៃសណ្តានចិត្តមេត្តា និងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ ស្គាល់ ស្រឡាញ់ ថែរក្សានិងការពារ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តំបន់ និងអន្តរជាតិ ស្រឡាញ់និងឱ្យតម្លៃបរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ មានទម្លាប់ និងអនុវត្តការរស់នៅប្រកបដោយសុខភាព តាមរយៈការធ្វើពលកម្ម និងហាត់កីឡា ទទួលខុសត្រូវ ចំពោះទង្វើរបស់ខ្លួនឯង និងរបស់ក្រុម ទាំងក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ។

**តារាងទី៣ : របាយមុខវិជ្ជានិងម៉ោងសិក្សាពីថ្នាក់ទី៧ដល់ថ្នាក់ទី៩**

| ល.រ. | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ៧ | ៨ | ៩ |
| ១ | ភាសាខ្មែរ | ៧ | ៧ | ៧ |
| ២ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៣ | គណិតវិទ្យា | ៧ | ៧ | ៧ |
| ៤ | វិទ្យាសាស្ត្រ | ៦ | ៦ | ៦ |
| ៥ | សិក្សាសង្គម | ៧ | ៧ | ៧ |
| ៦ | បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ | ២ | ២ | ២ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៨ | អប់រំសិល្បៈ | ១ | ១ | ១ |
| ៩ | អប់រំសុខភាព | ១ | ១ | ១ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ១ | ១ | ១ |
| **សរុបម៉ោងសិក្សាប្រចាំសប្តាហ៍** | | **៤០** | **៤០** | **៤០** |

សម្គាល់: ៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈ ពេល ៥០នាទី។ ជីវភាសាទី១មាន ៤ម៉ោងសិក្សានិង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

### គ.កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ

កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ដល់ទី១២ មានគោលបំណងមិនគ្រាន់ តែពង្រឹង និងពង្រីកចំណេះដឹង ដែលសិស្សទទួលបានពីកម្មវិធីសិក្សាអប់រំកម្រិតមូលដ្ឋានប៉ុណ្ណោះទេ គឺ ថែមទាំងផ្តល់ការសិក្សាបែបតម្រង់ទិស ដើម្បីឱ្យសិស្សមានសមត្ថភាពអាចបន្តការសិក្សានៅឧត្តមសិក្សា ឬសិក្សាឯកទេស ឬចូលរួមក្នុងជីវភាពសង្គម ដោយធានាថាសិស្សនឹងទទួលបាននូវការចេះដឹងកាន់តែខ្ពស់ផ្នែកអក្សរសាស្ត្រខ្មែរ និងគណិតវិទ្យា ស្គាល់អត្តសញ្ញាណជាតិកាន់តែច្បាស់ មានការអភិវឌ្ឍការយល់ដឹងកាន់តែខ្លាំងពីសីលធម៌រស់នៅ និងការទទួលខុសត្រូវរបស់ពលរដ្ឋចំពោះប្រទេស មានបំណិនជីវិតប្រចាំ ថ្ងៃចាំបាច់ សម្រាប់ការចូលរួមក្នុងជីវភាពសហគមន៍មូលដ្ឋាន និងក្នុងសង្គមកម្ពុជា មានការយល់ដឹងកាន់តែទូលំទូលាយពីពិភពលោក និងគោលការណ៍វិទ្យាសាស្ត្រ។សមត្ថភាពកាន់តែខ្ពស់ក្នុងការទំនាក់ទំនងជាភាសាបរទេស។

កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិចែកចេញជា ៣ បណ្តុំមុខវិជ្ជារួមមាន៖ បណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ បណ្តុំមុខវិជ្ជាវិទ្យាសង្គម និងបណ្តុំមុខវិជ្ជាអប់រំបច្ចេកទេស ពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។ គោលបំណងនៃកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិគឺ ពង្រឹងនិងពង្រីកចំណេះដឹងដែលសិស្សទទួលបានពីកម្រិតអប់រំមូលដ្ឋាន ដោយផ្តល់ឱកាសឱ្យសិស្សជ្រើសរើសមុខវិជ្ជាឯកទេសដែលខ្លួនពេញចិត្ត ដើម្បីអភិវឌ្ឍន៍ចំណេះដឹងឱ្យកាន់តែស៊ីជម្រៅលើមុខវិជ្ជានេះ ឬជ្រើសរើសមុខវិជ្ជាដែលមានមូលដ្ឋានសិក្សាឯកទេសវិជ្ជាជីវៈ ដើម្បីអាចបន្តការសិក្សានៅឧត្តមសិក្សា ឬសិក្សាឯកទេសវិជ្ជាជីវៈ ឬចូលរួមក្នុងជីវ ភាពសង្គម។

**តារាងទី៩៖របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ទី១១និងទី១២(បណ្តុំវិទ្យាសាស្ត្រ)**

| ល.រ | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | អក្សរសាស្ត្រខ្មែរ | **៥** | **៥** | **៥** |
| ២ | គណិតវិទ្យា | **៦** | **៦** | **៦** |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | **៤** | **៤** | **៤** |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ | ៣ |

| | | | | |
|---|---|---|---|---|
| ៩ | ជីវវិទ្យា | ៣ | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | **២** | **២** | **២** |
| ១១ | ភូមិវិទ្យា | ២ | ២ | ២ |
| ១២ | សីលធម៌ពលរដ្ឋវិជ្ជា | ២ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | **៤០** | **៤០** | **៤០** |

**សម្គាល់៖** ៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០ នាទី។ ជីវភាសាទី១ មាន៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

**តារាងទី ៥ ៖ របាយមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១០ ទី១១និងទី១២៩ (បណ្តុំវិទ្យាសាស្ត្រសង្គម)**

| ល.រ | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | អក្សរសាស្ត្រខ្មែរ | **៦** | **៦** | **៦** |
| ២ | គណិតវិទ្យា | **៥** | **៥** | **៥** |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | **២** | **២** | **២** |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ | ៣ |
| ៩ | ជីវវិទ្យា | ៣ | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | **៤** | **៤** | **៤** |
| ១១ | ភូមិវិទ្យា | ២ | ២ | ២ |
| ១២ | សីលធម៌ពលរដ្ឋវិជ្ជា | ២ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |

| | | | |
|---|---|---|---|
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | ៤០ | ៤០ | ៤០ |

សម្គាល់៖៦ថ្ងៃក្នុងមួយសប្តាហ៍ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០នាទី។ ការអប់រំបច្ចេកទេសមានមុខវិជ្ជាពីរគឺ មុខវិជ្ជាចំណេះទូទៅ និងមុខវិជ្ជាវិជ្ជាជីវៈ។ មុខវិជ្ជាចំណេះទូទៅ រួមមានអក្សរសាស្ត្រខ្មែរ ភាសាអង់គ្លេស គណិតវិទ្យា កុំព្យូទ័រ សីលធម៌ពលរដ្ឋវិជ្ជា កីឡា វិទ្យាសាស្ត្រ(រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា) វិទ្យាសាស្ត្រសង្គម(ប្រវត្តិវិទ្យា ភូមិវិទ្យា សេដ្ឋកិច្ច)។ មុខវិជ្ជាវិជ្ជាជីវៈរួមមានមុខវិជ្ជាបច្ចេកទេសវិជ្ជាជីវៈ និងមុខវិជ្ជាជីវៈតាមតំបន់។

**តារាងទី៦: របាយមុខវិជ្ជានិងម៉ោងសិក្សាឆ្នាំទី១ ឆ្នាំទី២ និងឆ្នាំទី៣**

| មុខវិជ្ជា | | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ |
|---|---|---|---|---|---|
| មុខវិជ្ជាចំណេះទូទៅ | អក្សរសាស្ត្រខ្មែរ | | ១១៤ម៉ោង | ១១៤ម៉ោង | ១១៤ម៉ោង |
| | ភាសាអង់គ្លេស | | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | គណិតវិទ្យា | | ១១៤ម៉ោង | ១១៤ម៉ោង | ១១៤ម៉ោង |
| | កុំព្យូទ័រ | | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | សីលធម៌ពលរដ្ឋវិជ្ជា | | ៣៨ម៉ោង | ៣៨ម៉ោង | ០ម៉ោង |
| | កីឡា | | ៣២ម៉ោង | ៣២ម៉ោង | ៣២ម៉ោង |
| | វិទ្យាសាស្ត្រឬវិទ្យាសាស្ត្រសង្គម | រូបវិទ្យា(១) | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | | គីមីវិទ្យាជីវវិទ្យា(២) | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | | សេដ្ឋកិច្ច(៣) | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | | ប្រវត្តិវិទ្យា-ភូមិវិទ្យា | ៧៦ម៉ោង | ៧៦ម៉ោង | ៧៦ម៉ោង |
| | សរុប | | ៥២៦ម៉ោង | ៥២៦ម៉ោង | ៤៨០ម៉ោង |
| មុខវិជ្ជាវិជ្ជាជីវៈ | មុខវិជ្ជាបច្ចេកទេសវិជ្ជាជីវៈ | | ៧៤៩-៧៦៩ម៉ោង | ៧៤៩-៧៦៩ម៉ោង | ៧៤៩-៧៦៩ម៉ោង |
| | មុខវិជ្ជាវិជ្ជាជីវៈតាមតំបន់ | | ៨០-១០០ម៉ោង | ៨០-១០០ម៉ោង | ៨០-១០០ម៉ោង |

| មុខវិជ្ជា | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ |
|---|---|---|---|---|
| | សរុប | ៨៤៨ម៉ោង | ៨៤៨ម៉ោង | ៨៤៨ម៉ោង |
| សកម្មភាពជម្រើស | | ៦ម៉ោង | ៦ម៉ោង | ៦ម៉ោង |
| កម្មសិក្សា | | | | ៣២០ម៉ោង (មិនរាប់បញ្ចូល) |
| សរុបរួម | | **១៣៨០ម៉ោង** | **១៣៨០ម៉ោង** | **១៣៣៤ម៉ោង** |

**សម្គាល់** :សិក្សា៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទៅ៦ម៉ោងសិក្សាក្នុងមួយថ្ងៃ ១ម៉ោងសិក្សារយៈពេល ៥០នាទី ១ឆ្នាំសិក្សារយៈពេល៣៨សប្តាហ៍។

(១) ត្រូវរៀនមុខវិជ្ជារូបវិទ្យា ចំនួន២ម៉ោងសិក្សាក្នុង១សប្តាហ៍ លើមុខជំនាញមេកានិចអេឡិចត្រូនិចឬអគ្គិសនី ដែលមានចំនួន៧៦ម៉ោងក្នុងមួយឆ្នាំ

(២) ត្រូវរៀនមុខវិជ្ជាគីមីវិទ្យា/ជីវវិទ្យា ចំនួន២ម៉ោងក្នុង១សប្តាហ៍ លើមុខជំនាញក្សេត្រសាស្រ្ត ឬបសុវប្បកម្ម ដែលមានចំនួន៧៦ម៉ោងក្នុងមួយឆ្នាំ

(៣) ត្រូវរៀនមុខវិជ្ជាសេដ្ឋកិច្ច ចំនួន២ម៉ោងក្នុង១សប្តាហ៍ លើមុខជំនាញគណនេយ្យនិងគ្រប់គ្រង ដែលមានចំនួន៧៦ម៉ោងក្នុងមួយឆ្នាំ។

## ២.៣.ការអនុវត្តកម្មវិធីសិក្សាកន្លងមក

ការបង្រៀនប្រកបដោយភាពជោគជ័យ គឺត្រូវគោរពទៅតាមនិតិវិធីត្រឹមត្រូវនិងមានការរៀបចំដំណើរការស្របទៅនឹងប្រព័ន្ធអប់រំ និងការតាមដានត្រួតពិនិត្យដើម្បីឱ្យដឹងថាតើគោល-នយោបាយត្រូវអនុវត្តតាមដែរឬទេ។ វាអាស្រ័យទៅតាមការរៀបចំរបស់ស្ថាប័នដែលមានដូចជា តើគ្រូបានបណ្តុះបណ្តាលត្រឹមត្រូវ និងប្រើប្រាស់ទៅតាមសមត្ថភាពរបស់ពួកគេដែរឬទេ តើមានការផ្តល់មូលនិធិគ្រប់គ្រាន់ដែរឬទេ និងតើការប្រើប្រាស់មូលនិធិបានត្រឹមត្រូវប្រកបដោយភាពឆ្លើយតបដែរឬទេ និងមានការរៀបចំរដ្ឋបាល ប្រកបដោយប្រសិទ្ធភាពគ្រប់គ្រាន់ ដែរឬទេ។ ទាំងនេះនឹងធ្វើឱ្យការអនុវត្តគោលនយោបាយអប់រំ ប្រកបដោយភាពជោគជ័យ(Van Schalk, ១៩៨៨:៨)។

Spady (១៩៩៤, p. ១២) ការអប់រំផ្តោតលើលទ្ធផលសិក្សា មានន័យថា គឺជាការផ្តោតលើការរៀបចំអ្វីៗទាំងអស់ដែលមានសារៈសំខាន់បំផុតសម្រាប់សិស្ស ឱ្យបានច្បាស់លាស់នៅក្នុងប្រព័ន្ធអប់រំ ដើម្បីឱ្យពួកគាត់អាចទទួលបានជោគជ័យក្នុងការសិក្សា។ Tucker (២០០៤) បានបន្ថែមទៀតថា ការអប់រំដោយផ្តោតលើលទ្ធផលសិក្សា គឺជាដំណើរការដែលគួររួមបញ្ចូលទាំង

ការកែលម្អកម្មវិធីសិក្សាឡើងវិញ វាយតម្លៃនិងរបាយការណ៍ស្តីពីការអនុវត្ត នៅក្នុងការអប់រំ។ នោះសំដៅទៅលើ លទ្ធផលសិក្សារបស់សិស្សជាជាងផ្តោតលើក្រេឌីតនៃវគ្គសិក្សា។ លទ្ធផលសិក្សាសំដៅលើសមត្ថភាពរំពឹងទុកដែល សិស្សទទួលបានក្រោយពីបញ្ចប់ការសិក្សានៅកម្រិតណាមួយ ដែលមិនមែនសំដៅលើការចាត់ចំណាត់ ថ្នាក់នោះទេ។ ដូចនេះការអនុវត្តការអប់រំដោយផ្តោតលើលទ្ធផលសិក្សា ទាមទារឱ្យមានការស៊ីសង្វាក់គ្នា រវាងលទ្ធផលសិក្សារបស់សិស្ស សកម្មភាពបង្រៀននិងរៀន វិធីសាស្ត្រក្នុងការវាយតម្លៃសមត្ថភាពសិស្ស និងការអនុវត្ត។ ដើម្បីរៀបចំប្រព័ន្ធអប់រំបែបនេះ កម្មវិធីសិក្សា ធនធាន សម្ភារសិក្សា សកម្មភាពផ្សេងៗ នៅក្នុងកម្មវិធីសិក្សា គួរតែត្រូវបានរៀបចំចាត់ចែងឱ្យសមស្របទៅតាមលទ្ធផលរំពឹងទុក។

Spady (១៩៩៤) បានកំណត់គោលការណ៍៣សំខាន់បំផុតក្នុងការអនុវត្តការអប់រំផ្តោតលើលទ្ធផលសិក្សារបស់សិស្សប្រកបដោយជោគជ័យមានដូចជា៖ ១)ការយល់ដឹងច្បាស់លាស់អំពីលទ្ធផលសិក្សា របស់សិស្ស។គ្រូត្រូវដឹងនិងយល់ច្បាស់អំពីលទ្ធផលសិក្សារំពឹងទុករបស់សិស្ស ដើម្បីការបង្រៀនទទួលបានជោគជ័យ ត្រូវតែធ្វើតេស្តវាយតម្លៃសមត្ថភាពសិស្សនិងទទួលយកព័ត៌មានត្រឡប់ ដើម្បីឈាន ដល់គោលបំណងដែលបានកំណត់ ២) គ្រូគួរទទួលបានឱកាសទូលំទូលាយ និងគាំទ្រការបង្រៀនរបស់ គាត់ដោយវិធីសាស្ត្រគ្រូបង្វឹកនិងឱ្យសិស្សមានពេលវេលា និងឱកាសគ្រប់គ្រាន់ ដើម្បីលើកកម្ពស់ការសិក្សា របស់ខ្លួន ៣)សាលារៀនត្រូវតែជំរុញការរំពឹងទុកឱ្យបានខ្ពស់ សម្រាប់ការសិក្សាប្រកបដោយជោគជ័យដោយទាមទារឱ្យសិស្សទាំងអស់ (មិនមែនមួយចំនួនតូច) ទទួលបានលទ្ធផលសិក្សាកម្រិតខ្ពស់។ McGee,១៩៩៧ ជឿថាគ្រូបង្រៀនគឺជាអ្នកធ្វើការសម្រេចចិត្តយ៉ាងសំខាន់បំផុតនៅក្នុងកម្មវិធីសិក្សា។ ពួកគេធ្វើការសម្រេចចិត្តជាច្រើនដោយគោរពទៅតាមកម្មិវិធីសិក្សា ដោយគិតគូរទៅលើសមត្ថភាពរបស់សិស្ស ឯកសារកម្មវិធីសិក្សា ធនធានដែលមានស្រាប់និងចំណុចខ្លាំងរបស់គេ។ គាត់ជឿថាគ្រូបង្រៀនគួរមានឯករាជ្យភាពនៃវិជ្ជាជីវៈ ដើម្បីឱ្យពួកគេអាច អនុវត្តកម្មវិធីសិក្សា ប្រកបដោយប្រសិទ្ធភាព ហើយពួកគេត្រូវតែមានឱកាស ដើម្បីបន្សុំាខ្លួនទៅនឹងកម្មវិធីសិក្សានិងបញ្ហារបស់កម្មវិធីសិក្សា។ គ្រូដែល មានគុណវុឌ្ឍិខ្ពស់អាចអនុវត្តការបង្រៀនប្រកបដោយគុណភាព មានន័យថាសិស្សរបស់ពួកគាត់ទទួល បានលទ្ធផលសិក្សាខ្ពស់ដែលទាំងនេះជាការរំពឹងទុករបស់ភាគីពាក់ព័ន្ធជាច្រើន។ ការរំពឹងទុកខ្ពស់នឹងត្រូវ បានសម្រេចនៅពេលដែលចំណេះដឹងលើខ្លឹមសាររបស់គ្រូប្រសើរឡើង។ ចំណេះដឹងលើខ្លឹមសារសំដៅលើ ចំណេះដឹង ការយល់ដឹង ជំនាញនិងបញ្ញត្តិដែលសិស្សត្រូវរៀននៅសាលា។ ខ្លឹមសារចំណេះដឹងផ្អែក លើថាគ្រូបង្រៀនមានធនធានវិជ្ជាជីវៈ

ល្អ និងមានចំណេះដឹងមូលដ្ឋានគ្រឹះនូវមុខវិជ្ជាដែលត្រូវបង្រៀន និង ចំណេះដឹងទូលំទូលាយជាមូលដ្ឋានដើម្បីអាចធ្វើការពន្យល់ផ្សេងៗនូវគំនិតស្រដៀងៗគ្នាឬទស្សនវិជ្ជា(Shulman, ១៩៨៧)។

ការសិក្សាស្រាវជ្រាវរកឃើញថា ការលើកទឹកចិត្តមានឥទ្ធិពលលើការរៀនរបស់សិស្សជាទូទៅ ជាពិសេសសិស្សនៅអាស៊ាន(Young, Johnson, Arthur, & Hawthome, ២០១១; Zhu & Leung, ២០១១)។ ការជំរុញទឹកចិត្តមាន២ប្រភេទគឺការលើកទឹកចិត្តពីខាងក្នុង និងកត្តាខាងក្រៅ។ ការជំរុញ ខាងក្នុងគឺជាការជំរុញដ៏មានឥទ្ធិពលបំផុតក្នុងការចូលរួមយ៉ាងសកម្មក្នុងការសិក្សានៅសាលា និងការ ទទួលបានជោគជ័យ (Hardre & Reeve, ២០០៣; Lau & Chan, ២០០៣; Reeve, bolt, & Cai, ១៩៩៩; Vallerand, Fortier, & Guay, ១៩៩៧)។ Deci (១៩៩២) បានកំណត់ថាកត្តាខាងក្នុង គឺជា ការជ្រើសរើសក្នុងការបំពេញភារកិច្ចណាមួយដែលកើតចេញពីក្នុងខ្លួនរបស់អ្នកអនុវត្តផ្ទាល់ ចំណែកឯ កត្តាខាងក្រៅគឺជាការបំពេញភារកិច្ចដោយមានរង្វាន់លើកទឹកចិត្ត។ ប៉ុន្តែមិនមែនគ្រប់សិស្សទាំងអស់សុទ្ធតែមានការលើកទឹកចិត្តពីខាងក្នុងលើគ្រប់មុខវិជ្ជានោះទេ សិស្សអាចមានការលើកទឹកចិត្តខ្ពស់ចំពោះកិច្ចការសាលានិងខ្លឹមសារមេរៀនតាមរយៈខ្លួនឯងផ្ទាល់។ ដំណើរការដែលអាចឱ្យសិស្សបង្កើនការតាំងចិត្តនិងការឱ្យតម្លៃទៅលើការសិក្សា និងមានភាពម្ចាស់ការលើដំណើរការរៀន (Reeve, Deci, & Ryan, ២០០៤; Ryan & Connel,១៩៨៩)។ ការលើកទឹកចិត្តពីខាងក្នុងតាមរយៈចរិតលក្ខណៈសំខាន់៣របស់សិស្សគឺឯករាជ្យភាព សមត្ថភាព និងភាពឆ្លើយតប(Black & Deci, ២០០០; Ryan & Deci,២០០០)។ តាមរយៈការលើកទឹកចិត្តពីខាងក្នុង សិស្សអាចនឹងមានការតាំងចិត្តខ្ពស់ក្នុងការសិក្សា(Deci, ១៩៩៥; Reeve et al.,២០០៤)។ ថ្នាក់រៀននិងបរិស្ថានសាលារៀនអាចជាកត្តាគាំទ្រ និងកាត់បន្ថយការលើកទឹក ចិត្តពីខាងក្នុងនិងខាងក្រៅដល់សិស្សតាមរយៈការយល់ឃើញរបស់សិស្សចំពោះគ្រូ និងមានឥទ្ធិពលពី សំណាក់មិត្តភក្តិ និងសង្គម(Deci & Ryan, ២០០០; Reeve, ១៩៩៦; Reeve et al., ២០០៤)។

Mason ក៏បានបង្ហាញថា ក្នុងការដឹកនាំការបង្រៀន នាយកសាលា ឬគណៈនាយកអាចកំណត់ នូវផែនការកម្មវិធីសិក្សានៅក្នុងសាលារៀន ជួយអភិវឌ្ឍសកម្មភាពនានាក្នុងការអប់រំផ្តោតលើលទ្ធផល អភិវឌ្ឍនិងគ្រប់គ្រងយុទ្ធសាស្ត្រក្នុងការវាយតម្លៃ ធានាបាននូវម៉ោងបង្រៀននិងរៀន បានអនុវត្តប្រកប ដោយប្រសិទ្ធភាព លើកកម្ពស់និងប្រើប្រាស់ ផែនការបច្ចេកទេសដែលរៀបចំដោយក្រុមអភិវឌ្ឍ និងគ្រប់គ្រងធនធានសិក្សា។ ក្នុងកិច្ចការស្រាវជ្រាវនេះ ការដឹកនាំការបង្រៀនគឺសំដៅលើការគាំទ្ររបស់ប្រធាន ក្រុមបច្ចេកទេសក្នុងការអនុវត្តកម្មវិធីសិក្សានៅក្នុង

សាលារៀន ដើម្បីឱ្យការបង្រៀន និងរៀនប្រកបដោយ ប្រសិទ្ធភាព។ ប្រធានក្រុមបច្ចេកទេស គួរតែលើកកម្ពស់ថ្នាក់និទស្សន៍ និងលើកកម្ពស់ឱ្យគ្រូដែលបង្រៀន មុខវិជ្ជាដូចគ្នា ធ្វើការចែករំលែកចំណេះដឹងនិងបទពិសោធន៍រវាងគ្នានឹងគ្នា (Mason, ២០០៤) ។

## ២.៤.បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា

តាមករណីសិក្សារបស់ Nontuthuzelo នៅអាហ្វ្រិកខាងត្បូងក្នុងឆ្នាំ២០០៣បានបង្ហាញថា ការ លំបាកច្រើនក្នុងការអនុវត្តការអប់រំផ្អែកលើលទ្ធផល ព្រោះគ្រូខ្លួនឯងមិនទាន់យល់ច្បាស់ ពីគោលនយោបាយអប់រំ។ គ្រូបង្រៀនគ្មានទំនុកចិត្តក្នុងការបង្រៀនព្រោះពួកគេយល់ថា គេមិនមានធនធានឬសម្ភារគ្រប់គ្រាន់សម្រាប់បង្រៀនសិស្សនៅឡើយ។ លោកគ្រូ អ្នកគ្រូមួយចំនួន មិនបានដឹងពីព័ត៌មានឬវគ្គបណ្តុះបណ្តាលនិងកម្មវិធីសិក្សាលម្អិតនោះទេ។ ពេលវេលាសម្រាប់បង្រៀនមិនគ្រប់គ្រាន់ សាលាមួយចំនួននៅ តែប្រឆាំងនឹងការអប់រំផ្តោតលើលទ្ធផលនៅឡើយ។

នៅក្នុងប្រទេស Nigeria លោកគ្រូ អ្នកគ្រូបានធ្វើការចាត់ថ្នាក់លើបញ្ហាទាំង១៥ ក្នុងការអនុវត្តកម្មវិធីសិក្សា ក្នុងនោះមានបញ្ហា៦ ដែលបានស្ថិតក្នុងចំណាត់ថ្នាក់លេខ២គឺ ពេលវេលាមិនគ្រប់គ្រាន់ក្នុង ការបង្រៀនឱ្យទាន់កម្មវិធីសិក្សា គុណវុឌ្ឍិគ្រូទាប និងខ្វះធនធានសម្ភារ ការត្រួតពិនិត្យតាមដានវាយតម្លៃ និងការគាំទ្របច្ចេកទេសមិនបានត្រឹមត្រូវ។ គ្រូបង្រៀនមានចំណេះដឹងតិចតួចបំផុត លើការបកស្រាយពីកម្មវិធីសិក្សាស្ថិតក្នុងលំដាប់លេខ៥ (Odey & Opoh, ២០១៥)។

តាមរយៈការសិក្សាស្រាវជ្រាវរបស់ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា ករណីសិក្សាសៀវភៅសិក្សាគោលមុខវិជ្ជាគីមីបោះពុម្ពឆ្នាំ១៩៩៦-២០០៤ បានបង្ហាញនូវកត្តាមួយដែលជះឥទ្ធិពលដល់ការអនុវត្តកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល។ បញ្ហាទាំងនោះរួមមានៈ ១) កំហុសច្រើនទាំងអក្ខរាវិរុទ្ធនិងរូបមន្ត ២)មេរៀនទាំងនោះលំបាកពេកទាំងគ្រូនិងសិស្ស ៣)ចំនួនម៉ោងនិងចំនួនខ្លឹមសារមិនស៊ីគ្នា ៤)ការពន្យល់ទៅលើខ្លឹមសារមេរៀនមិនមានភាពច្បាស់លាស់និងពិបាកយល់ ៥)ខ្លឹមសារមួយចំនួនមិនទាក់ទង ទៅនឹងជីវភាពប្រចាំថ្ងៃនិងធ្វើឱ្យសិស្សគ្មានចិត្តចង់រៀន៦)មេរៀនលំបាកៗជាច្រើនមិនសមដាក់នៅកម្រិត នេះត្រូវបានដាក់បញ្ចូល ៧)មេរៀនសំខាន់ៗដែលចាំបាច់និងជាមូលដ្ឋានគ្រឹះមួយចំនួនមិនត្រូវបានដាក់បញ្ចូល ៨)ចំណងជើងមេរៀនរៀបគ្មានលំដាប់លំដោយ ៩)មេរៀនមួយចំនួនមិនមានសារសំខាន់សម្រាប់បង្រៀនសិស្សឱ្យយល់ពីគីមីវិទ្យា ១០)លំហាត់មួយចំនួនមិនផ្សារភ្ជាប់ជាមួយនឹងខ្លឹមសារមេរៀន ១១) រូបភាពសម្រាប់សង្កេតមិនមានភាពច្បាស់លាស់ ១២)លំហាត់មួយចំនួនគ្មានចម្លើយនៅក្នុងសៀវភៅគ្រូ

១៣) ខ្លឹមសារពិសោធមួយចំនួនមិនបានគិតពីសម្ភារដែលសាលាកំពុងជួបប្រទះ ចំណែកឯលំនាំពិសោធគឺតាមបែបឧស្សាហកម្ម និង១៤) ពិសោធន៍មិនត្រូវបានបង្រៀនតាមវិធីវិទ្យាសាស្ត្រ។ផ្អែកតាមរបាយការណ៍ស្ទាបស្ទង់របស់គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំលើសៀវភៅសិក្សាគោលដែលកំពុងអនុវត្តនាពេលបច្ចុប្បន្នក៏បានរកឃើញនូវបញ្ហាប្រឈមមួយចំនួនផងដែរដូចជា៖ (១) មានកំហុសអក្ខរាវិរុទ្ធ ឧ.មុខវិជ្ជា គីមីវិទ្យា ថ្នាក់ទី១០ កំហុសពាក្យបច្ចេកទេសក្នុងមេរៀនទី១ជំពូកទី២ ថ្នាក់ទី១១ កំហុសគំនូសបំព្រួញថ្ម ពិលមេរៀនទី៣ត្រង់ចំណុចអុកស៊ីតកម្ម មេរៀនទី៥ អគ្គិសនីវិភាគ និងមេរៀនទី១១ ការគណនាកម្លាំង អគ្គិសនីចលករ ថ្នាក់ទី១២ កំហុសក្នុងការសរសេររូប-មន្តអ៊ីយ៉ុងក្លរីត។មានប្រើពាក្យបច្ចេកទេសខុស និង និយមន័យខ្លះមិនច្បាស់លាស់ ឧ.មុខវិជ្ជាជីវវិទ្យាមានការប្រើប្រាស់ពាក្យពេចន៍ខុសបច្ចេកទេស និងខ្វះចន្លោះមួយចំនួនដូចជានៅថ្នាក់ទី១០មេរៀនទី៤ និងទី៦។ មុខវិជ្ជាគីមីវិទ្យាថ្នាក់១០ កំហុសត្រង់ប្រតិកម្ម បំបែក $CaCO_3$ តារាងខួបគីមី និងប្រើនិមិត្តសញ្ញាខុសពីនិមិត្តសញ្ញា ដែលធ្លាប់ប្រើពីមុន។ មុខវិជ្ជាគណិតវិទ្យាថ្នាក់ទី១២ មេរៀនចម្លាស់ និងបន្សំ លីមីត។ មុខវិជ្ជាផែនដីវិទ្យាថ្នាក់ទី១០ កំហុសត្រង់ចំណុចបរិយាកាសអតីតកាល។ ថ្នាក់ទី១១កំហុសនៅត្រង់មេរៀនភពផែនដី និងត្រង់ចំណុចការរលាយនុយក្លេអ៊ែរអាយុកាលព្រះច័ន្ទ ថ្នាក់ទី១២កំហុសក្នុងមេរៀនភពផែនដី (ភពក្នុង ប្រព័ន្ធព្រះអាទិត្យ) (២) មានខ្លឹម សារពិបាកយល់និងមិនសូវច្បាស់លាស់ ឧ.មុខវិជ្ជាជីវវិទ្យាថ្នាក់ទី១០ មេរៀនផ្សិត សត្វប្រូការី យ៉ូត និងអឺការីយ៉ូត ថ្នាក់ទី១១ មេរៀនក្រូម៉ូសូម មេរៀនដំណរពូជ មេរៀនកំណ កោសិកា និងរូបផ្គុំកោសិកា ថ្នាក់ទី១២ មេរៀនតម្រូវប្រសាទ សរីរាង្គវិញ្ញាណ និងប្រព័ន្ធអង់ដូគ្រីន។ មុខវិជ្ជាគីមីវិទ្យាថ្នាក់ទី១១ មេរៀនធរណីមាត្រនៃម៉ូលេគុល មេរៀនអគ្គិសនីវិភាគត្រង់បាតុភូតតង់ស្យុងលើស មេរៀន កម្លាំងអន្តរកម្មម៉ូលេគុល ទំហំភាគល្អិត និងទ្រង់ទ្រាយ ចំនួនអុកស៊ីតកម្មអាគុយនិងថ្មពិលក្នុង មជ្ឈដ្ឋាន បាស ថ្នាក់ទី១២ មេរៀនអន្តរម៉ូលេគុល កាបូអ៊ីដ្រាតនិងលីពីតសមាសធាតុប្រហើរ។ មុខវិជ្ជារូប វិទ្យាថ្នាក់ទី១១ មេរៀនរលក និងមេរៀនការរីកនៃអង្គធាតុរាវ ថ្នាក់ទី១២មេរៀនអាំងទែផេរ៉ង់ និងឌីប្រាក់ស្យុង។ មុខវិជ្ជាគណិតវិទ្យាថ្នាក់ទី១០មេរៀនតក្កវិទ្យា ថ្នាក់ទី១១ មេរៀនស្វ៊ីត ថ្នាក់ទី១២មេរៀនដេរីវេ សមីការ ឌីផេរ៉ង់ស្យែលនិងប្រូបាប។ មុខវិជ្ជាផែនដីវិទ្យាថ្នាក់ទី១០ មេរៀនបឹងទន្លេសាប ថ្នាក់ទី១១ មេរៀនសម្ពាធបរិយាកាស សម្ពាធខ្ពស់ និងសម្ពាធទាបតាមរដូវចលនាដើរថយក្រោយរបស់ភពថ្នាក់ទី១២ មេរៀនព្រះអា ទិត្យ សំណាល់ (៣) មានខ្លឹមសារមេរៀនវែងតែម៉ោងតិច ឧ.មុខវិជ្ជាជីវវិទ្យាថ្នាក់ទី១០ មេរៀនផ្សិត ថ្នាក់ទី១១ មេរៀនកំណ កោសិកាបន្តពូជ ប្រដាប់បញ្ចេញចោល ប្រដាប់របត់ឈាម ថ្នាក់ទី១២មេរៀន ប្រព័ន្ធ

អង់ដូគ្រីន។ មុខវិជ្ជាគណិតវិទ្យាថ្នាក់ទី១០ មេរៀនធរណីមាត្រជាដើម (៤) មានការលំបាកក្នុងការប្រើប្រាស់វិធីសាស្ត្រថ្មីៗ ដោយសារសៀវភៅសិក្សាគោលបច្ចុប្បន្នសរសេររបៀប Content Base។ ការអនុវត្ត វិធីសាស្ត្របង្រៀនថ្មីធ្វើឱ្យសិស្សរៀនឆាប់ចេះ ព្រោះសិស្សធ្វើសកម្មភាពច្រើនជាងគ្រូតែត្រូវការពេលវេលា។ ដូច្នេះ បើអនុវត្តវិធីសាស្ត្របង្រៀនថ្មី ការបង្រៀនគឺមិនទាន់កម្មវិធី។

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានប្រើប្រាស់គោលវិធីចម្រុះដោយបញ្ចូលគ្នារវាងវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យផង និងគុណវិស័យផង ។ គោលវិធីនេះប្រើប្រាស់ការវិភាគ បែបប្រមូលផ្តុំគំនិត។

## ៣.២.វិធីសាស្ត្រនៃការប្រមូលទិន្នន័យ

វិធីសាស្ត្រនៃការប្រមូលទិន្នន័យ គឺប្រើវិធីសាស្ត្រតាមបែបគុណវិស័យ ហើយត្រូវបានសង្ខេបតាមដំណាក់កាលនីមួយៗ។ ដើម្បីឱ្យការស្រាវជ្រាវនេះទទួលបានជោគជ័យទាមទារឱ្យព័ត៌មាន និងទិន្នន័យប្រមូលបានមានប្រភពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយពោលគឺត្រូវ៖ (១) រៀបចំកម្រងសំណួរដើម្បី សម្ភាសន៍ជាមួយគណៈគ្រប់គ្រងសាលារៀនចំនួន១៣នាក់ ជាមួយលោកគ្រូ អ្នកគ្រូចំនួន ១៩៥នាក់ដែលកំពុងបង្រៀនគ្រប់មុខវិជ្ជានៅកម្រិតទុតិយភូមិក្នុងវិទ្យាល័យចំនួន៤ ក្នុងខេត្តព្រៃវែងគឺវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន កំពង់លាវ វិទ្យាល័យ បាភ្នំ វិទ្យាល័យ ជា ស៊ីមរក្សជ័យ និងវិទ្យាល័យបឹងព្រះ ដើម្បីធ្វើជាសំណាកគម្រូ។ ការជ្រើសរើសអ្នកចូលរួមផ្តល់ចម្លើយគឺធ្វើឡើងតាមរយៈការស្ម័គ្រចិត្ត (២) ធ្វើការស្វែងរកឯកសារដែលមានស្រាប់ដូចជាក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសបោះពុម្ពឆ្នាំ២០១៦ គោល-នយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩ គោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ឯកសារដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សា ដែលបោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា កិច្ចការស្រាវជ្រាវនិងសៀវភៅដែលរៀបរៀងដោយអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិព្រមទាំងឯកសារដែលមាននៅក្នុងគេហទំព័ររបស់ក្រសួង និងគេហទំព័រផ្សេងៗទៀត។

## ៣.៣. ការបង្កើតកម្រងសំណួរ

កម្រងសំណួរមួយចំនួន ត្រូវបានបង្កើតសម្រាប់ប្រមូលទិន្នន័យនេះ ដោយផ្អែកលើគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សាគោល កម្មវិធីសិក្សាលម្អិត និងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា។

# ៣.៤. កម្រងសំណួរ និងគោលបំណង

ផ្នែកទី១ ព័ត៌មានទូទៅរបស់អ្នកផ្តល់ចម្លើយមានដូចជាភេទ ស្រុក ឈ្មោះសាលា ឋានៈតួនាទី កម្រិតវប្បធម៌ មុខវិជ្ជាឯកទេស។ផ្នែកទី២ ចំណេះដឹង និងទស្សនៈទាក់ទងទៅនឹងកម្មវិធីសិក្សា មានដូចជាកម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត ចំណុចអវិជ្ជមានបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សាថ្មី កម្មវិធីសិក្សាចាស់ និងមធ្យោបាយក្នុងការដោះស្រាយ ព្រមទាំងមតិយោបល់ក្នុងការចូលរួមអភិវឌ្ឍន៍កម្មវិធីសិក្សាលើកក្រោយឱ្យបានល្អ។

## ៣.៥ ដំណើរការនៃការជ្រើសរើសនិងវិភាគសំណាក

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងនៅក្នុងវិទ្យាល័យចំនួន៤ គឺវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន កំពង់លាវ ស្ថិតក្នុងក្រុងព្រៃវែង ខេត្តព្រៃវែង វិទ្យាល័យបាភ្នំ ស្ថិតក្នុងស្រុក បាភ្នំ ខេត្តព្រៃវែង និងវិទ្យាល័យ បឹងព្រះ ស្ថិតក្នុងឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង និងវិទ្យាល័យ ជា ស៊ីម រក្សជ័យ ស្ថិតក្នុងឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង មានគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀន នៅកម្រិតមធ្យមសិក្សាទុតិយភូមិចូលរួមផ្តល់ការសម្ភាសន៍សរុបមានចំនួន ១៥៨នាក់។

**តារាងសំណាកទី១ ៖ អ្នកចូលរួមសម្ភាសន៍និងបំពេញកម្រងសំណួរ**

| អ្នកចូលរួមសម្ភាសន៍និងបំពេញកម្រងសំណួរ | វិ.កំពង់លាវ | វិ.បាភ្នំ | វិ. បឹងព្រះ | វិ. រក្សជ័យ | សរុប |
|---|---|---|---|---|---|
| គណៈគ្រប់គ្រង | ៣នាក់ | ៤នាក់ | ៣នាក់ | ៣នាក់ | ១៣នាក់ |
| គ្រូបង្រៀន (ទី១០ ១១ ១២) | ៤០នាក់ | ៤០នាក់ | ៣០នាក់ | ៣៥នាក់ | ១៤៥នាក់ |

**តារាងទី២ ៖ សំណាកគិតតាមតួនាទី ភេទ និងភាគរយ**

| អ្នកចូលរួមផ្តល់ការសម្ភាស | ភេទ | ចំនួន | ភាគរយ |
|---|---|---|---|
| គណៈគ្រប់គ្រងសាលារៀន | ប្រុស | ១២ | ៧.៥៩ % |
| | ស្រី | ០១ | ០.៦៣ % |
| គ្រូបង្រៀនកម្រិតទុតិយភូមិ | ប្រុស | ៩១ | ៥៧.៥៩ % |
| | ស្រី | ៥៤ | ៣៤.១៧ % |
| សរុប | ប្រុស | ១០៣ | ៦៥.១៩ % |
| | ស្រី | ៥៥ | ៣៤.៨១ % |

## ៣.៦.សង្ខេបដំណើរការស្រាវជ្រាវ

ក្រោយពីការសិក្សាស្រាវជ្រាវពីបញ្ហា និងឯកសារសំខាន់ៗដែលពាក់ព័ន្ធហើយកម្រងសំណួរត្រូវបានបង្កើតឡើង និងអនុវត្តសាកល្បងចំនួនពីរដង ហើយត្រូវបានកែសម្រួលដោយសាស្ត្រាចារ្យណែនាំមុននឹងដាក់អនុវត្តជាផ្លូវការ។ អ្នកស្រាវជ្រាវបានព្យាយាមសុំជួបគណៈគ្រប់គ្រងសាលារៀនទាំងបួនសាលាដើម្បីសុំស្ថិតិចំនួនគ្រូ កាលវិភាគ ឬសេវាបង្រៀន ប្រចាំសប្តាហ៍ និងព័ត៌មានផ្សេងៗសម្រាប់ងាយស្រួលទំនាក់ទំនងទៅកាន់លោកគ្រូ អ្នកគ្រូ ដែលបង្រៀនថ្នាក់ទី ១០ ១១ ១២ គ្រប់មុខវិជ្ជាទាំងអស់ និងសុំណាត់ជួបធ្វើការសម្ភាសនិងបំពេញកម្រងសំណួរ ដោយរៀបរាប់ពីគោលបំណង សារៈប្រយោជន៍នៃការចូលរួម ក្នុងការផ្តល់ ចម្លើយ ប្រសិនបើលោកគ្រូ អ្នកគ្រូយល់ព្រមទទួលការសម្ភាស ទើបអ្នកស្រាវជ្រាវចាប់ផ្តើមធ្វើការសម្ភាស។ លោកគ្រូ អ្នកគ្រូមានសិទ្ធិបដិសេធមិនឆ្លើយនឹងសំណួរដែលខ្លួនមិនចង់ឆ្លើយ ឬគាត់មានសិទ្ធិចាកចេញនៅពេលដែលគាត់ចង់ចាកចេញ។ ដំណើរការនៃការសម្ភាស ចំណាយពេលប្រហែល២០ ទៅ២៥ នាទីសម្រាប់ការសម្ភាសម្នាក់ ឬពីរនាក់ដែលនៅជុំគ្នា ហើយស្រាវជ្រាវត្រូវចំណាយអស់រយៈពេល ២ ខែដើម្បីទទួលបានគ្រប់ចំនួននៃសំណាក។

បន្ទាប់ពីទទួលបានទិន្នន័យគ្រប់គ្រាន់ហើយ អ្នកស្រាវជ្រាវបានចាប់ផ្តើមពិនិត្យមើល និងកត់ត្រាគ្រប់ចម្លើយ និងទស្សនៈទាំងអស់ដើម្បីប្រមូលផ្តុំគំនិត បន្ទាប់មកបង្កើតជាតារាងទិន្នន័យរួចបញ្ចូលទិន្នន័យក្នុងកម្មវិធី Excel ដើម្បីធ្វើលទ្ធផលនោះឱ្យទៅជាភាគរយ ប្រេកង់ ដ្យាក្រាម

ក្រាប បន្ទាប់មកធ្វើការបែងចែក និងវិភាគតាមបែបបរិមាណវិស័យផង និងតាមបែបគុណវិស័យផង រួចទាញសេចក្តីសន្និដ្ឋាន។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤
# លទ្ធផលស្រាវជ្រាវ

## ៤.១ ចំណេះដឹងទាក់ទងទៅនឹងកម្មវិធីសិក្សាថ្មី

**៤.១.១ការផ្តល់និយមន័យចំពោះពាក្យ៖** កម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិតមានដូចខាងក្រោម៖

**តារាងទី ៣៖ ចំណេះដឹងទាក់ទងទៅនឹងកម្មវិធីសិក្សា**

| អ្នកចូលរួមផ្តល់ចម្លើយដល់ការស្រាវជ្រាវ | យល់ច្រើន | | យល់តិចតួច | | យល់ច្រឡំទៅនឹងបំណែងចែកកម្មវិធីសិក្សា | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| គណៈគ្រប់គ្រង | ៦ | ៤៦.១៥ | ៥ | ៣៨.៤៦ | ២ | ១៥.៣៨ |
| គ្រូបង្រៀន | ២៧ | ១៨.៦៦ | ១៨ | ១២.៤១ | ១០០ | ៦៩ |

តាមទិន្នន័យក្នុងតារាងខាងលើបានបង្ហាញថា ក្នុងចំណោមគណៈគ្រប់គ្រង១៣នាក់ និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន១៤៥នាក់ មានគណៈគ្រប់គ្រងតែ៦នាក់ និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិតែ២៧នាក់ប៉ុណ្ណោះ ដែលបានយល់ច្រើនទៅលើនិយមន័យនៃពាក្យកម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត។ ពួកគាត់បានឱ្យនិយមន័យប្រហាក់ប្រហែលគ្នាថា កម្មវិធីសិក្សាគឺជាបណ្តុំមុខវិជ្ជាទាំងឡាយណាដែលដាក់ឱ្យសិស្សានុសិស្សសិក្សារៀនសូត្រ។ស្តង់ដាកម្មវិធីសិក្សាគឺជាសំណុំនៃលទ្ធផលសិក្សា ដែលចែងពីចំណេះដឹង និងបំណិនមូលដ្ឋានសំខាន់បំផុតហើយទាមទារឱ្យសិស្សសម្រេចបាននៅពេលពួកគេបញ្ចប់ដំណាក់កាលសិក្សា ដែលបានកំណត់ណាមួយ។ ចំណែកគណៈគ្រប់គ្រងចំនួន៥នាក់ និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន១៨នាក់ទៀត បានយល់តិចតួច ហើយពួកគាត់បានឱ្យនិយមន័យប្រហាក់ប្រហែលគ្នាដែរថា កម្មវិធីសិក្សាគឺជាគម្រោងផែនការ ដែលកំណត់ដោយ

ក្រសួងអប់រំ យុវជន និងកីឡា មានម៉ោងកំណត់តាមមុខវិជ្ជានីមួយៗ ដើម្បីឱ្យលោកគ្រូ អ្នកគ្រូអនុវត្តនៅតាមសាលាចំណោះទូទៅ។ រីឯ គណៈគ្រប់គ្រងចំនួន២នាក់ និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន១០០នាក់ សរុបចំនួន១០២នាក់ គិតជាភាគរយប្រហែលជា៨៩.៣៨% បានយល់ច្រឡំពាក្យកម្មវិធីសិក្សា ទៅនឹងបំណែងចែកកម្មវិធីសិក្សា ឬសេវាបង្រៀនប្រចាំសប្តាហ៍ ដែលលោកគ្រូ អ្នកគ្រូបង្រៀនក្នុងមួយសប្តាហ៍ មួយខែ ឬមួយឆ្នាំសិក្សា ដោយរៀបរៀងចេញពីសៀវសិក្សាគោល មានន័យថា ពួកគាត់យល់ច្រឡំកម្មវិធីសិក្សា ទៅនឹងតារាងបំណែងចែកកម្មវិធីសិក្សានៅតាមសាលារៀនដែលតម្រូវឱ្យលោកគ្រូ អ្នកគ្រូអនុវត្តតាមក្នុងមួយឆ្នាំៗ។ តារាងកម្មវិធីនេះ រៀបរៀងចេញពីសៀវភៅសិក្សាគោល ដោយយកចំនួនថ្ងៃក្នុងបវេសនកាលទាំងអស់ ដកចំនួនថ្ងៃឈប់សម្រាកជាផ្លូវការចេញ ហើយចំនួនថ្ងៃដែលនៅសល់ ត្រូវយកមកបែងចែកទៅតាមចំនួនជំពូក និងចំនួនមេរៀន ក្នុងសៀវភៅសិក្សាគោល។ ប៉ុន្តែចំនួនជំពូក ឬមេរៀនខ្លះ ត្រូវបានរំលងចោល ប្រសិនបើមានការណែនាំពីមន្ទីរ ឬក្រសួង។

## ៤.១.២ ការបានដឹង និងទទួលបានការផ្សព្វផ្សាយកម្មវិធីសិក្សាថ្មី

**តារាងទិន្នន័យទី ៤**

| អ្នកចូលរួមផ្តល់ចម្លើយដល់ការស្រាវជ្រាវ | បានដឹង និងទទួល | | បានខ្លះៗ | | មិនបាន | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| គណៈគ្រប់គ្រង | ៥ | ៣៨.៤៦ | ១ | ៧.៦៩ | ៧ | ៥៣.៨៤ |
| គ្រូបង្រៀន | ១៥ | ១.០៣ | ២១ | ១៤.៤៨ | ១០៩ | ៧៥.១៧ |

តារាងទី៣ បានបង្ហាញថា ចំនួនគណៈគ្រប់គ្រងដែលបានដឹង និងទទួលបាននូវការផ្សព្វផ្សាយកម្មវិធីសិក្សាថ្មីមាន៥នាក់ ស្មើនឹង៣៨.៨៦% ដឹងតិចតួចមានចំនួន១នាក់ ស្មើនឹង៧.៦៩% មិនបានដឹង និងមិនបានទទួលការផ្សព្វផ្សាយកម្មវិធីសិក្សាថ្មីនេះទាល់តែសោះ មានចំនួន៧នាក់ ស្មើនឹង៥៣.៨៦%។ ដោយឡែក លោកគ្រូ អ្នកគ្រូ ដែលបង្រៀនកម្រិតវិទ្យាល័យទាំង៨វិទ្យាល័យ មានចំនួនសរុប១៤៥នាក់ បានដឹងចំនួនតែ១៥នាក់ ស្មើនឹង១.០៣% បានដឹងតិចតួចចំនួន២១នាក់ ស្មើនឹង១៤.៤៨% និងមិនបានដឹងទាល់តែសោះមានចំនួន១០៩នាក់ ស្មើនឹង៧៥.១៧%។ នេះសបញ្ជាក់ឱ្យឃើញថាគណៈគ្រប់គ្រង និងគ្រូបង្រៀនភាគច្រើន មិនបានទទួលការផ្សព្វ

ផ្សាយពីក្របខណ្ឌកម្មវិធីសិក្សានិងកម្មវិធីសិក្សាលម្អិតថ្មីនោះទេ ទោះក្នុងទម្រង់ផ្លូវការ ឬមិនផ្លូវការក្តី ព្រោះលទ្ធផលនៃចម្លើយ បានបង្ហាញថាមានគណៈគ្រប់គ្រង និងគ្រូឧទ្ទេសតិចតួចបំផុត ដែលបានដឹងពីក្របខណ្ឌកម្មវិធីសិក្សានិងកម្មវិធីសិក្សាលម្អិតថ្មី តាមរយៈFaceBook ឬគេហទំព័ររបស់ក្រសួងអប់រំ យុវជន និងកីឡា គឺមិន បានដឹងតាមរយៈសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលនោះទេ។

ការមិនបានដឹងអំពីក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតថ្មី គឺស្មើនឹងមិនបានដឹងពីនិន្នាការនិងកំណែទម្រង់ថ្មីៗរបស់ប្រទេសជាតិ។នៅពេលមានការកែប្រែកម្មវិធីសិក្សាថ្មី ចំណេះ និងជំនាញក៏ត្រូវឱ្យមានការដុះខាត់ទៅតាមបរិបទថ្មីនេះដែរ។ ដូច្នេះ មធ្យាបាយដែលនាំឱ្យឈានទៅដល់បរិបទថ្មី គឺមានតែការអប់រំ តាមរយៈគ្រូបង្រៀន និងនាយកសាលាប៉ុណ្ណោះ។

## ៤.១.៣ ការធ្លាប់ និងមិនធ្លាប់បានទទួលវគ្គបណ្តុះបណ្តាល កម្មវិធីសិក្សាថ្មី

**តារាងទិន្នន័យទី ៥**

| អ្នកចូលរួមផ្តល់ចម្លើយដល់ការស្រាវជ្រាវ | ធ្លាប់ | | មិនធ្លាប់ | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| គណៈគ្រប់គ្រង | ២ | ១៥.៣៨% | ១១ | ៨៤.៦១% |
| គ្រូបង្រៀន | 0 | 0.00% | ១៩៥ | ១00% |

តារាងទី៥ បានបង្ហាញថាក្នុងចំណោមគណៈគ្រប់គ្រង១៣នាក់ អ្នកធ្លាប់បានទទួលវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីសិក្សាថ្មីចំនួន២នាក់ ស្មើនឹង១៥.៣៨% មិនធ្លាប់សោះមានចំនួន១១នាក់ ស្មើនឹង៨៤.៦១% ហើយគ្រូបង្រៀនកម្រិតវិទ្យាល័យចំនួន១៩៥នាក់ ស្មើនឹង១00% មិនធ្លាប់បានទទួលវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីសិក្សាថ្មីនោះទេ ។ ដូច្នេះ ចំណេះដឹងរបស់ពួកគាត់ទាក់ទងទៅនឹងកម្មវិធីសិក្សាថ្មីគឺនៅមានកម្រិតទាបបំផុត ដែលក្រសួង ឬមន្ទីរគួរពន្លឿនយន្តការនៃការផ្សព្វផ្សាយ ឬបណ្តុះបណ្តាលដល់បុគ្គលិកអប់រំឱ្យបានទាន់ពេលវេលា និងស្របតាមភាពចាំបាច់ ព្រោះចំណេះដឹងពាក់ព័ន្ធនឹងកម្មវិធីសិក្សានេះ មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ត្រូវតែយល់ដឹងពិសេសគ្រូបង្រៀន និងនាយកសាលា។ ពួកគាត់ ជាអ្នកប្រែក្លាយគោលនយោបាយរបស់ជាតិឱ្យទៅជាការពិតនិងអនុវត្តជាក់ស្តែងនៅកម្រិតសាលារៀន ពិសេសដល់សិស្សានុសិស្ស និងនិស្សិតដែលជាទំពាំងស្នងឬស្សីសម្រាប់ការអភិវឌ្ឍសង្គមពុទ្ធិ និងវិបុលភាពក្នុងការសម្រេចផែន

ការរយៈពេលខ្លី មធ្យម និងរយៈពេលវែង ពោលគឺការសម្រេចបាន ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសឧស្សាហកម្មនាឆ្នាំ២០២៥ ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និងទៅជាប្រទេសមានចំណូលខ្ពស់ ឬប្រទេសអភិវឌ្ឍន៍នាឆ្នាំ២០៥០ខាងមុខ។

### ៤.១.៤ ការបែងចែកបណ្តុំមុខវិជ្ជា

**តារាងទិន្នន័យទី ៦**

| អ្នកចូលរួមផ្តល់ចម្លើយដល់ការស្រាវជ្រាវ | ផ្តល់ចម្លើយត្រឹមត្រូវ | | ផ្តល់ចម្លើយខុស | | គ្មានចម្លើយ | |
|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| គណៈគ្រប់គ្រង | ១៣ | ១០០% | 0 | 0.00% | 0 | 0.00% |
| គ្រូបង្រៀន | ១៣៧ | ៩៤.៤៨% | ២ | ១.៣៧% | ៦ | ៤.១៣% |

តារាងទី៦បង្ហាញថា គណៈគ្រប់គ្រងទាំង១៣នាក់ មានចំណេះដឹងលើការបែងចែកបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម។ ចំណែកឯគ្រូបង្រៀន មានតែចំនួន១៣៧នាក់ប៉ុណ្ណោះដែលដឹងថាមានបណ្តុំទាំងពីរនេះ។ ដោយឡែកក៏នៅមានគ្រូបង្រៀនចំនួន៨នាក់ផ្សេងទៀត មិនបានដឹងថាមានបណ្តុំទាំងពីរនេះនៅកម្រិតមធ្យមសិក្សាទុតិយភូមិនោះទេ។ លទ្ធផលនេះបញ្ជាក់ថា គណៈគ្រប់គ្រង និងគ្រូបង្រៀនបានដឹងពីការចែកបណ្តុំវិទ្យាសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

### ៤.១.៥ ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងនិងគ្រូបង្រៀនលើការបែងចែកបណ្តុំមុខវិជ្ជា

**តារាងទិន្នន័យទី ៧**

| អ្នកចូលរួមផ្តល់ចម្លើយដល់ការស្រាវជ្រាវ | ល្អ | | មិនល្អ | | គុណសម្បត្តិខ្លះ គុណវិបត្តិខ្លះ | | មិនដឹង | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១៥៨ នាក់ | ១១៣ | ៧១.៥១ | ៣៦ | ២២.៧៨ | ៣ | ១.៩០ | ៦ | ៣.៨០ |

តារាងទី៧ បង្ហាញពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងនិងគ្រូបង្រៀនលើការបែងចែកបណ្តុំមុខវិជ្ជានៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ក្នុងចំណោមគណៈគ្រប់គ្រង និងគ្រូបង្រៀន

ចំនួន១៥៨នាក់ អ្នកដែលមានទស្សនៈយល់ឃើញថា ការបែងចែកបណ្ដុំមុខវិជ្ជានេះគឺជាការល្អ មានចំនួន១១៣នាក់ ស្មើនឹង៧១.៥១% ព្រោះពួកគាត់យល់ឃើញថា ការបែងចែកបណ្ដុំមុខវិជ្ជានេះធ្វើឱ្យសិស្សជ្រើសរើសមុខវិជ្ជាដែលខ្លួនចូលចិត្ត ហើយមានពេលវេលាច្រើនសម្រាប់ខិតខំប្រឹងប្រែងរៀនសូត្រលើមុខវិជ្ជាដែលខ្លួនបានជ្រើសរើស។ ទន្ទឹមនឹងនោះ ក៏មានគណៈគ្រប់គ្រងនិងគ្រូបង្រៀនចំនួន៣៦ នាក់ផ្សេងទៀតដែរដែលមានទស្សនៈថាមិនល្អ ព្រោះសិស្សមិនសូវខិតខំសិក្សាលើមុខវិជ្ជាក្រៅពីបណ្ដុំមុខវិជ្ជាដែលពួកគេបានជ្រើសរើស។ ដោយឡែកក៏មានគណៈគ្រប់គ្រងនិងគ្រូបង្រៀនចំនួន៣នាក់ដែរដែលមានទស្សនៈថា ការបែងចែកនេះ មានគុណសម្បត្តិផងនិងគុណវិបត្តិផង ព្រោះសិស្សមួយចំនួនធំជ្រើសរើសមុខវិជ្ជាតាមចំណង់ចំណូលចិត្ត ហើយខិតខំរៀនសូត្រ ឯសិស្សខ្លះទៀតជ្រើសរើសតាមមិត្តភក្តិ មិនមានការពិចារណាត្រឹមត្រូវ រួចពេលមានការលំបាកក្នុងការសិក្សា នាំឱ្យមានការបោះបង់ការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ និងចំនួន ៦ នាក់ទៀតស្មើនឹង ៣.៨០% មិនមានទស្សនៈថា ល្អ ឬមិនល្អនោះទេ ព្រោះកម្មវិធីសិក្សាថ្មីនេះមិនទាន់បានអនុវត្តផង។

៤.១.៦ ទស្សនៈយល់ឃើញលើការអនុវត្តម៉ោងសិក្សាលើកម្មវិធីសិក្សាថ្មី

**តារាងទិន្នន័យទី ៨**

| អ្នកចូលរួមផ្ដល់ចម្លើយដល់ការស្រាវជ្រាវ | អនុវត្តបាន (+) | | អនុវត្តមិនបាន (-) | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១៥៨ នាក់ | ៨៧ | ៥៥.០៦% | ៧១ | ៤៤.៩៤% |

តារាងទី៨បង្ហាញពីទស្សនៈយល់ឃើញរបស់អ្នកចូលរួមផ្ដល់ចម្លើយដល់ការស្រាវជ្រាវក្នុងការអនុវត្តម៉ោងសិក្សាលើកម្មវិធីសិក្សាថ្មី។ ក្នុងចំណោមអ្នកផ្ដល់ចម្លើយចំនួន១៥៨ នាក់ មាន៨៧ នាក់ស្មើនឹង៥៥.០៦% មានទស្សនៈថា អនុវត្តបាន និងមានចំណុចវិជ្ជមានច្រើន ដោយសារតែសាលារៀនរបស់ពួកគាត់មានទីតាំងស្ថិតនៅទីប្រជុំជន ក្នុងទីរួមស្រុក និងខេត្ត ហើយមានបន្ទប់រៀនគ្រប់គ្រាន់ ហើយក៏មានគ្រូតាមមុខវិជ្ជាច្រើន។ ដូច្នេះ ការបង្រៀន៤០ម៉ោងសិក្សា ក្នុង១សប្ដាហ៍ដូចមានចែងនៅក្នុងក្របខណ្ឌកម្មវិធីសិក្សាថ្មីនោះ នឹងនាំឱ្យគុណភាពនៃការសិក្សាមានការកើនឡើង ឬអាចនិយាយម្យ៉ាងទៀតថា លទ្ធផលនៃការសិក្សារបស់សិស្សនឹងកើនឡើង ព្រោះគ្រូបង្រៀនមានពេលវេលាច្រើនដើម្បីពង្រឹងពុទ្ធិសិស្សហើយការបង្រៀនអាចចប់កម្មវិធិសិក្សាដោយ

រលួន។ ទោះជាយ៉ាងនេះក្តីក៏មានអ្នកផ្តល់ចម្លើយដល់ការស្រាវជ្រាវនេះចំនួន ៧១នាក់ ស្មើនឹង ៤៤.៩៤% មានទស្សនៈថា អនុវត្តមិនបានដែរ ព្រោះសាលារៀន របស់ពួកគាត់ មានទីតាំងស្ថិតនៅទីជនបទ មិនមានបន្ទប់រៀននិងគ្រូតាមឯកទេសគ្រប់គ្រាន់ទេ។ មុខវិជ្ជាខ្លះលើសគ្រូ មុខវិជ្ជាខ្លះខ្វះគ្រូ ជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រពិតគឺខ្វះគ្រូច្រើន ដោយសារតែគ្រូមុខវិជ្ជានេះភាគច្រើនគាត់ទៅបង្រៀនតែនៅទីប្រជុំជន ទីរួមស្រុក ឬទីរួមខេត្ត។ ដូចនេះដើម្បីអនុវត្តកម្មវិធីសិក្សាថ្មីប្រកបដោយគុណភាព លុះត្រាតែក្រសួងឬមន្ទីរត្រូវផ្តល់អគាសិក្សាឱ្យបានគ្រប់គ្រាន់គ្រប់ទីកន្លែងពិសេសនៅទីជនបទ ត្រូវពង្រាយគ្រូ ឬបែងចែកគ្រូឱ្យគ្រប់ឯកទេសដល់សាលានៅទីជនបទ កុំនៅផ្តុំច្រើនតែក្នុងទីប្រជុំជន ធ្វើឱ្យការបង្រៀនមិនមានភាពស្មើគ្នា។ តាមការជាក់ស្តែង ក្នុងពេលបច្ចុប្បន្ននេះ លោកគ្រូ អ្នកគ្រូនៅទីប្រជុំជនខ្លះបង្រៀនតែ៣ ទៅ៦ ម៉ោងទេ ក្នុងមួយសប្តាហ៍ តែលោកគ្រូ អ្នកគ្រូនៅទីជនបទ បង្រៀនពី១៦ ទៅ១៨ម៉ោង ឬលើសពីនេះ ទៅទៀតក្នុងមួយសប្តាហ៍ហើយប្រាក់ខែទទួលបានដូចគ្នា។ករណីនេះហើយ ដែលធ្វើឱ្យគ្រូនៅទីប្រជុំជនមានពេលច្រើនធ្វើការផ្សេង និងបង្រៀនឯកជនច្រើន មិនសូវយកចិត្តទុកដាក់ក្នុងម៉ោងរដ្ឋ រីឯ លោកគ្រូ អ្នកគ្រូនៅទីជនបទមិនសូវមានទឹកចិត្តក្នុងការបង្រៀនឈ្លៀតតែធ្វើកិច្ចការផ្ទះ។ កត្តាទាំងអស់នេះហើយដែលធ្វើឱ្យគុណភាពនៃការអប់រំនៅមានកម្រិត។

៤.១.៧ មូលហេតុនៃការពេញចិត្ត ឬមិនពេញចិត្តកម្មវិធីសិក្សាថ្មី

**តារាងទិន្នន័យទី៩**

| អ្នកផ្តល់ការសម្ភាស | ពេញចិត្ត | | មិនពេញចិត្ត | | មិនដឹង | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| គណៈគ្រប់គ្រង | ១៣ | ១០០% | ០ | ០.០០% | ០ | ០.០០% |
| លោកគ្រូ អ្នកគ្រូ | ៩៤ | ៦៤.៨២% | ៤៧ | ៣២.៤១% | ៤ | ២.៧៦% |

តាមតារាងទិន្នន័យខាងលើបានបង្ហាញថា ក្នុងចំណោមអ្នកចូលរួមផ្តល់ការសម្ភាសទាំងអស់ មានគណៈគ្រប់គ្រងចំនួន ១៣នាក់ ស្មើនឹង ១០០% គ្រូបង្រៀនចំនួន ៩៤ នាក់ស្មើនឹង ៦៤.៩២% ឆ្លើយថា ពេញចិត្តកម្មវិធីសិក្សាថ្មី ព្រោះមានចំនួនម៉ោងច្រើនជាងមុន ធ្វើឱ្យការបង្រៀននិងរៀនបានច្រើនជាងមុនដែរ មានការបែងចែកបណ្តុំមុខវិជ្ជា ធ្វើឱ្យសិស្សជ្រើសរើសត្រូវតាមចំណង់ចំណូលចិត្ត និងនាំឱ្យមានការខិត្តខំសិក្សារៀនសូត្រច្រើនលើបណ្តុំមុខវិជ្ជាដែល ខ្លួនបាន

ជ្រើសរើស។ ដោយឡែក លោកគ្រូ អ្នកគ្រូចំនួន ៤៧ នាក់ទៀតស្មើនឹង ៣២.៤១% មានទស្សនៈថា មិនពេញចិត្ត ព្រោះចំនួនម៉ោងបង្រៀនរហូត ដល់៤០ម៉ោងក្នុងមួយសប្តាហ៍ ច្រើនពេកគ្មានពេលធ្វើការងារក្រៅ ឬបង្រៀនគួរក្រៅទេ រីឯលោកគ្រូ អ្នកគ្រូចំនួន ៤ នាក់ទៀត ស្មើនឹង ២.៧៦% មិនមានចម្លើយទេគឺមិនដឹង។

## ៤.២.បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីសិក្សា

លោកគ្រូ អ្នកគ្រូស្ទើរតែទាំងអស់យល់ឃើញថា ការអនុវត្តកម្មវិធីសិក្សា ប្រកបដោយប្រសិទ្ធភាពគឺសំដៅលើការបង្រៀនឱ្យចប់បំណែងចែកមេរៀនដែលត្រូវបង្រៀនប្រចាំសប្តាហ៍ ខែ ឆ្នាំហើយឱ្យសិស្សមានគុណភាពទៀតគឺមានន័យថាសិស្សទទួលបានលទ្ធផលសិក្សាល្អ។ លោកគ្រូ អ្នកគ្រូដែលចូលរួមផ្តល់ចម្លើយ ពួកគាត់កំពុងតែប្រើសៀវភៅសិក្សាគោលដែល បោះពុម្ពពីឆ្នាំ២០១០ រហូតដល់២០១៦ លើកលែងតែមុខវិជ្ជាភាសាបរទេសទេដែលបោះពុម្ពនៅអំឡុងឆ្នាំ ១៩៩៩-២០០០។ លោកគ្រូ អ្នកគ្រូបានលើកឡើងថា ពួកគាត់មិនអាច អនុវត្ត កម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពទេ ព្រោះគាត់មានការលំបាកមួយចំនួនដូចជា៖

### ៤.២.១ មុខវិជ្ជាគណិតវិទ្យា

សមត្ថភាពសិស្សនៅមានកម្រិត មានន័យថាសិស្សគ្មានមូលដ្ឋានគ្រឹះគ្រប់គ្រាន់ ឬសមត្ថភាពមិនស្មើនឹងកម្រិតថ្នាក់ដែលកំពុងរៀន សិស្សច្រើនពេកនៅក្នុងថ្នាក់រៀនលើសពី៤៥នាក់ ចំនួនមេរៀននៅក្នុងសៀវភៅសិក្សាគោលច្រើនពេកមិនសមមាត្រទៅនឹងម៉ោងបង្រៀន និងមិនមានភាពទាក់ទាញ ហើយមានបញ្ហាជាច្រើនទៀតដូចជា មេរៀននីមួយៗមានវត្ថុបំណងមិនច្បាស់លាស់ លំហាត់ដែលដាក់នៅក្នុងសៀវភៅសិស្សមានកំហុសច្រើន និងកំណែនៅក្នុងសៀវភៅគ្រូក៏មានកំហុសឆ្គងច្រើនដែរ។ លំហាត់មិនសូវស៊ីជាមួយមេរៀន ខ្លឹមសារមេរៀននៅក្នុងសៀវភៅខ្លះមិនសូវល្អ គឺសម្រាយច្រើនពេកចំពោះចំណុចដែលមិនចាំបាច់ មេរៀនខ្លះមានកម្រិតខ្ពស់ជាងសមត្ថភាពសិស្ស និងមានភាពស្មុគស្មាញសូម្បីតែគ្រូបង្រៀនក៏មិនសូវយល់ដែរ (ឧ. គណិតវិទ្យាទី១២ ភាគ២) នៅក្នុងសៀវភៅគ្រូលំហាត់ដែលលំបាកអត់មានកំណែ និងខ្វះខាតសម្ភារៈឧបទ្ទេស។

### ៤.២.២ មុខវិជ្ជាភាសាបរទេស

បរិមាណសិស្សច្រើនពេកពិបាកគ្រប់គ្រង និងបែងចែកជាក្រុម សិស្សភាគច្រើនមិនមានមូលដ្ឋានគ្រឹះសម្រាប់ភាសាបរទេស និងមានសមត្ថភាពខុសគ្នានៅក្នុងថ្នាក់តែមួយនាំឱ្យពិបាកក្នុងការបង្រៀន ខ្វះគ្រូឯកទេសច្រើនព្រោះម៉ោងសិក្សា៦ម៉ោងក្នុងមួយសប្ដាហ៍ ខ្វះខាតសម្ភារៈឧបទ្ទេសដូចជាកាសែតសម្រាប់ឱ្យសិស្សស្ដាប់ ប្រើក្នុងបំណិនស្ដាប់

### ៤.២.៣ មុខវិជ្ជាភាសាខ្មែរ

ខ្វះខាតសម្ភារឧបទេស និងឯកសារយោង ឬពិបាកយកមកប្រើប្រាស់ខ្វះខាតសៀវភៅសិក្សាគោលសម្រាប់សិស្ស ខ្លឹមសារលំអៀងលើសំណួរដដែល មានការកែតម្រូវ ឬប្រែប្រួលដោយគ្មានឯកសារយោងច្បាស់លាស់ លំដាប់មេរៀនមិនស៊ីទៅនឹងខ្លឹមសារបំណិន (ឧ. មេរៀនកំណាព្យ បែរជាខ្លឹមសារមេរៀនជាអត្ថបទទៅវិញ)។ ខ្លឹមសារមេរៀនច្រំដែល ខុសអក្ខរាវិរុទ្ធវត្ថុបំណងមេរៀន មិនស៊ីជាមួយខ្លឹមសារ ឆ្នាំនិពន្ធរឿងខុសៗគ្នា (ឧ. មាលាដួងចិត្ត) ខ្លឹមសារមេរៀនមិនទាន់សម័យ មានកំហុសឆ្គងវេយ្យាករណ៍ លំដាប់លំដោយមេរៀនមិនត្រឹមត្រូវ បំណិនមានច្រើនតែសំណេរ មិនសូវមានការអាន និយាយ និងស្ដាប់ឡើយ។

### ៤.២.៤ មុខវិជ្ជារូបវិទ្យា

ម៉ោងតិចតែមេរៀនច្រើន។ សៀវភៅសិក្សាគោលខុសរូបមន្ត លំហាត់ខុស ខ្លឹមសារមេរៀនច្រំដែល និងខុសអក្ខរាវិរុទ្ធ។

### ៤.២.៥ មុខវិជ្ជាគីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យានិងបរិស្ថាន

សមត្ថភាពសិស្សមិនសមស្រប ទៅនឹងកម្រិតថ្នាក់ដែលកំពុងរៀន។កម្រិតសមត្ថភាពសិស្សខុសគ្នាខ្លាំងនៅក្នុងថ្នាក់រៀនតែមួយ។ សិស្សមិនយល់ពីសារសំខាន់ នៃមុខវិជ្ជាទាំងនេះ ។ ខ្វះសម្ភារៈពិសោធន៍ ឬពិបាកក្នុងការយកមកប្រើប្រាស់។

### ៤.២.៦ មុខវិជ្ជាភូមិវិទ្យា

សិស្សច្រើនពេក ហើយភាគច្រើនមិនយកចិត្តទុកដាក់សិក្សាមុខវិជ្ជានេះ ព្រោះមិនចេញនៅក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ខ្លឹមសារមេរៀនមិនទាក់ទងនឹងកត្តាជីវភាពរស់នៅប្រចាំថ្ងៃ។

### ៤.២.៧ មុខវិជ្ជាប្រវត្តិវិទ្យា

បញ្ហាសៀវភៅគោលខុសច្រើន ពិសេសប្រវត្តិសាស្ត្រខ្មែរ។ ខ្លឹមសារមេរៀនច្រំដែលមាន ខ្លះកាត់ពេកបាត់ខ្លឹមសារ និងខ្លឹមសារមេរៀនខ្លះមិនស៊ីទៅនឹងចំណងជើងមេរៀន កំហុសឆ្នាំក្នុង មេរៀន។

### ៤.២.៨ មុខវិជ្ជាសីលធម៌ពលរដ្ឋ

មេរៀនខ្លះមិនសំខាន់និងមានកម្រិតទាបជាងសិស្សពេក (ថ្នាក់ទី១០)។ មេរៀនខ្លះខ្ពស់ ជាងកម្រិតសិស្សថ្នាក់ទី១២ ហើយសៀវភៅគ្មានសទ្ទានុក្រម។

### ៤.២.៩មុខវិជ្ជាគេហកិច្ច

មិនចាំបាច់ព្រោះមិនប្រឡង ខ្វះសម្ភារៈពិសោធន៍ ឬពិបាកក្នុងការយកមកប្រើប្រាស់។

# ជំពូកទី៥៖

## សេចក្តីសន្និដ្ឋាន និង សំណូមពរ

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និង សំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

កម្មវិធីសិក្សាគឺជាកត្តាមួយសំខាន់ ក្នុងការចូលរួមចំណែកកសាងធនធានមនុស្ស ប្រកបដោយគុណភាព និងភាពឆ្លើយតប។ ប៉ុន្តែទោះបីជាកម្មវិធីសិក្សាល្អប៉ុនណាក៏ដោយ បើលោកគ្រូ អ្នកគ្រូ ដែលជាបុគ្គលសំខាន់ក្នុងការអនុវត្តកម្មវិធីសិក្សានៅក្នុងថ្នាក់រៀន មិនមានចំណេះដឹងស៊ីជម្រៅលើកម្មវិធីសិក្សានោះទេ ពួកគាត់នឹងមិនអាចអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពបានឡើយ ព្រោះក្នុងដំណើរការនៃការផ្តល់ចំណេះដឹងតាមមុខវិជ្ជានីមួយៗដល់សិស្ស គ្រូមិនត្រឹមតែផ្អែកលើចំណេះដឹង និងបទពិសោធន៍ ដែលគាត់មានប៉ុណ្ណោះទេ ប៉ុន្តែគាត់ត្រូវអនុវត្តតាមកម្មវិធីសិក្សាដែលបានផ្តល់ដោយក្រសួងអប់រំយុវជន និងកីឡា ដើម្បីរៀបចំយុទ្ធសាស្ត្រវិធីបង្រៀន សម្ភារឧបទេសសម្រាប់ដំណើរការបង្រៀន និងការវាយតម្លៃសមត្ថភាពសិស្សធៀបទៅនឹងស្តង់ដាដែលបានកំណត់រួចជាស្រេចទៀតផង ដើម្បីឆ្លើយតបទៅនឹងបញ្ញត្តិកម្មវិធីសិក្សាប្រកបដោយជោគជ័យ និងប្រសិទ្ធភាព។ នៅក្នុងប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា កម្មវិធីសិក្សាគោល ស្តង់ដារកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត ដល់មន្ត្រីជាន់ខ្ពស់ថ្នាក់ជាតិ ថ្នាក់មន្ទីរ គ្រូបង្គោល និងគ្រូប្រធានក្រុមបច្ចេកទេសមួយចំនួនព្រមទាំងបានបោះពុម្ពផ្សាយឯកសារទាំងនោះផងដែរ។ គ្រូបង្រៀនជា អ្នកអនុវត្តកម្មវិធីសិក្សានៅក្នុងថ្នាក់រៀន ត្រូវបានផ្តល់ជូននូវសៀវភៅគ្រូ សៀវភៅសិស្ស សម្ភារឧបទេស និងការគាំទ្រពីប្រធានក្រុមបច្ចេកទេស។ ដូចនេះការស្រាវជ្រាវចង់រកឱ្យឃើញពី (១) ចំណេះដឹងរបស់អ្នកអនុវត្តក្របខណ្ឌកម្មវិធីសិក្សា (២) ទស្សនៈយល់ឃើញពីការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅថ្មីដែលក្រសួងអប់រំ យុវជន និងកីឡា ដាក់ឱ្យអនុវត្ត (៣) ចំណុចវិជ្ជមាន និងបញ្ហាប្រឈមនៅពេលអនុវត្តកម្មវិធីសិក្សាថ្មីនេះ ព្រមទាំងមធ្យោបាយក្នុងការដោះស្រាយ ហើយការសិក្សាស្រាវជ្រាវនេះគឺមិនផ្អែកទៅលើភេទ ឋានៈតួនាទី មុខវិជ្ជាឯកទេស កម្រិតវប្បធម៌ និងបទពិសោធក្នុងការគ្រប់គ្រង ការបង្រៀនរបស់ពួកគាត់ឡើយ។

ការសិក្សាស្រាវជ្រាវនេះធ្វើការសម្ភាសន៍ជាមួយ គណៈគ្រប់គ្រងចំនួន **១៣នាក់** លោកគ្រូអ្នកគ្រូចំនួន **១៤៥ នាក់ សរុបមានចំនួន ១៥៨ នាក់**។ក្នុងចំណោមគណៈគ្រប់គ្រង និងលោកគ្រូអ្នកគ្រូទាំងអស់នោះគឺពួកគាត់កំពុងគ្រប់គ្រង និងបង្រៀននៅកម្រិតវិទ្យាល័យលើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ភូមិវិទ្យា ផែនដីវិទ្យា ភាសាខ្មែរ គេហវិទ្យា សីលធម៌ពលរដ្ឋវិទ្យា ប្រវត្តិវិទ្យា និង ភាសាបរទេសនៅក្នុងវិទ្យាល័យចំនួនបួន ក្នុងខេត្តព្រៃវែង គឺ វិទ្យាល័យបឹងព្រះ វិទ្យាល័យជា ស៊ីម រក្សជ័យ ដែលជាវិទ្យាល័យស្ថិតនៅទីជនបទ វិទ្យាល័យ បាភ្នំស្ថិតនៅទីប្រជុំជនស្រុក និងវិទ្យាល័យ សម្តេចតេជោ ហ៊ុន សែន កំពង់លាវស្ថិតនៅទីប្រជុំជនខេត្ត/ក្រុង។ទិន្នន័យបែបបរិមាណវិស័យគឺសំដៅទៅលើចំណេះដឹងរបស់លោកគ្រូ អ្នកគ្រូស្តីកម្មវិធីសិក្សា ចំណែកឯគុណវិស័យគឺទស្សនៈ យោបល់និងតម្រូវការរបស់លោកគ្រូអ្នកគ្រូក្នុងការអនុវត្តកម្មវិធីសិក្សាថ្មី។

ជាការសន្និដ្ឋានសម្រាប់កិច្ចការស្រាវជ្រាវលើប្រធានបទនេះ អ្នកស្រាវជ្រាវបានរកឃើញដូចតទៅ៖

## ៥.១.១ ចំណេះដឹងទាក់ទងនឹងកម្មវិធីសិក្សា

មានគណៈគ្រប់គ្រងចំនួន៦នាក់ស្មើនឹង៤៦.១៥% និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន២៧នាក់ស្មើនឹង១៨.៦៦%ប៉ុណ្ណោះ ដែលបានយល់ច្រើនទៅលើនិយមន័យនៃពាក្យកម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត។ ពួកគាត់បានឱ្យនិយមន័យប្រហាក់ប្រហែលគ្នាថា កម្មវិធីសិក្សាគឺជាបណ្តុំមុខវិជ្ជាទាំងឡាយណាដែលដាក់ឱ្យសិស្សានុសិស្សសិក្សារៀនសូត្រ។ស្តង់ដាកម្មវិធីសិក្សាគឺជាសំណុំនៃលទ្ធផលសិក្សា ដែលចែងពីចំណេះដឹង និងបំណិនមូលដ្ឋានសំខាន់បំផុតហើយទាមទារឱ្យសិស្សសម្រេចបាននៅពេលពួកគេបញ្ចប់ដំណាក់កាលសិក្សា ដែលបានកំណត់ណាមួយ។ ចំណែកឯគណៈគ្រប់គ្រងចំនួន៥នាក់ស្មើនឹង៣៨.៤៦% និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន១៨នាក់ស្មើនឹង១២.៤១%ទៀតបានយល់តិចតួចហើយពួកគាត់បានឱ្យនិយមន័យប្រហាក់ប្រហែលគ្នាដែរថា កម្មវិធីសិក្សា គឺជាគម្រោងផែនការ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា មានម៉ោងកំណត់តាមមុខវិជ្ជានីមួយៗ ដើម្បីឱ្យលោកគ្រូ អ្នកគ្រូ អនុវត្តនៅតាមសាលាចំណេះទូទៅ។ រីឯគណៈគ្រប់គ្រងចំនួន២នាក់ និងគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិចំនួន១០០នាក់ សរុបចំនួន១០២នាក់ គិតជាភាគរយប្រហែលជា៨៤.៣៨% បានយល់ច្រឡំពាក្យកម្មវិធីសិក្សា ទៅនឹង

បំណែងចែកកម្មវិធីសិក្សា ឬសេវាបង្រៀនប្រចាំសប្តាហ៍ ដែលលោកគ្រូ អ្នកគ្រូបង្រៀនក្នុងមួយសប្តាហ៍ មួយខែ ឬមួយឆ្នាំសិក្សា ដោយរៀបរៀងចេញពី សៀវសិក្សាគោល មានន័យថា ពួកគាត់យល់ច្រឡំកម្មវិធីសិក្សា ទៅនឹងតារាងបំណែងចែកកម្ម វិធីសិក្សានៅតាមសាលារៀនដែលតម្រូវឱ្យលោកគ្រូ អ្នកគ្រូអនុវត្តតាមក្នុងមួយឆ្នាំៗ។

នេះបង្ហាញថាគណៈគ្រប់គ្រង និងគ្រូបង្រៀនភាគច្រើន គ្មានចំណេះដឹងទាក់ទងទៅនឹងកម្មវិធីសិក្សានោះទេ។ ពួកគាត់ភាគច្រើនយល់ច្រឡំកម្មវិធីសិក្សាទៅនឹងតារាងបំណែងចែកកម្មវិធីសិក្សា នៅតាមសាលារៀនដែលតម្រូវឱ្យលោកគ្រូ អ្នកគ្រូអនុវត្តតាមក្នុងមួយឆ្នាំៗ។ តារាងកម្មវិធីនេះ រៀបរៀងចេញពីសៀវភៅសិក្សាគោល ដោយយកចំនួនថ្ងៃក្នុងបវេសនកាលទាំងអស់ដកចំនួនថ្ងៃ ឈប់សម្រាកជាផ្លូវការចេញ ហើយចំនួនថ្ងៃដែលនៅសល់ ត្រូវយកមកបែងចែកទៅតាមចំនួន ជំពូក និងចំនួនមេរៀននៅក្នុងសៀវភៅសិក្សាគោល។

### ៥.១.២ ទស្សនៈរបស់នាយកសាលានិងគ្រូបង្រៀនលើការបែងចែកបណ្តុំមុខវិជ្ជា និងការអនុវត្ត កម្មវិធីសិក្សា៤0ម៉ោងក្នុងមួយសប្តាហ៍៖

ក្នុងចំណោមចំនួនគណៈគ្រប់គ្រង ១៣ នាក់ពួកគាត់ បានឆ្លើយថា ការបែងចែក បណ្តុំមុខវិជ្ជា ជាពីរផ្នែកគឺ បណ្តុំវិទ្យាសាស្ត្រពិត និងបណ្តុំវិទ្យាសាស្ត្រសង្គម ដែលជាចម្លើយត្រឹមត្រូវមានចំនួន ១៣នាក់ ស្មើនឹង ១០០% ហើយអ្នកដែលផ្តល់ចម្លើយខុសគឺ 0 នាក់ ស្មើនឹង 0.00% រីឯលោកគ្រូ អ្នកគ្រូចំនួន ១៣៧ នាក់ ស្មើនឹង៩៤.៥៨%បានផ្តល់ចម្លើយត្រឹមត្រូវ ២នាក់ ស្មើនឹង ១.៣៧% បានផ្តល់ចម្លើយខុស និង ៦នាក់ទៀតស្មើនឹង ៤.១៥% គ្មានផ្តល់ចម្លើយអ្វីទាំងអស់ និងក្នុងចំណោម គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូដដែលនេះ អ្នកដែលមានទស្សៈយល់ឃើញថាការបែងចែកបណ្តុំមុខវិជ្ជានេះគឺជាការល្អ មានចំនួន ១១៣ នាក់ ស្មើនឹង ៧១.៥១% ហើយតាមការផ្តុំគំនិត ឬទស្សនៈរបស់ពួកគាត់ដែលបានបញ្ចេញដូចគ្នា និងប្រហាក់ប្រហែលគ្នានោះថាការបែងចែកបណ្តុំមុខវិជ្ជានេះធ្វើឱ្យ សិស្សជ្រើសរើសមុខវិជ្ជាដែលខ្លួនចូលចិត្ត ហើយមានពេលវេលាច្រើនសម្រាប់ខិតខំប្រឹងប្រែងរៀនសូត្រលើមុខវិជ្ជាដែលខ្លួនបានជ្រើសរើស ហើយចំនួន៣៦ នាក់ទៀត ស្មើនឹង ២២.៧៨%មានទស្សនៈថា មិនល្អ ព្រោះសិស្សមិនសូវខិតខំសិក្សាលើ មុខវិជ្ជាដែលក្រៅពីបណ្តុំមុខវិជ្ជា ដែលពួកគេជ្រើសរើស។ដោយឡែកចំនួន ៣ នាក់ទៀត ស្មើនឹង ១.៩០% មានទស្សនៈថា ការបែងចែកនេះ មានគុណសម្បត្តិផង និងគុណវិបត្តិផង ព្រោះ សិស្ស

មួយចំនួនធំជ្រើសរើសមុខវិជ្ជាតាមចំណង់ចំណូលចិត្ត ហើយខិតខំរៀនសូត្រ ឯសិស្សខ្លះទៀតជ្រើសរើសតាមមិត្តភក្តិ មិនមានការពិចារណាត្រឹមត្រូវ រួចពេលមានការលំបាកក្នុងការសិក្សានោះនាំឱ្យមានការបោះបង់ការខិតខំប្រឹងប្រែងសិក្សារៀនសូត្រនិងចំនួន ៦ នាក់តៀតស្មើនឹង ៣.៨០% មិនមានទស្សនៈថា ល្អ ឬមិនល្អទេ ព្រោះកម្មវិធីសិក្សាថ្មីនេះមិនទាន់បានអនុវត្តផង និងចំនួន ៨៧នាក់ស្មើនឹង៥៥.០៦% មានទស្សនៈថា អនុវត្តកម្មវិធីសិក្សាថ្មីដែលបង្រៀន និងរៀន ៩០ ម៉ោងក្នុងមួយសប្តាហ៍បាននិងមានចំណុចវិជ្ជមានច្រើន ហើយ៧១នាក់ស្មើនឹង៤៤.៩៤% មានទស្សនៈថាអនុវត្តមិនបាន ។

ដោយឡែកលោកគ្រូ អ្នកគ្រូខ្លះបានបញ្ចេញទស្សនៈថា ការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពគឺសំដៅលើការបញ្ចប់មេរៀន ដែលមាននៅក្នុងសៀវភៅសិក្សាគោល ឬតាមផែនការកំណត់ឱ្យបង្រៀន ហើយសិស្សមានគុណភាព ឬទទួលបានលទ្ធផលល្អទៀត។ ប៉ុន្តែពួកគាត់បានលើកឡើងពីបញ្ហាប្រឈមដែល ពួកគាត់មិនអាចសម្រេចបាននូវអ្វី ដែលពួកគាត់បានលើកឡើងនោះទេ ព្រោះ៖

- សមត្ថភាពសិស្សមិនសមស្របទៅនឹងកម្រិតថ្នាក់ដែលកំពុងរៀន (សិស្សភាគច្រើនខ្សោយគ្មានមូលដ្ឋានគ្រឹះពីថ្នាក់ក្រោម)
- សិស្សមិនយកចិត្តទុកដាក់ និងឱ្យតម្លៃលើការសិក្សា
- ខ្វះខាតសៀវភៅសិក្សាគោលច្រើនលើមុខវិជ្ជាមួយចំនួន
- ចំនួនមេរៀន និងម៉ោងបង្រៀនក្នុងមួយសប្តាហ៍មិនសមស្រប
- សៀវភៅសិក្សាគោលមានការខ្វះចន្លោះច្រើន ចំពោះមុខវិជ្ជាមួយចំនួនដូចជា
  - មានកំហុសអក្ខរាវិរុទ្ធ
  - មានកំហុសឆ្គងលើលំហាត់ និងកំណែលំហាត់
  - ខ្លឹមសារមេរៀនច្រំដែល
  - ខ្លឹមសារមេរៀនខ្លះទាបជាងសមត្ថភាពសិស្ស ខ្លះខ្ពស់ជាងសមត្ថភាពសិស្សខ្លាំងពេក
  - ការពន្យល់លើខ្លឹមសារមេរៀន មិនមានភាពច្បាស់លាស់ និងពិបាកយល់
  - ខ្លឹមសារមួយចំនួនមិនទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ ដែលនាំឱ្យសិស្សគ្មានចិត្តចង់រៀន

- លំដាប់លំដោយនៃមេរៀនមិនត្រឹមត្រូវ

➢ ខ្វះខាតឯកសារយោងដូចជាមេរៀនភាសាខ្មែរ

➢ ខ្វះខាតសម្ភារឧបទេសដោយសម្ភារៈមានស្រាប់តែតាំងលម្អ ហើយបែបបទនៃការយកសម្ភារៈមកប្រើប្រាស់នូវក្នុងថ្នាក់រៀនមានការលំបាក

➢ មិនមានការគាំទ្របច្ចេកទេស ពីប្រធាបក្រុមបច្ចេកទេសគ្រប់គ្រាន់តាមតម្រូវការនោះទេ

➢ គ្មានការចែករំលែកចំណេះដឹងរវាងគ្រូ និងគ្រូដែលជាសមាជិកក្រុមបច្ចេកទេសដូចគ្នា

➢ គោលវិធីសិស្សមជ្ឈមណ្ឌលដែលបានណែនាំក្នុងកម្មវិធីសិក្សា មិនអាចអនុវត្តបានទាំងស្រុងទេ ព្រោះ៖

- ទំហំថ្នាក់រៀនធំពេក សិស្សលើសពីនិយាមថ្នាក់នាំឱ្យពិបាកគ្រប់គ្រង និងបែងចែកក្រុម
- បរិស្ថានថ្នាក់រៀនមិនអំណោយផល ឱ្យអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបាន
- មិនមានបន្ទប់ពិសោធន៍ និងបន្ទប់ICTជាដើម

### ៥.១.៣ តម្រូវការក្នុងការអនុវត្តកម្មវិធីសិក្សាថ្មី

ប្រសិនបើមានការអភិវឌ្ឍកម្មវិធីសិក្សាលើកក្រោយលោកគ្រូ អ្នកគ្រូសំដៅលើការកែរប្រែសៀវភៅសិក្សាគោលថ្មី លោកគ្រូ អ្នកគ្រូមានតម្រូវការក៏ដូចជាយោបល់មួយចំនួនដូចជា៖

១)ត្រូវការចាំបាច់នូវសៀវភៅគ្រូគ្រប់មុខវិជ្ជាទាំងអស់ បើទោះបីជាពួកគាត់មានចំណេះដឹងលើមុខវិជ្ជាឯកទេសក៏ដោយពួកគាត់ត្រូវការសៀវភៅគ្រូ ដើម្បីជំនួយក្នុងកិច្ចតែងការបង្រៀនជាឯកសារណែនាំក្នុងការបង្រៀនបើទោះបីជាពួកគាត់ មិនបានអនុវត្តតាមសៀវភៅគ្រូទាំងស្រុងក៏ដោយ។

២)ត្រូវការវគ្គបណ្តុះបណ្តាលលើខ្លឹមសារមេរៀនថ្មីដែលបានដាក់បន្ថែមក្នុងសៀវភៅសិក្សាគោល ដោយគ្រូភាគច្រើនចង់ចូលរួមវគ្គបណ្តុះបណ្តាលដោយខ្លួនឯងព្រោះពួកគាត់មិនសូវមានទំនុកចិត្តលើប្រធានក្រុមបច្ចេកទេសក្នុងការចែករំលែកចំណេះដឹង ដែលប្រធានក្រុមទទួលបានពីវគ្គបណ្តុះបណ្តាលនានាកន្លងមកនោះទេ។

៣)ម៉ោងបង្រៀនលើមុខវិជ្ជានីមួយៗឱ្យសមស្របទៅនឹងចំនួនមេរៀន នៅក្នុងសៀវភៅសិក្សាគោល

៤)សូមគណៈកម្មការរៀបចំតាក់តែងនិពន្ធនិងបោះពុម្ពសៀវភៅសិក្សាគោល មេត្តាពិនិត្យឱ្យបានច្បាស់លាស់មុននឹងបោះពុម្ពសៀវភៅ ត្បិតអីសៀវភៅសិក្សាគោលមានកំហុសឆ្គងច្រើន និងមេត្តាពិភាក្សាគ្នារវាងមុខវិជ្ជាមួយចំនួនដូចជា គណិតវិទ្យា រូបវិទ្យា ដើម្បីឱ្យមេរៀននៅក្នុងសៀវភៅសិក្សាគោលមានការស៊ីសង្វាក់គ្នា។

## ៥.២ ពិភាក្សាលើលទ្ធផលស្រាវជ្រាវ

### ៥.២.១ ចំណេះដឹងស្ដីពីកម្មវិធីសិក្សា

តាមរយៈការស្រាវជ្រាវនេះរកឃើញថា មានគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូប្រហែលជា ៨៥%មានការយល់ដឹងតិចតួចបំផុតលើគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីសិក្សាគោល ស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតដែលចំណុចនេះដូចគ្នាទៅនឹងរបាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំសិក្សា២០១៦-២០១៧ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ដែរ ដោយនៅក្នុងរបាយការណ៍បានបង្ហាញថា លោកគ្រូ អ្នកគ្រូមានចំណេះដឹងតិចតួចបំផុតលើគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ប៉ុន្តែមិនបានលើកឡើងពីកម្រិតចំណេះដឹងនោះទេ។ការដែលមិនបានយល់ដឹងពីគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីសិក្សាគោល ស្តង់ដាកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិត ធ្វើឱ្យលោកគ្រូ អ្នកគ្រូមិនបានយល់ដឹងស៊ីជម្រៅពីគោលបំណងនិងខ្លឹមសារកម្មវិធីសិក្សាដែរ។

ការស្រាវជ្រាវនេះរកឃើញថា ៨៥%នៃគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ មិនអាចរៀបរាប់ពី **ចំណេះដឹង និងបំណិន**ដែលសិស្សទទួលបានបន្ទាប់ពីបញ្ចប់ថ្នាក់ទី១២នោះទេ លទ្ធផលនេះកាន់តែបន្ថែមទម្ងន់ថា លោកគ្រូ អ្នកគ្រូដែលជាអ្នកអនុវត្តកម្មវិធីសិក្សានៅក្នុងថ្នាក់រៀនពិតជាមិនបានយល់ដឹងពីខ្លឹមសារ និងគោលបំណងកម្មវិធីសិក្សាច្បាស់លាស់និងស៊ីជម្រៅ នោះទេ ហើយវាអាចជាកត្តាមួយបណ្ដាលឱ្យការអនុវត្តកម្មវិធិសិក្សាគ្មានប្រសិទ្ធភាព ព្រោះការដែលពឹងផ្អែកទៅលើសៀវភៅគ្រូ និងប្រធានក្រុមបច្ចេកទេសមិនអាចផ្តល់ចំណេះដឹង និងបញ្ញត្តិសំខាន់ៗរបស់កម្មវិធីសិក្សាដល់លោកគ្រូ អ្នកគ្រូនោះបានទេ។ តាមការជាក់ស្តែងចំនួនមេរៀននៅក្នុងសៀវភៅសិក្សាគោលច្រើន នោះបណ្តាលឱ្យការអនុវត្តកម្មវិធីសិក្សានៅក្នុងថ្នាក់រៀនរបស់គ្រូគ្មានស្តង់ដារួម មានន័យថាពួកគាត់ព្យាយាមកំណត់ទិសដៅដោយខ្លួនឯង អ្នកខ្លះគាត់យកការប្រឡងសញ្ញាបត្រទុតិយភូមិជាទិសដៅ ដោយគាត់ព្យាយាមទស្សទាយនូវសំណួរ ឬ

លំហាត់ដែលនឹងត្រូវចេញក្នុងការប្រឡង ប្រសិនបើមេរៀនណាឧស្សាហ៍ចេញនៅក្នុងការប្រឡង គាត់នឹងសង្កត់ធ្ងន់ទៅលើមេរៀននោះឱ្យបានច្រើន ចំណែកគ្រូខ្លះទៀតប្រសិនបើគាត់បង្រៀនច្រើនកម្រិតគាត់អាចកំណត់យកភាពទាក់ទងគ្នាពីលំដាប់ថ្នាក់នីមួយៗ នៃមេរៀនជាទិសដៅទៅវិញ ដោយគាត់សង្កត់ធ្ងន់លើមេរៀនណាដែលប្រទាក់ក្រឡាគ្នាពីថ្នាក់ទី១០ ដល់ថ្នាក់ទី១២។គ្រូខ្លះគាត់បង្រៀនតែមួយកម្រិតថ្នាក់ ហើយគាត់ព្យាយាមបង្រៀនឱ្យទាន់តែបំណែងចែក កម្មវិធីសិក្សាប្រចាំសប្តាហ៍ តែប៉ុណ្ណោះដោយមិនបានគិតពី គុណភាពសិស្ស ឬលទ្ធផលសិក្សារបស់សិស្សជាចម្បងនោះទេ។

លើសពីនេះទៅទៀត ៨៤%នៃលោកគ្រូ អ្នកគ្រូមិនបានប្រើប្រាស់លទ្ធផលនៃការវាយតម្លៃសិក្សារបស់សិស្សនៅក្នុងថ្នាក់រៀនឱ្យបានត្រឹមត្រូវនោះទេ ដោយពួកគាត់ឱ្យតម្លៃទៅលើការទាន់បំណែងចែកកម្មវិធីសិក្សាឬផែនការបង្រៀនជាជាងគុណភាពសិក្សាឬលទ្ធផលសិក្សារបស់សិស្ស ព្រោះខ្លាចទទួលបានការស្តីបន្ទោសពីអធិការកិច្ចថ្នាក់ស្រុក មន្ទីរ និងក្រសួងក៏ផ្តោតតែទៅលើការទាន់ឬមិនទាន់ផែនការបង្រៀនតែប៉ុណ្ណោះ។ MoGee (1997) ជឿថាគ្រូបង្រៀនគឺជាអ្នកធ្វើការសម្រេចចិត្តយ៉ាងសំខាន់បំផុតនៅក្នុងកម្មវិធីសិក្សា ពួកគេធ្វើការសម្រេចចិត្តជាច្រើនដោយគោរពទៅតាមកម្មវិធីសិក្សា។ គាត់ជឿថាគ្រូបង្រៀនគួរមានឯករាជភាពវិជ្ជាជីវៈដើម្បីឱ្យពួកគេអាចអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព។ប៉ុន្តែភាពពិតជាក់ស្តែងនៅក្នុងថ្នាក់រៀនរបស់លោកគ្រូ អ្នកគ្រូនៅក្នុងវិទ្យាល័យទាំង ៤ គឺ បឹងព្រះ ជា ស៊ីមរក្សជ័យ បាភ្នំនិងវិទ្យាល័យ ហ៊ុន សែន កំពង់លាវ ពួកគាត់មិនហ៊ានធ្វើការសម្រេចចិត្តនៅចំពោះមុខ នៅពេលដែលគាត់ដឹងថា សិស្សរបស់គាត់មិនយល់មេរៀននោះទេ ព្រោះខ្លាចមានកំហុស។ មួយវិញទៀតវាក៏ជាកត្តាមួយដែលជម្រុញឱ្យសិស្ស និងគ្រូចូលរួមយ៉ាងសកម្មនៅក្នុងថ្នាក់គួរក្រៅម៉ោងផងដែរ ព្រោះនៅក្នុងថ្នាក់គួរក្រៅម៉ោង លោកគ្រូ អ្នកគ្រូមានភាពម្ចាស់ការ និងមានទំនុកចិត្តក្នុងការសម្រេចចិត្តនូវអ្វីដែលគាត់ត្រូវបង្រៀនបន្ថែមដល់សិស្សដែលនាំឱ្យការរៀនគួរបន្ថែមអាចបង្កើនសមត្ថភាពសិស្ស ប៉ុន្តែក៏បង្កើតឱ្យមានបាតុភាពអវិជ្ជមានទាំងឡាយ ឬជាឧបសគ្គសម្រាប់សិស្សដែលមានជីវភាពក្រីក្រ។

តាមរយៈការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ វិស័យអប់រំឆ្នាំ ២០០៩-២០១៣នៅក្នុងសៀវភៅផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ទំព័រទី១០ បានរៀបរាប់ថា ប្រព័ន្ធអប់រំនៅកម្ពុជានៅតែប្រឈមជាមួយនឹងបញ្ហាគុណភាពអប់រំនៅឡើយ។

ដូចនេះបញ្ហាដែលគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូមិនបានដឹងពីគោលនយោបាយ អភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីសិក្សាគោល ស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិតគឺជាកត្តាមួយចូលរួមចំណែកដែលបណ្តាលឱ្យការអប់រំគ្មានគុណភាពខ្ពស់ និងភាពឆ្លើយតបដែលកត្តានេះបានលើកឡើងដោយលោក Gurol (2004) ដោយគាត់បានបង្ហាញថាការអនុវត្តកម្មវិធីសិក្សានឹងគ្មានប្រសិទ្ធភាពប្រសិនបើគ្រូមិនបានយល់ដឹងអំពីកម្មវិធីសិក្សា។

## ៥.២.២ បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធិសិក្សា

លោកគ្រូ អ្នកគ្រូយល់ឃើញថាការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពគឺសំដៅទៅលើការបង្រៀនឱ្យទាន់បំណែងចែកមេរៀន ហើយសិស្សទទួលបានលទ្ធផលសិក្សាល្អដូចរំពឹងទុកដែលមាននៅក្នុងវត្ថុបំណងមេរៀននីមយយៗ។

លោកគ្រូ អ្នកគ្រូបានលើកឡើងនូវបញ្ហាប្រឈមដូចខាងក្រោម៖

➢ ចំនួនមេរៀននិងម៉ោងបង្រៀនក្នុងមួយសប្តាហ៍មិនសមស្រប ហើយការបែងចែកម៉ោងបង្រៀនលើមុខវិជ្ជានីមួយៗនៅក្នុងវិទ្យាល័យ គឺបែងចែកទៅតាមធនធានដែលសាលាមានប៉ុណ្ណោះគឺអាស្រ័យលើចំនួនគ្រូបង្រៀន និងអាគារជាដើម។វាជារឿងត្រឹមត្រូវហើយដែលគ្រូថាចំនួនម៉ោងបង្រៀនមិនសមស្របទៅនឹង ចំនួនមេរៀននៅក្នុងសៀវភៅសិក្សាគោលនោះ ព្រោះម៉ោងដែលគាត់ត្រូវបង្រៀនមិនបានបែងចែកត្រឹមត្រូវ តាមគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សានោះទេ។និយាយរួមបញ្ហានេះមិនមែនជាបញ្ហាចំនួនមេរៀនច្រើននោះទេ តែវាជាបញ្ហាកង្វះធនធាននៅក្នុងសាលាទៅវិញ។ក៏ប៉ុន្តែបញ្ហាទាំងនេះអាចនឹងល្អប្រសើ ប្រសិនបើលោកគ្រូ អ្នកគ្រូបានយល់ដឹងពីស្តង់ដាកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត នោះគាត់ពិតជាអាចលៃលកនិងបទបែនដើម្បីបង្រៀននូវខ្លឹមសារមេរៀនដែលសំខាន់ៗដល់សិស្ស ដោយមិនពឹងផ្អែកតាមសៀវភៅសិក្សាគោលទាំងស្រុងនោះទេ។ សរុបមកក្រសួងគួរតែគិតគូរនិងដោះស្រាយពីបញ្ហាខ្វះខាតធនធាននេះជាមុនសិន មុននឹងធ្វើការអភិវឌ្ឍកម្មវិធីសិក្សាដើម្បីឱការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព។

➢ កង្វះខាតការគាំទ្របច្ចេកទេសនិងដឹកនាំបង្រៀនពីប្រធានក្រុមបច្ចេកទេស តាមរយៈ Hoy and Miskel (2008:40) ការដឹកនាំការបង្រៀនក្នុងការអនុវត្តកម្មវិធីសិក្សាថ្មីជាតួនាទីភារកិច្ចរបស់នាយកសាលា ឬនាយកត្រូវផ្ទេរភារកិច្ចនេះទៅប្រធានក្រុមបច្ចេកទេសដើម្បីលើកកម្ពស់

ការសិក្សារបស់សិស្ស។ ប្រធានក្រុមបច្ចេកទេសគួរតែលើកកម្ពស់ថ្នាក់និទស្សន៍ និងលើកកម្ពស់ឱ្យគ្រូដែលបង្រៀនមុខវិជ្ជាដូចគ្នាធ្វើការចែករំលែកចំណេះដឹង និងបទពិសោធន៍រវាងគ្នានិងគ្នា។ ប៉ុន្តែតាមរយៈការស្រាវជ្រាវរកឃើញថាគ្រូមិនបានដឹងពីខ្លឹមសារកម្មវិធីសិក្សា ដែលនេះអាចឆ្លុះបញ្ចាំងពីឆន្ទៈក្នុងការបំពេញភារកិច្ចរបស់ប្រធានក្រុមបច្ចេកទេស និងការគ្រប់គ្រងនិងចាត់តាំងបុគ្គលិករបស់នាយកសាលាមិនទាន់មានប្រសិទ្ធភាព។ មួយវិញទៀតគ្មានការចែករំលែកចំណេះដឹងរវាងគ្រូនិងគ្រូដែលជាសមាជិកក្រុមបច្ចេកទេសដូចគ្នា ទាំងនេះអាចជាលទ្ធផលនៃការប៉ះពាល់លើការបង្រៀនគួរក្រៅម៉ោង ដែលធ្វើឱ្យគ្មានការសហការគ្នាក្នុងការធ្វើការងារជាក្រុមដើម្បីសម្រេចវត្ថុបំណងអប់រំ។

➢ សៀវភៅសិក្សាគោលមានការខ្វះខាតចន្លោះច្រើនចំពោះមុខវិជ្ជាមួយចំនួន។

តាមរយៈការសិក្សាស្រាវជ្រាវរបស់ សៀង សុវណ្ណា បានរកឃើញពីបញ្ហាសៀវភៅសិក្សាគោលមុខវិជ្ជាគីមីវិទ្យាបោះពុម្ពពីឆ្នាំ១៩៩៦-២០០៤ គឺជាកត្តាមួយដែលជះឥទ្ធិពលដល់ការអនុវត្តកម្មវិធីសិក្សា ដោយសៀវភៅទាំងនេះមានបញ្ហាដូចជា (១).មានកំហុសច្រើនទាំងអក្ខរាវិរុទ្ធនិងរូបមន្ត (២).មេរៀនទាំងនោះគឺពិបាកពេកទាំងគ្រូ ទាំងសិស្ស (៣).ចំនួនម៉ោងនិងចំនួនខ្លឹមសារមិនស៊ីគ្នា (៤).ការពន្យល់ទៅលើខ្លឹមសារមេរៀនមិនមានភាពច្បាស់លាស់និងពិបាកយល់ (៥).ខ្លឹមសារមួយចំនួនមិនទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃនិងធ្វើឱ្យសិស្សគ្មានចិត្តចង់រៀន (៦).មេរៀនលំបាកៗជាច្រើនដែលមិនសមដាក់នៅកម្រិតនេះត្រូវបានគេដាក់បញ្ចូល (៧).មេរៀនសំខាន់ៗដែលចាំបាច់និងជាមូលដ្ឋានគ្រឹះមួយចំនួនមិនត្រូវបានគេដាក់បញ្ចូលនោះទេ (៨).ចំណងជើងមេរៀនរៀបគ្មានលំដាប់លំដោយ (៩).មេរៀនមួយចំនួនមិនមានសារៈសំខាន់សម្រាប់បង្រៀនសិស្សឱ្យយល់ពីគីមីវិទ្យាឡើយ (១០).លំហាត់មួយចំនួនមិនផ្សាភ្ជាប់ជាមួយខ្លឹមសារមេរៀនឡើយ (១១).រូបភាពសង្កេតមានភាពមិនច្បាស់លាស់ (១២).លំហាត់មួយចំនួនគ្មានចម្លើយនៅក្នុងសៀវភៅគ្រូ (១៣).ខ្លឹមសារពិសោធន៍មួយចំនួនមិនបានគិតពីសម្ភារៈដែលសាលាកំពុងជួបប្រទះ។ សៀវភៅដែលលោកគ្រូ អ្នកគ្រូកំពុងតែប្រើប្រាស់គ្រប់មុខវិជ្ជានេះគឺជាសៀវភៅដែលបោះពុម្ពចាប់ពីឆ្នាំ២០១០ដល់២០១៦ ប៉ុន្តែសៀវភៅទាំងនេះនៅតែមានបញ្ហាដូចលទ្ធផលស្រាវជ្រាវរបស់ សៀង សុវណ្ណា ដដែល។

សរុបសេចក្តីមកយើងអាចសន្និដ្ឋានបានថា បញ្ហាប្រឈមដែលលោកគ្រូ អ្នកគ្រូបានជួបប្រទះក្នុងការអនុវត្តកម្មវិធីសិក្សានោះគឺ ១) ចំនួនមេរៀននិងម៉ោងបង្រៀនក្នុងមួយសប្តាហ៍ មិនសមស្រប ២) កង្វះខាតការគាំទ្របច្ចេកទេសនិងដឹកនាំបង្រៀនពីប្រធានក្រុមបច្ចេកទេស ៣) សៀវភៅសិក្សាគោលមានការខ្វះខាតចន្លោះច្រើនចំពោះមុខវិជ្ជាមួយចំនួន ៤)ចំណេះដឹងរបស់គ្រូលើកម្មវិធីសិក្សានៅមានកម្រិតនិង ៥) ភាពខ្វះសិទ្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត របស់គ្រូ។

## ៥.៣ សំណូមពរ

តាមលទ្ធផលនៃការសិក្សាស្រាវជ្រាវខាងលើ ខ្ញុំបាទសូមសំណូមពរដល់:

### ក. អ្នករៀបចំគោលនយោបាយអប់រំ

-សូមធ្វើការផ្សព្វផ្សាយនូវកម្មវិធីសិក្សាឱ្យបានទូលំទូលាយដោយដាក់បញ្ចូលវគ្គ កម្មវិធីសិក្សានៅក្នុងវគ្គបណ្តុំបណ្តាលគ្រូបង្រៀន

-សូមប្រើប្រាស់ពាក្យកម្មវិធីសិក្សាឱ្យបានច្បាស់លាស់ នៅពេលមានវគ្គបណ្តុំបណ្តាល

-រៀបចំសេចក្តីនែនាំស្តីពីការអនុវត្តកម្មវិធីសិក្សាដោយមានចែងពីតួនាទី ភារកិច្ច ដែនកំណត់សិទ្ធក្នុងការសម្រេចចិត្ត កម្រិតចំណេះដឹងលើកម្មវិធីសិក្សារបស់ភាគីពាក់ព័ន្ធឱ្យបានច្បាស់លាស់។

### ខ. គណៈគ្រប់គ្រងសាលារៀន

គួរតែផ្តោតសំខាន់ទៅលើគុណភាពអប់រំជាចំបងដោយត្រូវប្រាកដថាលទ្ធផលសិក្សារបស់សិស្សដែលទទួលបានពីលោកគ្រូ អ្នកគ្រូ ពិតជាត្រឹមត្រូវ និងស្របតាមសមត្ថភាពរបស់សិស្សនៅក្នុងសាលារបស់ខ្លួនមែន ដោយពង្រឹងឡើងវិញនូវ ការចុះធ្វើអធិការកិច្ចផ្ទៃក្នុងរបស់ខ្លួនត្រង់ចំណុចគុណភាពជាជាងការទាន់ផែនការដែលខ្លួនបានកំណត់ ព្រោះវាជះឥទ្ធិពលដល់ការសិក្សារបស់សិស្សតាមលំដាប់ថ្នាក់។

-គួរធ្វើការជ្រើសរើស និងចាត់តាំងអ្នកដែលមានមនសិការខ្ពស់ក្នុងការចែករំលែកចំណេះដឹងដែលសមស្របតាមឯកទេសរបស់គាត់មកទទួលវគ្គបណ្តុះបណ្តាលនានា ដែលផ្តល់ដោយក្រសួង។

-សូមផ្សព្វផ្សាយឱ្យបានច្បាស់លាស់ពីកម្មវិធីសិក្សាដល់គ្រូដែលស្ថិតនៅក្នុង អង្គភាពរបស់ខ្លួន ត្រូវចែករំលែក ឬផ្សព្វផ្សាយអំពីរបាយម៉ោងសិក្សាលើមុខវិជ្ជានីមួយៗក្នុងមួយសប្តាហ៍តាមក្របខណ្ឌកម្មវិធីសិក្សាដល់លោកគ្រូ អ្នកគ្រូឱ្យពួកគាត់បានដឹងផង។

## គ.ប្រធានក្រុមបច្ចេកទេស

-របៀបវារៈនៅក្នុងអង្គប្រជុំគួរតែផ្តោតសំខាន់លើគុណភាពអប់រំ ដែលឆ្លុះបញ្ចាំងតាមរយៈលទ្ធផលសិក្សារបស់សិស្សក្នុងខែនីមួយៗជាជាងផ្តោតតែទៅលើការទាន់ ឬមិនទាន់កម្មវិធីសិក្សា

-គួរតែតាមដាននូវដំណោះស្រាយពីថ្នាក់គ្រប់គ្រងសាលារៀន ចំពោះការលំបាករបស់គ្រូដែលបានលើកឡើងក្នុងការអនុវត្តកម្មវិធិសិក្សាក៏ដូចជាការបង្រៀន។

-គួរចេះចែករំលែកនូវចំណេះដឹង និងព័ត៌មានដែលខ្លួនទទួលបានពីវគ្គបណ្តុះបណ្តាលក៏ដូចជាសិក្ខាសាលាផ្សេងៗទៅដល់សមាជិករបស់ខ្លួន។

## ឃ.គ្រូបង្រៀន

-ស្វែងរកចំណេះដឹងស្តីពីកម្មវិធីសិក្សាឱ្យបានស៊ីជម្រៅ និងចេះបទបែនក្នុងម៉ោងបង្រៀនរបស់ខ្លួនដោយផ្អែកលើស្តង់ដាកម្មវិធីសិក្សា

-មានការតាំងចិត្ត និងមនសិការខ្ពស់ក្នុងការអនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាពខ្ពស់ ស្រាវជ្រាវឯកសារបន្ថែមតាមរយៈបណ្ណាល័យ បណ្ណាគារ និងតាមបណ្តាគេហទំព័រនានាដូចជា គេហទំព័ររបស់ក្រសួងអប់រំយុវជន និងកីឡាដែលតែងតែចែករំលែកឯកសារសំខាន់ៗនៅក្នុងវិស័យអប់រំនេះ។

-គួរដឹងនិងពន្យល់សិស្សឱ្យដឹងពីសារៈសំខាន់នៃការសិក្សារបស់ខ្លួន ដើម្បីឱ្យសិស្សយកចិត្តទុកដាក់ក្នុងការសិក្សាមុខវិជ្ជានេះជាជាងផ្តោតសំខាន់តែលើមុខវិជ្ជាដែលមានចេញប្រឡងបបញ្ចប់ សិក្សាទុតិយភូមិ។

## ឯកសារពិគ្រោះ


ក្រសួងអប់រំយុវជន និងកីឡា(១៩៩៦ក) កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយ- ភូមិ ភ្នំពេញ វិទ្យាស្ថានស្រាវជ្រាវនៃក្រសួងអប់រំ យុវជន និងគីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា(១៩៩៦ខ) កម្មវិធីសិក្សាគោលសម្រាប់មធ្យមសិក្សាទុតិយ- ភូមិ ភ្នំពេញ វិទ្យាស្ថានស្រាវជ្រាវនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០០៤) គោលនយោបាយអភិវឌ្ឍកម្មវិធីសាក្សាចំណោះ ទូទៅ ២០០៥-២០០៩ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០០៦ក) កម្មវិធីសិក្សាគោល សម្រាប់អប់រំមូលដ្ឋាន ចំណោះ ទូទៅភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួង អប់រំ យុវជន និងកីឡា នៃ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០០៦ខ) កម្មវិធីសិក្សាលម្អិត សម្រាប់អប់រំមូលដ្ឋានចំណោះ ទូទៅភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួង អប់រំ យុវជន និងកីឡានៃ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០០៩) កម្មវិធីសិក្សាលម្អិតភាសាខ្មែរ និងអក្សរសាស្ត្រខ្មែរ ផែនដីនិងបរិស្ថាន និងសិក្សាសង្គមសម្រាប់មធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ទី១១ និង ទី១២ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យនៃក្រសួង អប់រំ យុវជន និងកីឡានៃ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០១០) ផែនការគោលបច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍ ក្នុងវិស័យអប់រំ ២០០៩-២០១៣ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា នៃ ព្រះរាជាណាចក្រ កម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០១៨ក) គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា នៃ ព្រះរាជាណាចក្រ កម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០១៤ខ) គោលនយោបាយស្តីពីការអប់រំបច្ចេកទេស ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា នៃ ព្រះរាជាណាចក្រ កម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០១៤គ) គោលនយោបាយស្តីពីសៀវភៅសិក្សា និងមគ្គុទេសក៍សម្រាប់ការអភិវឌ្ឍសៀវភៅសិក្សាគោល ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា នៃ ព្រះរាជាណាចក្រ កម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងអប់រំយុវជន និងកីឡា (២០១៦) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ភ្នំពេញ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការនៃក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំយុវជន និងកីឡា (២០១៦) ក្របខណ្ឌកម្មវិធិសិក្សាចំណេះទូទៅ និងអប់រំ បច្ចេកទេស ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ហង់ជួន ណារ៉ុន(២០១៦) កំណែទម្រង់វិស័យអប់រំនៅកម្ពុជា មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព ភ្នំពេញ

សៀង សុវណ្ណា ភាពខ្វះចន្លោះរបស់សៀវភៅសិក្សាគោលគីមីវិទ្យាបោះពុម្ពនៅចន្លោះឆ្នាំ ១៩៩៦-២០០៤ ភ្នំពេញ

Angelo, T.(1995). Ressessing (and Defining) Assessment. The AAHT Bulletin,48(2), 7-9.Birgit P, Sven A.S, Ragnhild L.S, Heidi D, Maria I. M.F.(2014).National Working papers on analysis of policy context.

Cart,A.(2009). Teacher Empowerment through curriculum development theory into practice.

ASEAN (2012).ASEAN curriculum sourcebook.

Ministry of Education of Singapore (2012). Nurturing early learners: Curriculem framework for kindergarten in Singapore.

Ministry of Education of Singapore (2012). Education system of Singapore.

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៩៦៣៣**អយក.**ដល

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩។

និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវ តាមសាកលវិទ្យាល័យ និងរាជធានី ខេត្តនានា ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០ តាមបំណែងចែកដូចខាងក្រោម៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កូវ ប៊ុន្ថា | ប្រុស | តាកែវ |
| ២ | កែម សុកែវ | ប្រុស | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៣ | ជិន ភិរម្យ | ប្រុស | ព្រៃវែង |
| ៤ | ញ៉ែម ធា | ប្រុស | ត្បូងឃ្មុំ កំពង់ចាម ព្រៃវែង |
| ៥ | ឌៀន សុគុណ | ប្រុស | ព្រៃវែង |
| ៦ | ផន ឡេង | ប្រុស | ភ្នំពេញ |
| ៧ | ភោគ ស៊ីថន | ប្រុស | សៀមរាប |
| ៨ | ម៉េត ចាន់ណេត | ប្រុស | កណ្តាល |
| ៩ | យ៉ុន សុខេន | ប្រុស | ភ្នំពេញ |
| ១០ | វ៉ាន់ លីឆេង | ប្រុស | បាត់ដំបង |
| ១១ | ស្រី ស្មើ | ប្រុស | ភ្នំពេញ |
| ១២ | ហុក វិចិត្រ | ប្រុស | ព្រះវិហារ |
| ១៣ | ឡុង ចំណាន | ប្រុស | កំពង់ចាម |

ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- សាលារាជធានី-ខេត្តពាក់ព័ន្ធ "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអ.យ.ក "ដើម្បីជ្រាបជាព័ត៌មាន"
- មន្ទីរអ.យ.ក រាជធានី-ខេត្តដែលពាក់ព័ន្ធ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ រដអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខៈ ៦២៩២០ អយក.វិធ

*ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩*

**ជម្រាបមក**
**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវរបស់និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៅតាមសាកលវិទ្យាល័យ និងរាជធានី ខេត្ត។
**យោង ៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ ឆ្នាំសិក្សា ២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកប្រធានថាៈ និស្សិតវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ ចំនួន១៣នាក់ ដូចមានក្នុងលិខិតឧទ្ទេសនាមជូនភ្ជាប់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរ និក្ខេបបទស្រាវជ្រាវតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២០។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកប្រធានទទួលនូវការរាប់អានពីខ្ញុំ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូនៈ**
-ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
-សាលារាជធានី-ខេត្តពាក់ព័ន្ធ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងអ.យ.ក
"ដើម្បីជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ - ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# កម្រងសំណួរ

ខ្ញុំបាទឈ្មោះ **ជិន តិរម្យ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសវិជ្ជាជីវៈនាយកសាលាជំនាន់ទី២នៅវិទ្យាស្ថានជាតិអប់រំ។ដើម្បីបំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់នេះខ្ញុំបាទបានជ្រើសរើសធ្វើការស្រាវជ្រាវទៅលើប្រធានបទ**«ទស្សនៈយល់ឃើញរបស់នាយកសាលា និងគ្រូវិទ្យាល័យលើការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី»** ។កិច្ចការស្រាវជ្រាវនេះមានបំណងរកឱ្យឃើញពីចំណេះដឹង ទស្សនៈ បញ្ហាប្រឈម និងតម្រូវការក្នុងការអនុវត្តកម្មវិធីសិក្សារបស់នាយកសាលា លោកគ្រូ អ្នកគ្រូនៅក្នុងកម្រិត វិទ្យាល័យ។ការចូលរួមក្នុងកិច្ចពិភាក្សា ឬការសម្ភាសន៍របស់លោកគ្រូ អ្នកគ្រូពិតជាមាន សារៈសំខាន់ណាស់ ព្រោះវាមិនត្រឹមតែជួយខ្ញុំបាទក្នុងការបំពេញលក្ខខណ្ឌប៉ុណ្ណោះទេ វាថែម ទាំងជួយនាំយោបល់របស់លោកគ្រូ អ្នកគ្រូជូនដល់នាយកដ្ឋានកម្មវិធីសិក្សា ដើម្បីចូលរួម ចំណែកក្នុងការអភិវឌ្ឍកម្មវិធីសិក្សាលើកក្រោយទៀត។ មតិយោបល់ទាំងអស់ដែលបានបញ្ចេញ នៅក្នុងក្រុមពិភាក្សា ត្រូវបានបង្ហាញជាលទ្ធផល នៃកិច្ចពិភាក្សាជាក្រុមដោយ មិនមែនសំដៅ លើមតិយោបល់របស់បុគ្គលណាមួយ ក្នុងចំណោមអ្នកចូលរួមឡើយ។ដូចនេះរាល់ យោបល់ របស់បុគ្គលម្នាក់ៗត្រូវបានរក្សាការសម្ងាត់។

សំគាល់៖ប្រសិនបើលោកគ្រូ អ្នកគ្រូមានអារម្មណ៍មិនចង់ចូលរួមនៅក្នុងកិច្ចពិភាក្សានេះទេ លោកគ្រូ អ្នកគ្រូអាចមានសិទ្ធចាកចេញបាន។កម្រងសំណួរសម្រាប់សម្ភាសន៍នាយកសាលា និងគ្រូបង្រៀន

I. ព័ត៌មានផ្ទាល់ខ្លួន

1. ស្រុក/ក្រុង:……………………………………………..
2. ឈ្មោះសាលា :…………………………………………..
3. ឋានៈ តួនាទី ☐ នាយក/នាយិកា ☐ នាយករង/នាយិការង ☐ បង្រៀន
4. ភេទ : ☐ ប្រុស ☐ ស្រី
5. កម្រិតវប្បធម៌ : …………………………………………………….
6. មុខវិជ្ជាឯកទេស: …………………………………………………….

II. ចំណេះដឹង និងទស្សនៈទាក់ទងទៅនឹងកម្មវិធីសិក្សា

១) តើពាក្យមួយចំនួននេះមានន័យដូចម្តេច?

-

កម្មវិធីសិក្ស……………………………………………………………………………………………

……………………………………………………………………………………………………………

………..………………………………………………………………………………………………

……………………….

……………………………………………………………………………………………………………

…………..

-

ស្តង់ដាកម្មវិធីសិក្សា…………………………..........................................................................

.

……………………………………………………………………………………………………………

..………………………………………………………………………………………………………

……………………….

-

កម្មវិធីសិក្សាលម្អិត………………………………..................................................................

.

……………………………………………………………………………………………………………

..………………………………………………………………………………………………………

……………………

២) តើលោក/លោកស្រីបានដឹង ឬទទួលការផ្សព្វផ្សាយអំពីកម្មវិធីសិក្សាថ្មីយ៉ាងដូចម្តេចដែរ? តាមរយៈអ្វី?

………………………………………………………………………………………………………

…..……………………………………………………………………………………………..………

……..…………..………………………………………………………………………………….

......................................

៣)តើលោក/លោកស្រីធ្លាប់ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីសិក្សាថ្មីដែរ ឬទេ?

………………………………………………………………………………………………………

…………….

៤)តើនៅក្នុងកម្មវិធីសិក្សាថ្មីគេចែកចេញជាប៉ុន្មានបណ្តុំមុខវិជ្ជា ? អ្វីខ្លះ ?

………………………………………………………………………………………………………

……………..……………………………………………………………………………………….

……………………………..

៥)តើការបែងចែកបណ្តុំមុខវិជ្ជាចាប់ពីថ្នាក់ទីប៉ុន្មាន ? តាមទស្សនៈលោក/លោកស្រី ការបែងចែកនេះជាការល្អ ឬទេ ? ព្រោះអ្វី ?

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

………………………………………………………………………………………………………

៦)ក្នុងកម្មវិធីសិក្សាថ្មីនេះសរុបម៉ោងសិក្សាក្នុងមួយសប្តាហ៍គឺ ៤០ ម៉ោង ។សូមលោក/លោកស្រីពិនិត្យតារាងរបាយមុខវិជ្ជានិងម៉ោងសក្សា រួចឆ្លើយទៅនឹងសំណួរដូចខាងក្រោម៖

| លរ | មុខវិជ្ជា(វិទ្យាសាស្ត្រពិត) | ថ្នាក់ | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | ភាសាខ្មែរ | ៥ | ៥ | ៥ |
| ២ | គណិតវិទ្យា | ៦ | ៦ | ៦ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | ៤ | ៤ | ៤ |
| ៧ | ផែនដីវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ២ | ២ | ២ |
| ៩ | ជីវវិទ្យា | ២ | ២ | ២ |
| ១០ | ប្រវត្ត | ២ | ២ | ២ |
| ១១ | ភូមិ | ៣ | ៣ | ៣ |
| ១២ | សីលធម៌ពលរដ្ឋ | ៣ | ៣ | ៣ |
| ១៣ | (ICT ) | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៤០ | ៤០ | ៤០ |

| លរ | មុខវិជ្ជា(វិទ្យាសាស្ត្រសង្គម | ថ្នាក់ | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | ភាសាខ្មែរ | ៦ | ៦ | ៦ |
| ២ | គណិតវិទ្យា | ៥ | ៥ | ៥ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |
| ៦ | រូបវិទ្យា | ២ | ២ | ២ |
| ៧ | ផែនដីវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ២ | ២ | ២ |
| ៩ | ជីវវិទ្យា | ២ | ២ | ២ |
| ១០ | ប្រវត្ត | ៤ | ៤ | ៤ |
| ១១ | ភូមិ | ៣ | ៣ | ៣ |
| ១២ | សីលធម៌ពលរដ្ឋ | ៣ | ៣ | ៣ |
| ១៣ | (ICT ) | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៤០ | ៤០ | ៤០ |

ក)តើលោក/លោកស្រីគិតថាមានគ្រូបង្រៀនគ្រប់គ្រាន់ដែរឬទេ?

……………………………………………………………………………………………………………

………….……………………………………………………………..........................................................

ខ )មានបន្ទប់គ្រប់គ្រាន់ឬទេ?

..........................................................................................................

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

គ )អនុវត្តបានដែរឬទេ?

ព្រោះអ្វី?………………………………………………........................................................

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

ឃ )គុណភាពសិក្សាយ៉ាងដូចម្តេចនិងមានចំណុចវិជ្ជមានអ្វីខ្លះ?................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

ង )ចំណុចអវិជ្ជមានឬបញ្ហាប្រឈមអ្វីខ្លះ ? ……………………………………………………………

.....………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

ច)តើលោកលោកស្រីមានទស្សនៈឬមធ្យោបាយដូចម្តេចខ្លះដើម្បីឱ្យការអនុវត្តកម្មវិធីសិក្សាថ្មីនេះប្រកបដោយគុណភាពខ្ពស់?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

៧)តើលោក/លោកស្រីពេញចិត្តនឹងការអនុវត្តកម្មវិធីសិក្សាថ្មីនេះដែរ ឬទេ ? ហេតុអ្វី ?

…………………………………………………………………………………………………………

…………..……………………………………………………………………………………………

…………………………..………………………………………………………………………………

៨)តើលោក/លោកស្រីចង់ឱ្យក្រសួងអនុវត្តកម្មវិធីសិក្សាចាស់ឬកម្មវិធីសិក្សាថ្មី ?

…………………………………………………………………………………………………………

៩)តើនៅសាលារបស់លោក/លោកស្រីបានអនុវត្តក្នុងការបង្រៀន
និងរៀនមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍(ICT )ហើយ ឬនៅ ?

-បានហើយ : នៅកម្រិតថ្នាក់ទីប៉ុន្មាន ?..........................................គិតថាល្អដែរឬទេ ?
.................................ព្រោះអ្វី ?

..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................

-មិនទាន់បានទេ :

មូលហេតុ៖…………………………………………………………………………….

………………………………………………………………………………………………………
………………………………………………………………………………………………………
………………………………………………………………………………………………………
…………………………………………………………………………………………..........................